Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមីនា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០០




# ពលរដ្ឋកម្ពុជាចាប់អារម្មណ៍នឹងសេវាកម្មដឹកជញ្ជូនតាមរថភ្លើងប៉ុន្តែរអ៊ូរឿងពេលវេលា

*photo supply*

## សេចក្ដីជូនដំណឹង

“គ្មាននរណាមានសេចក្ដីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ ។” (យហ. ១៥,១៣) គំរូរបស់មរណសាក្សី ជួយជំរុញជំនឿរបស់យើងៗ សូមអរគុណបងប្អូន ដែលផ្ដល់ព័ត៌មានមួយចំនួនហើយទាក់ទងនឹងមរណសាក្សីរបស់យើងៗ យើងនៅតែត្រូវការរូបថត លិខិតឬស្នាដៃរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ទាំងនោះៗ សូមបងប្អូនផ្ដល់ព័ត៌មានឲ្យយើងទាំងនោះ តាមរយៈអាសយដ្ឋាននៅខាងក្រោម៖

Tel : 077 800 211 / 096 34 22 144

Email: martyrscambodia@gmail.com

ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# បុណ្យរោយផេះ រំឭកយើងពីប្រភពកំណើត និងស្លាប់ទៅវិញក្លាយជាធូលីដី

ព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុននៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានប្រារព្ធពិធីបុណ្យរោយផេះដែលជាបុណ្យប្រពៃណីរបស់ព្រះសហគមន៍កាតូលិក។

ពិធីបុណ្យនេះបានប្រព្រឹត្តឡើងនៅថ្ងៃពុធ ដែលជាថ្ងៃដំបូងក្នុងរដូវអប់រំពិសេស ឬរដូវត្រណម ក្រោមអធិបតីភាពលោកអភិបាល អូលីវីយេ ឝ្មិតអីស្លែរ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដោយមានគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ កាលពីថ្ងៃទី១ មីនា ២០១៧នេះ។

មុននឹងចាប់ផ្តើមអភិបូជានៃពិធីបុណ្យនេះ លោកអភិបាលបានមានប្រសាសន៍រំឭកអំពីបុណ្យនេះថា នេះជាថ្ងៃទីមួយនៃរដូវអប់រំពិសេស ដែលព្រះជាម្ចាស់អញ្ជើញយើងដែលជាព្រះសហគមន៍ឲ្យកែប្រែចិត្តគំនិត និងជឿលើដំណឹងល្អ។ លោកថាពិធីរោយផេះនេះ គឺរំឭកយើងដែលកើតពីធូលីដី និងស្លាប់ទៅក្លាយជាធូលីដីវិញ ហើយក៏ជាឱកាសមួយឲ្យយើងភ្ញាក់ស្មារតីដោយរស់នៅក្នុងជីវិតថ្មី ក្នុងរយៈពេល ៤០ថ្ងៃខាងមុខ។

នៅក្នុងធម្មទេសនា លោកអូលីវីយេបានអប់រំគ្រីស្តបរិស័ទឲ្យចេះស្តាប់ និងអនុវត្តតាមព្រះបន្ទូល គឺឲ្យទៅរកព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត។ លោកបន្តថា យើងបានចេញពីរដូវបុណ្យព្រះយេស៊ូប្រសូត និងបានចូលនៅក្នុងរដូវធម្មតា ហើយជីវិតរបស់យើងបានជាប់ជាមួយការងារ រវល់ជាមួយនឹងបញ្ហា និងកិច្ចការផ្ទាល់ខ្លួនច្រើន ហើយនៅពេលយើងចូលនៅក្នុងរដូវត្រណម ជាឱកាសមួយដើម្បីឲ្យយើងនឹកឃើញថា ព្រះជាម្ចាស់ទន្ទឹងរង់ចាំយើង។ យើងត្រូវវិលរវល់ជាមួយព្រះជាម្ចាស់សារជាថ្មី ដើម្បីសូមឲ្យព្រះអង្គគង់នៅជាមួយយើងគ្រប់ពេលវេលា។

លោកអភិបាលក៏បានបង្ហាញអំពីរបៀបដែលគ្រីស្តបរិស័ទ ត្រូវរត់ទៅរកព្រះយេស៊ូវិញដោយលើកយកសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ ដែលបានណែនាំគ្រីស្តបរិស័ទទាំងអស់ក្នុងរដូវអប់រំពិសេសនេះឲ្យចេះទទួលស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជាអំណោយទាន និងទទួលស្វាគមន៍បងប្អូនឯទៀតៗ ជាអំណោយទាន។ លោកក៏បានបញ្ជាក់បន្ថែមអំពីរបៀបទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ ក្នុងរដូវបុណ្យអប់រំពិសេសនេះ គឺយើងត្រូវ ធ្វើទាន អធិដ្ឋាន និងតមអាហារ។ មុននឹងយើងតមអាហារ គឺធ្វើទានជួយបងប្អូនឯទៀតៗ។ សូមឲ្យយើងយកពេលវេលា៤០ថ្ងៃនេះ ក្នុងរដូវនេះដើម្បីអធិដ្ឋាន ព្រោះថាពេលយើងចូលនៅក្នុងអធិដ្ឋាន គឺជាពេលវេលាមួយឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង នៅក្នុងជីវិតរបស់យើងយ៉ាងពិតប្រាកដមែន។

លោកអភិបាលបានសំណូមពរថា ដើម្បីអធិដ្ឋាន គឺមុនដំបូងយើងត្រូវបិទសម្លេងជុំវិញយើង ដូចការណែនាំរបស់ព្រះយេស៊ូ គឺនៅពេលអធិដ្ឋានយើងត្រូវចូលនៅក្នុងបន្ទប់របស់យើង ចូលទៅក្នុងដួងចិត្តរបស់យើងដើម្បីទុកឲ្យព្រះយេស៊ូមានព្រះបន្ទូលមកយើង។

លោកអូលីវីយេបានលើកឡើងទៀតថា សម្តេចប៉ាបបានអញ្ជើញយើងឲ្យស្តាប់ព្រះបន្ទូល គឺដើម្បីឲ្យព្រះបន្ទូលកែប្រែចិត្តគំនិត ដូចនេះសូមអានព្រះបន្ទូលជារៀងរាល់ថ្ងៃ។ ហើយព្រះបន្ទូលណែនាំជីវិតយើង លុះត្រាតែយើងយកព្រះបន្ទូលនេះឲ្យចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់យើង។ មិនតែប៉ុណ្ណោះលោកស្នើសុំឲ្យគ្រីស្តបរិស័ទតមអាហារជារៀងរាល់ថ្ងៃសុក្រក្នុងរដូវនេះ។ លោកថាតមអាហារគឺដើម្បីរកផលប្រយោជន៍នៅក្នុងជីវិតរបស់យើង ដោយត្រឡប់ទៅរកព្រះយេស៊ូវិញ ដោយទុកឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ សូន្យបេះដូង សូន្យជីវិតយើងសារជាថ្មី តាមរយៈការកែប្រែឥរិយាបទ ទស្សនៈ និងដួងចិត្តរបស់យើង ដើម្បីធ្វើជាមនុស្សថ្មី។ ចំណុចចុងក្រោយគឺបន្ទាប់ពេលក្លាយជាមនុស្សថ្មីហើយ សូមសម្រេចចិត្តជួយបងប្អូនឯទៀតៗ ដោយជាក់ស្តែង និងផ្ទាល់ខ្លួន កុំទុកឲ្យតែក្រុមសង្គហៈធ្វើឡើយ។

ក្រោយពីធម្មទេសនា លោកអភិបាល និងលោកបូជាចារ្យ បានប្រទានពរលើផេះ (ដែលបានមកពីស្លឹកព្រះពរក្នុងឱកាសបុណ្យព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ឬបុណ្យហែរស្លឹក) រួចយកមកគូសជាសញ្ញាឈើឆ្កាងដល់គ្រីស្តបរិស័ទ និងអ្នកដែលកំពុងស្វែងយល់ពីជំនឿ។

ពិធីបុណ្យរោយផេះ ជាពិធីបុណ្យមួយរបស់ព្រះសហគមន៍កាតូលិកសកល ដែលធ្វើឡើងនៅថ្ងៃពុធក្នុងដើមរដូវអប់រំពិសេស ដែលមានរយៈពេល៤០ថ្ងៃ។

*ដោយដាលីស*



*ថតដោយ ដាលីស*

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ត្រូវរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ គឺជាប់នឹងព្រះបន្ទូល



លោក លី សុវណ្ណា
ចាងហ្វាងកាសែតអ្នកនាំសារ

តាមប្រតិទិនព្រះសហគមន៍កាតូលិកចាប់ពីថ្ងៃទី១ ខែមីនា រហូតដល់ពាក់កណ្តាលខែមេសា ឆ្នាំ២០១៧ ជាពេលមួយយ៉ាងពិសេសបំផុតសម្រាប់គ្រីស្តបរិស័ទកាតូលិក ដើម្បីភ្ញាក់ស្មារតីវិលត្រលប់មកកេព្រះជាម្ចាស់ ឬក៏ជាពេលវេលាមួយ ត្រូវរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ គឺជាប់នឹងព្រះបន្ទូលរបស់ព្រះអង្គ។

តាមព្រះសហគមន៍កាតូលិក រយៈពេលនេះជារដូវអប់រំពិសេស ឬរដូវត្រណមដែលមានរយៈពេល៤០ថ្ងៃ រហូតដល់ថ្ងៃបុណ្យព្រះយេស៊ូសោយទិវង្គត ហើយមានព្រះជន្មរស់ឡើងវិញ។

ក្នុងសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សម្រាប់រដូវអប់រំពិសេសនេះ លោកបានរំឭកដល់គ្រីស្តបរិស័ទទាំងអស់យកចិត្តទុកដាក់ នឹងព្រះបន្ទូល និងយកចិត្តទុកដាក់អំពីរបៀបដែលយើងប្រព្រឹត្តចំពោះអ្នកដទៃ។

ក្នុងសារលិខិតនេះក៏បានបង្ហាញអំពីទង្វើមួយចំនួន ដែលនាំឲ្យមនុស្ស ធ្លាប់ក្នុងអំពើបាប ដែលនាំវិនាស គឺនាំឲ្យមនុស្សខ្វាក់ភ្នែក។ សម្តេចប៉ាបបានបង្ហាញនូវប្រភពដែលនាំឲ្យមនុស្សធ្លាក់ក្នុងអំពើបាប គឺការស្រឡាញ់ប្រាក់ ភាពក្រអឺតក្រទម និងភាពអំនួត។

ការស្រឡាញ់ប្រាក់ជាមូលហេតុដ៏ចំបងជាងគេ នាំឲ្យប្រព្រឹត្តអំពើពុករលួយ ជាដើមកំណើតនៃការច្រណែន ឈ្នានីស ការប្រកែកគ្នា និងមន្ទិលសង្ស័យគ្នាទៅវិញទៅមក។

ប្រាក់ក៏អាចបណ្តាលឲ្យយើងធ្វើអំពើល្អបានដែរ។ ប៉ុន្តែផ្ទុយទៅវិញ ប្រាក់អាចបណ្តាលឲ្យយើងរស់នៅដូចជាខ្ញុំបម្រើ ធ្វើឲ្យពិភពលោកនេះ គិតតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានកន្លែងសម្រាប់សេចក្តីស្រឡាញ់ ជាការរារាំងនូវសន្តិភាព។

ចិត្តលោភលន់បណ្តាលឲ្យអ្នកមានក្នុងគម្ពីរ ទៅជាមនុស្សក្រអឺតក្រទម។ គេចូលចិត្តបង្ហាញអ្វីៗដែលជាសំបកក្រៅ បង្ហាញឲ្យគេឃើញនូវអ្វីៗដែលគេចម្រេចបាន គឺបិទបាំងនូវអ្វីៗដែលខ្វះខាតនៅក្នុងខ្លួនរបស់គេ។ ការរស់នៅរបស់គេ គឺអាស្រ័យលើតែរបស់ខាងក្រៅប៉ុណ្ណោះ។

ភាពអំនួតជាកម្រិតទាបជាងគេ នៃអំពើអសីលធម៌របស់ខ្លួន។ អ្នកពុករលួយដែលស្រឡាញ់ធនធានគេគិតតែខ្លួនឯងប៉ុណ្ណោះ។ ជាហេតុនាំឲ្យគេក្លាយជាមនុស្សខ្វាក់ មើលមិនឃើញអ្នកនៅជុំវិញខ្លួនគេនោះទេ។

ពិតណាស់ក្នុងរដូវអប់រំពិសេសនេះ យើងអាចសួរខ្លួនឯងថា ប៉ុន្មានដងខ្ញុំមានចិត្តលោភលន់ បំពានអ្នកដទៃ កេងចំណេញពីអ្នកដទៃ? ប៉ុន្មានដងខ្ញុំមិនយកចិត្តទុកដាក់នឹងបងប្អូនរបស់ខ្ញុំ ដែលត្រូវការឲ្យខ្ញុំយកចិត្តទុកដាក់? ប៉ុន្មានដងខ្ញុំបោកបញ្ឆោតគេ ដើម្បីប្រយោជន៍ខ្ញុំ? ប៉ុន្មានដងខ្ញុំមិនអើពើនឹងអយុត្តិធម៌សង្គម?

យើងរស់នៅក្នុងពិភពលោកនេះដែលមានភាពស្រស់ស្អាត ត្រូវតែទទួលស្គាល់លទ្ធផលដែលសង្គមមាន។ ម្យ៉ាងក៏ត្រូវតែស៊ូប្រឆាំង និងអំពើអយុត្តិធម៌ ភាពលោភលន់ អំពើពុករលួយ ភាពឃោរឃៅ និងអំពើអសីលធម៌នានា ដែលនាំឲ្យមនុស្សវិនាស និងសង្គមទាំងមូលវិនាស។ល។

ចូរស្ញៀមស្ងាត់ ឲ្យព្រះបន្ទូលបានចូលក្នុងចិត្ត គំនិត និងចូលក្នុងបេះដូងរបស់បងប្អូន ហើយអនុវត្តន៍ដោយយកចិត្តទុកដាក់ឲ្យអស់ពីសមត្ថភាព យកចិត្តទុកដាក់ចំពោះអ្នកដែលនៅក្រៅសង្គម អ្នកក្រីក្រទ្រព្យសម្បត្តិ និងក្រីក្រខាងវិញ្ញាណ។

ភ្ញាក់ស្មារតីដើម្បីចូលរួមកែប្រែសហគមន៍យើង ដែលអសកម្ម ឲ្យបានពោរពេញដោយសេចក្តីស្រឡាញ់ មេត្តាករុណា សន្តិភាព យុត្តិធម៌ ការលើកលែងទោស និងសុភមង្គល។

# ពិធីប្រោះទឹកព្រះពរបើកការដ្ឋានសាងសង់អគារថ្មីនៃសហគមន៍គ្រីស្តបរិស័ទជនជាតិកូរ៉េ

គម្រោងសាងសង់អគារថ្មីសម្រាប់បម្រើការឲ្យការធ្វើសកម្មភាពផ្សេងៗរបស់សហគមន៍គ្រីស្តបរិស័ទកាតូលិកជនជាតិកូរ៉េ ដែលកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមដោយពិធីប្រោះទឹកព្រះពរបើកការដ្ឋានសាងសង់កាលពីរសៀលថ្ងៃអាទិត្យទី០៥មីនា ២០១៧កន្លងទៅ នៅមណ្ឌលសកម្មភាពភ្នំពេញថ្មីក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឆ្មឺតអឺស្លែរជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកបូជាចារ្យសួន ហង្សលីជាបូជាចារ្យទទួលខុសត្រូវនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី លោកបូជាចារ្យអ៊ីន ហ្គុនជាបូជាចារ្យអ្នកទទួលមើលថែសហគមន៍គ្រីស្តបរិស័ទកាតូលិកជនជាតិកូរ៉េរួមជាមួយបងប្អូនគ្រីស្តបរិស័ទជនជាតិកូរ៉េយ៉ាងច្រើនកុះករ។

លោកអូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានមានប្រសាសន៍ថា នៅថ្ងៃនេះយើងឆ្លៀតឱកាសសូមព្រះជាម្ចាស់ប្រទានពរសម្រាប់ការសាងសង់អគារថ្មីដោយជោគជ័យ។ លោកបន្តថា ទីតាំងដីនេះស្ថិតនៅក្នុងភ្នំពេញថ្មី ខាងក្រោយព្រះវិហារសន្តសិលា និងសន្តប៉ូល គឺយើងបានរៀបចំគម្រោងជាច្រើន។ ជាក់ស្តែងអ្វីដែលយើងបានរៀបចំហើយគឺរៀបចំជាមជ្ឈមណ្ឌលសម្រាប់ការអប់រំនិងសំណាក់ធម៌ជួបជុំគ្នាប្រជុំព្រមទាំងបំរើឲ្យការរៀបចំ សម្រាប់ការធ្វើសកម្មភាពផ្សេងៗទៀត។

លោកអភិបាលបានបញ្ជាក់ថា ក្រោយពីបញ្ចប់ការសាងសង់អគារនេះព្រះសហគមន៍ និងសហគមន៍គ្រីស្តបរិស័ទជនជាតិកូរ៉េអាចប្រើប្រាស់អគារនេះរួមគ្នាដោយទីតាំងមួយផ្នែកនៃអគារនេះប្រើសម្រាប់បងប្អូនគ្រីស្តបរិស័ទកូរ៉េ គឺសម្រាប់ការអធិដ្ឋាន និងអាហារដ្ឋាន និងមួយផ្នែកទៀតសម្រាប់ប្រើប្រាស់ធ្វើជាការិយាល័យ នៃភូមិភាគភ្នំពេញ គឺការិយាល័យការអប់រំសិក្សា ការិយាល័យសុខភាពនិងការិយាល័យយុវជន។ក្នុងនោះក៏មានក្លីនីកព្យាបាលជំងឺត្រចៀកផងដែរ។

តំណាងសហគមន៍បងប្អូនគ្រីស្តបរិស័ទកាតូលិកជនជាតិកូរ៉េលោកបូជាចារ្យអ៊ីន ហ្គុនបានមានប្រសាសន៍ថា ចាប់តាំពីឆ្នាំ២០០៨មកក្រុមគ្រីស្តបរិស័ទជនជាតិកូរ៉េដែលបានធ្វើការ និងស្នាក់នៅក្នុងប្រទេសកម្ពុជាគឺក្រៅពីការជួបជុំគ្នាថ្វាយអភិបូជា និងលើកតម្កើងព្រះជាម្ចាស់ក្រុមគ្រីស្ត-បរិស័ទកូរ៉េបានរួបរួមគ្នាក្នុងការធ្វើសកម្មភាពផ្សេងៗទាក់ទងទៅនិងកិច្ចការមនុស្សធម៌និងការសម្តែងមេត្តាករុណា។

លោកបានបន្តថាក្នុងនាមសហគមន៍គ្រីស្តបរិស័ទជនជាតិកូរ៉េសូមថ្លែងអំណរគុណចំពោះលោកអភិបាលអូលីវីយេដែលជួយគាំទ្រទាំងស្មារតីនិងការគាំទ្រទៅលើការងារសាងសង់អគារនេះ។ សម្រាប់កិច្ចការទាំងអស់នេះសហគមន៍ជនជាតិកូរ៉េនៅកម្ពុជាបានទទួលនូវការគាំទ្រជាច្រើនពីសំណាក់លោកអភិបាលអូលីវីយេរៀងរហូតមក ជាក់ស្តែងលោកអភិបាលបានអនុញ្ញាត្ត និងយល់ព្រមប្រគល់ដីមួយចំណែកនៅក្នុងមណ្ឌលសកម្មភាពនៃភូមិភាគភ្នំពេញសម្រាប់ឲ្យសហគមន៍ជនជាតិកូរ៉េសាងសង់អគារក្នុងការជួបជុំគ្នា ធ្វើសកម្មភាពផ្សេងៗ។

លោកបូជាចារ្យអ៊ីន ហ្គុនបានបញ្ជាក់ថា អគារថ្មីនេះគ្រោងសាងសង់ឲ្យបញ្ចប់រួចរាល់នៅក្នុងរយៈពេល១០ខែខាងមុខពោលគឺបញ្ចប់រួចរាល់នៅមុនពិធីបុណ្យព្រះយេស៊ូប្រសូត្រចុងឆ្នាំនេះ។ ចំណែកថវិកាចំណាយសម្រាប់ការសាងសង់អគារនេះគឺបានមកពីការចូលរួមនិងឧបត្ថម្ភពីក្រុមគ្រីស្តបរិស័ទកាតូលិកកូរ៉េនៅក្នុងប្រទេសកម្ពុជានិងការឧបត្ថម្ភពីគ្រីស្តបរិស័ទនៅប្រទេសកូរ៉េ។

សូមបញ្ជាក់ថាទៅថ្ងៃអនាគតសម្រាប់ទីតាំងដីនៅមណ្ឌលសកម្មភាពភ្នំពេញថ្មីនេះគ្រោងនឹងមានការសាងសង់អគារនានាសម្រាប់គម្រោងជាច្រើនមានដូចជា សង់អាសនៈព្រះវិហារ មួយអាគារសិក្សាថ្នាក់ឧត្តមសិក្សា មន្ទីរពេទ្យរបស់ព្រះសហគមន៍កាតូលិក និងគម្រោងសកម្មភាពផ្សេងៗទៀតដែលបម្រើឲ្យការងារអប់រំសុខភាពនិងកិច្ចការមនុស្សធម៌ផ្សេងៗសម្រាប់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងមូល៕

ដោយ ឡុង សម្ភស្ស



ថតដោយ សុធីរ័ទ្ធ

# ក្រសួងកសិកម្ម៖ ការងារបង្កបង្កើនផលឆ្នាំនេះធ្លាក់ចុះ តែទិន្នផលនៅគ្រប់គ្រាន់

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា កាលពីឆ្នាំ២០១៦ កន្លងទៅនេះ ការងារបង្កបង្កើនផលរបស់កសិករកម្ពុជា ជាពិសេសគឺស្រូវ និងដំណាំរួមផ្សំ គឺមានការធ្លាក់ចុះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយទិន្នផលគឺ អាចទ្រទ្រង់ការហូបចុករបស់ប្រជាពលរដ្ឋ និងការនាំចេញបាន។

យោងទៅតាមរបាយការណ៍របស់ក្រសួងដែលបានធ្លាក់នៅក្នុងដៃអ្នកសារព័ត៌មានបានឲ្យដឹងថា សម្រាប់ការបង្កបង្កើនផលស្រូវរដូវវស្សាកាលពីឆ្នាំ២០១៦ គឺសម្រេចបានចំនួនជាង ៣លានហិចតា តិចជាងឆ្នាំមុន ប្រមាណជា ៥៥៣.០០០ ហិចតា ប៉ុន្តែទិន្នផលវិញគឺ ប្រសើរដោយដីមួយហិចតា អាចផ្តល់ផលជាមធ្យម គឺ ២,៩តោន ខ្ពស់ជាងឆ្នាំទៅ ចំនួន ២២១ គីឡូក្រាម។

ប្រភពដដែលបានបន្តទៀតថា សម្រាប់ដំណាំស្រូវប្រាំងវិញ គឺមានសម្រេចប្រមាណជា ៣៦៩.០០០ហិចតាប៉ុណ្ណោះនៅក្នុងរដូវប្រមូលផលពីឆ្នាំ២០១៦-២០១៧ នេះ ដោយតិចជាងរដូវប្រមូលផល ឆ្នាំ ២០១៥-២០១៦ ១០៩.០០០ ហិចតា ដោយសារតែបញ្ហាទឹកវាស្រកយឺត។

ដោយឡែកជុំវិញការងារបង្កបង្កើតផលដំណាំរួមផ្សំ ដែលមានបន្លែបង្គា និងដំណាំកសិឧស្សាហកម្មមួយចំនួន ក្រៅពីកៅស៊ូ គឺកសិករបានអនុវត្តសម្រេចចំនួន ៤៥.០០០ ហិចតា តិចជាងឆ្នាំមុនចំនួនប្រមាណជា ៤.០០០ហិចតា។

ជុំវិញដំណាំឧស្សាហកម្មមួយទៀតដែលជាមាសសមួយរបស់កសិកម្មកម្ពុជា គឺកៅស៊ូ របាយការណ៍ដដែលបានឲ្យដឹងថា កំពុងតែលាតសន្ធឹងនៅលើផ្ទៃដីសរុបប្រមាណជា ៤៣១.០៥៣ ហិចតា នៅក្នុងនោះផ្ទៃដីដែលអាចប្រមូលផលបានមានតែ ១២៦.៩៩៦ហិចតា ដោយប្រមូលផលសរុប បានចំនួនប្រមាណជា ១២៧.៨៥២ តោន។ ប្រភពដដែលបានបន្តថា តម្លៃកៅស៊ូឆ្នាំនេះ នៅពេលដើមឆ្នាំបានធ្លាក់ចុះដល់មួយតោន ១.០៤២ ដុល្លារ ប៉ុន្តែនៅចុងឆ្នាំ ឃើញឡើងវិញដល់ ១.៧០៣ ដុល្លារ។

ជុំវិញការងារបង្កបង្កើនផលនេះ លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានប្រាប់អ្នកសារព័ត៌មាននៅក្នុងស្រុក កាលពីពេលថ្មីៗនេះថា ទិន្នផលសរុបនៃការបង្កបង្កើនផលរបស់កសិកម្មកម្ពុជា គឺអាចទ្រទ្រង់ការហូបចុក និងការនាំចេញបានជាពិសេស គឺដំណាំស្រូវ។

> **“មិនដែលល្បីថា កសិករនោះវាសប្បាយទេ បើមិនជួបគ្រោះធម្មជាតិ ជួបរឿងសត្វចង្រៃ ហើយបើគេចរួចមកជួបអារឿងផលវាថោក”**

លោកបានបញ្ជាក់ថា ទិន្នផលប្រមូលផលស្រូវរដូវវស្សាគឺមានប្រមាណជា ១០ លានតោន ហើយស្រូវប្រាំងកំពុងតែបន្តធ្វើបន្តទៀត ដែលគ្រប់គ្រាន់សម្រាប់ការហូបចុករបស់ប្រជាពលរដ្ឋ និងការនាំចេញ ដោយតម្លៃស្រូវ គឺនៅក្នុងចន្លោះ ៨៥០រៀល ដល់៩០០រៀលនៅក្នុងមួយគីឡូក្រាម។

នេះគឺជាទិន្នផលសរុប ដែលលោករដ្ឋមន្ត្រី និងរបាយការណ៍របស់ក្រសួងបានប្រកាស ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយកសិករកម្ពុជាមួយចំនួនបានត្អូញត្អែររឿងជីវភាព។

លោក រិន ហេង អ្នករត់ម៉ូតូឌុប នៅរាជធានីភ្នំពេញបានថ្លែងថា តាំងតែពីដើមមក មិនដែលល្បីថា កសិករនៅស្រុកខ្មែរយើងនេះមានទេ គឺមួយឆ្នាំទៅមួយឆ្នាំមានតែត្រដាបត្រដួស ដូច្នេះហើយបានជាឃើញមុខលោកមករត់ម៉ូតូឌុបនៅទីក្រុងបែបនេះ។

លោកបានបញ្ជាក់ថា "សប្បាយនោះវានិយាយមិនចេញ បើដីវាតិច ហើយចង់ហ៊ុលអស់ទៀត តែដល់ពេលខំធ្វើបានផលលក់ចេញវិញថោក។ មានតែមករត់ ឌុប (ម៉ូតូឌុប) ជួយទប់ជីវភាពតែប៉ុណ្ណោះ"។

លោក រិន ហេង ក៏ជាកសិករមួយរូបនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលបានអះអាងថា ឆ្នាំនេះលោក និងគ្រួសារប្រមូលផលបាន ៣ទៅ ៤ តោនដែរ ដោយទុកពាក់កណ្តាល ហូបពាក់កណ្តាលគ្រាន់នឹងលក់ទប់ទល់ដោះស្រាយជីវភាព សងគេខ្លះ តែបានស្មីបើស្រូវគេឲ្យត្រឹម៧០០ ទៅ៨០០រៀល (ស្រូវធម្មតាមិនមែនប្រភេទស្រូវក្រអូប)។

លោកបានបញ្ជាក់ថា "សប្បាយម៉េចកើត បើវាតែអីចឹងរាល់តែឆ្នាំ។ រាល់ថ្ងៃនេះបើកុំបានរត់ឌុបខ្លះ កូនមកធ្វើការរោងចក្រខ្លះ ប្រហែលជាដាច់បាយ បើឲ្យនៅតែស្រែនោះ"។

លោក ចិត សម្បត្តិ ដែលអះអាងថាជាកសិករមកពីពោធិសាត់ បានរៀបរាប់នៅក្នុងខណៈពេល ដែលកំពុងតែដើររកទិញគ្រឿងបន្លាស់គោយន្តរបស់គាត់នោះបាននិយាយថា តាំងតែពីដើមមកមិនដែលល្បីថា កសិករនោះវាសប្បាយទេ បើមិនជួបគ្រោះធម្មជាតិ ជួបរឿងសត្វចង្រៃ ហើយបើគេចរួចមកជួបអារឿងផលវាថោក។

លោកបានបន្តថា លោកមានដីស្រែនោះបួនទៅដប់ហិចតាដែរ ដោយប្រមូលស្រូវនោះបាន មួយហិចតាខ្លះ៤តោន ខ្លះ៥តោន តែមកដល់ពេលនេះកំពុងតែជួបរឿងគេបង្អាប់ថ្លៃ។

លោកបានបន្តថា ឆ្នាំនេះផលវាបានគួរសមដែរ តែវាយ៉ាប់ត្រង់គុណភាពស្រូវ ដោយសារតែ វាភ្លៀងចុងដៃ ធ្វើឲ្យស្រូវប្រមូលផលមិនទាន់ គ្មានកន្លែងហាលដល់អីចឹងរោងម៉ាស៊ីនគេបង្អាប់តម្លៃតែម្តង។

លោកបានបញ្ជាក់ថា "វាបាន តែសប្បាយមិនចេញទេ បើវាអីចឹងរាល់តែឆ្នាំឥឡូវនេះមិនទាន់សងថ្លៃប្រេង ថ្លៃដីគេអស់ផងខ្ញុំ ហើយអាគោយន្តនោះវាខូចទៀត"។

លោក សម្បត្តិ បានបន្តថា "ណើ្ហយជីវិតកសិករវាតែប៉ុណ្ណឹង វាមិនខុសពីចម្រៀងគេច្រៀងឲ្យស្តាប់ទេ។ កសិករបើវាមិនក្រ គេមែនហៅថាកសិករទេ គេហៅថា ដង្ហៅ ឬថៅកែបាត់ទៅហើយ"។

លោកបានបន្តទៀតថា ដោយសារតែវាអីចឹងហើយបានជាសព្វថ្ងៃនេះខិតខំធ្វើយ៉ាងណា បណ្តុះបណ្តាលកូនៗឲ្យគេរៀនគេសូត្រ ចេះឲ្យគ្រប់គ្នា ក្រែងលោបានការងារល្អៗ ហើយកុំមកធ្វើស្រែដូច ឪពុកម្តាយ នាំតែយ៉ាប់ចិត្តយ៉ាប់កម្លាំងនោះទេ។

ជុំវិញរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្មនេះចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះបំផុត នៅក្នុងចំណុចទីមួយដែលនិយាយអំពីសភាពការណ៍រួមដោយក្រសួងបានបញ្ជាក់ថា ការប្រើប្រាស់គ្រឿងយន្ត សម្រាប់ផលិតកម្មកសិកម្មកំពុងតែមាននិន្នាការកើនឡើង។

ប្រភពដដែលបានបញ្ជាក់ថា ការប្រើប្រាស់គ្រឿងយន្តកសិកម្មនៅក្នុងការងារបង្កបង្កើនផលកាលពីឆ្នាំចាស់ គឺប្រើប្រាស់គ្រឿងយន្តកសិកម្មមានរហូតដល់ទៅ ៩១,១៧ ភាគរយ ខណៈដែលការប្រើប្រាស់សត្វពាហនៈគឺមានចំនួនត្រឹមតែ ៨,៨៣ ភាគរយ ប៉ុណ្ណោះ។

*ដោយ អរិយបុត្រ*



*ថតដោយ រិទ្ធី*

# តើយុវជនគួរប្រាប់រឿងអតីតកាលខ្លួនអោយដៃគូដឹងឬទេមុនពេលរៀបការ ?



ថតដោយ សម្បត្តិ

មានមនុស្សប៉ុន្មាននាក់ដែលអាចរក្សាស្នេហាដំបូងរហូតដល់ថ្ងៃចុងក្រោយនោះ? ប្រហែលជាមានតិចតួចបំផុតព្រោះភាគច្រើនសុទ្ធតែធ្លាប់មានប្រវត្តិជួរចត់ជួបស្នេហាឈឺចាប់ខ្លោចផ្សាទម្រាំរកបានគូអនាគតម្នាក់មករួមផ្លូវជីវិតបាន។

យ៉ាងណាមនុស្សម្នាក់ៗតែងតែមានគំនិតនិងការគិតខុសៗគ្នា ដោយអ្នកខ្លះគិតថា ការដែលនិយាយពីរឿងអតីតកាលរបស់ខ្លួនប្រាប់ទៅមនុស្សដែលខ្លួនស្រលាញ់ ឬដៃគូ អាចនឹងធ្វើឲ្យដៃគូ ទទួលយកមិនបាន ឬក៏អាចបាត់បង់គេ ខណៈដែលអ្នកខ្លះយល់ថា នេះជារឿងមួយដែលល្អ ដើម្បីបញ្ជាក់ចិត្តស្មោះគួររៀបរាប់អតីតកាលនៃស្នេហាដែលធ្លាប់ជួបទាំងនោះប្រាប់គេ។ ដូចនេះតើគួរឬមិនគួរ?

អ្នកនាង នឹម កុម្ភៈ ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយ បាននិយាយថា យើងគួរតែប្រាប់រឿងគ្រប់យ៉ាងឲ្យដៃគូរបស់ខ្លួនដឹង ជៀសវាងគេដឹងរឿងដោយខ្លួនឯងនិងមានបញ្ហានៅថ្ងៃក្រោយ។

អ្នកនាងបញ្ជាក់ថា "ប្រសិនបើជាគេស្រឡាញ់យើងពិតមែន ទោះយើងមិនល្អយ៉ាងណាក៏គេអាចទទួលយកយើងបានគ្រប់យ៉ាងដែរ ណាមួយវាគ្រាន់តែរឿងអតីតកាល ប្រសិនជាគេមិនអាចទទួលយកបានទេយើងក៏គួរតែឲ្យគេទៅ ប៉ុន្តែទោះបីជាយើងឲ្យគេទៅ ក៏យើងនៅតែផ្តល់ឱកាសសម្រាប់គេក្នុងការត្រឡប់មកវិញនៅពេលណាគេគិតថា មិនអាចរស់នៅដោយគ្មានយើង"។

ងាកមក ជា សុវត្ថា ជាអតីតនិស្សិតនៅសាកលវិទ្យាល័យបញ្ញាជាតិបានអះអាងថា មិនមែនចេះតែប្រាប់ទេ តែក៏មិនលាក់ដែរ។ ប្រសិនបើសង្សារ ចង់សួរគាស់កកាយ ចាំរៀបរាប់ប្រាប់គេ ហើយក៏ត្រូវតែគិតដែរថា វាមានផលប៉ះពាល់ ឬអត់។ សុវត្ថា បាននិយាយបន្តថា ជួនកាលការលើករឿងមិនល្អច្រើន អាចធ្វើឲ្យគេពិចារណា និងគិតថា ខ្លួនជាមនុស្សមិនអាចផ្ញើវាសនាបាន។

សុវត្ថាបានបញ្ជាក់ថា "មិនមែនសុខៗទៅប្រាប់គេទេ ប្រាប់ធ្វើអីបើអត់មានរឿងផង...តែបើសួរហើយ ត្រូវប្រាប់កុំឲ្យគេថា យើងព្យាយាមលាក់។ អ្នកខ្លះធ្លាប់ឆ្លងកាត់ស្នេហាច្រើន... តែបើប្រាប់គេច្រើនពេកវាមិនល្អទេ។ បើខ្ញុំវិញធ្លាប់បែកអស់ ២ នាក់ហើយ មុនជួបអ្នករាល់ថ្ងៃនេះ តែខ្ញុំមិនខ្លាចប្រាប់ទេ ព្រោះខ្ញុំមិនមែនជាអ្នកខុសផង"។

ចំណែកឯកញ្ញា ព្រុំ ចិន្តា ជាបុគ្គលិកការិយាល័យរោងចក្រមួយរូបបានរៀបរាប់ឲ្យដឹងថា សម្រាប់កញ្ញាផ្ទាល់គិតថារឿងអ្វីៗទាំងអស់នៅលើលោកនេះ គឺគ្មានទេអាថ៌កំបាំង យូរនិងឆាប់គេគង់តែនឹងដឹង។ ដូច្នេះជៀសវាងគេដឹងរឿងដោយខ្លួនឯង យើងគួរប្រាប់រឿងអតីតកាលរបស់យើងឲ្យគេដឹង មិនថារឿងល្អ ឬមិនល្អនោះទេដើម្បីអាចងាយស្រួលដោះស្រាយជាមួយគ្នាថា តើហេតុអ្វីបានជាអតីតកាលនោះកើតឡើងចំពោះយើង។ កញ្ញាបន្ថែមថា បើសិនគេស្រលាញ់យើងពិតមែនគេនឹងយល់ពីអតីតកាលរបស់យើង ម្យ៉ាងទៀតប្រសិនបើយើងប្រាប់គេនោះគេនឹងគិតថាយើងមានភាពស្មោះត្រង់សម្រាប់គេ។

ចំណែកនិស្សិតឆ្នាំទី៣ ម្នាក់មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលសុំប្រើត្រឹមឈ្មោះកាត់ 'រ៉ាឌី បាននិយាយថា ទោះស្រលាញ់ស្មោះយ៉ាងណាក៏ដោយក៏មិនគួរប្រាប់អតីតកាលមិនល្អដល់គេដែរ។ 'រ៉ាឌី បានបញ្ជាក់ថា ធ្វើដូចនេះគឺមានតែប៉ះពាល់ដល់ទំនាក់ទំនងប៉ុណ្ណោះ ហើយការបញ្ជាក់ចិត្តស្មោះក៏មិនមែនមានន័យថាត្រូវប្រាប់អស់ពីពោះដែរ។

កញ្ញាបានបញ្ជាក់ថា "ខ្ញុំមិនប្រាប់គេទេរឿងមិនល្អដូចជាធ្លាប់មានសង្សារច្រើនអីហ្នឹង គឺដាច់ខាតតែម្តង...បងដឹងស្រាប់ហើយ បើដឹងរឿងមិនល្អគឺពិបាកចិត្តខ្លាំង ប្រាប់ហើយគ្មានប្រយោជន៍ទេ នាំតែបញ្ហា។ និយាយប្រាប់គេតែរឿងណាដែលគិតថា មិនប៉ះពាល់ដល់ទំនាក់ទំនងនិងធ្វើឲ្យអារម្មណ៍គេល្អ"។

លោកហុក សត្យា ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយរូប បាននិយាយថា នឹងរៀបរាប់ប្រាប់សង្សារទាំងអស់ ចំពោះអតីតកាលរបស់ខ្លួន បើទោះបីវាមិនសូវល្អក៏ដោយ។ សត្យា បានបញ្ជាក់ថា អតីតកាលគ្រាន់តែជាអតីតកាល តែចង់ប្រាប់គេឲ្យជឿជាក់លើខ្លួន ហើយក៏មិនចង់លាក់ប្រវត្តិដែរ។ លោកបានបន្តទៀតថា "ខ្ញុំមិនលាក់ទេ ប្រាប់គេទាំងអស់ព្រោះមនុស្សទាំងអស់សុទ្ធតែធ្លាប់ឆ្លងកាត់ស្នេហាច្រើនជួនកាលសុខៗគេដឹងដោយខ្លួនឯងនាំតែខឹងយើង ថាមិនប្រាប់ក៏ថាបាន"។

ក្រៅពីយុវជន និងយុវនារី នាសម័យបច្ចុប្បន្នបញ្ចេញយោបល់ជុំវិញរឿងខាងលើនេះ ក៏មានយុវជននិងយុវនារី សម័យមុនមួយចំនួន បានគាំទ្រយោបល់របស់ពួកគេទាំងអស់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អស់លោកក៏បានផ្តាំផ្ញើ និងសង្កត់យុវជន និងយុវនារីសម័យបច្ចុប្បន្ននេះខ្លាំងរឿងទំនាក់ទំនងលើសពីចិត្តនិងចិត្ត។

ជុំវិញបញ្ហានេះលោកស្រី ជ័យ សកុណា អាយុ ៦៥ឆ្នាំ ជាស្ត្រីមេផ្ទះមួយរូបបានមានប្រសាសន៍ថា រឿងក្តីស្រលាញ់នេះវាគ្មានបែងចែកសម័យមុន សម័យនេះអ្វីនោះទេសំខាន់ឲ្យតែយល់ចិត្តគ្នាទៅបានហើយ។

លោកស្រី បានបញ្ជាក់ថា "រឿងស្នេហារឿងក្តីស្រលាញ់នរណាក៏មានដែរ ហើយអ៊ុំ ជឿថា សម័យអ៊ុំ និងក្មេងៗសម័យនេះក៏មិនខុសគ្នាដែរ ប៉ុន្តែសម័យមុន គ្រាន់តែចាស់ៗប្រកាន់បន្តិច ជាពិសេសបើដឹងថា ខាងស្រីមានទំនាក់ទំនងជំពាក់ជំពិននឹងប្រុសៗច្រើន គឺអត់តែម្តង"។

លោក ទុំ សម្បត្តិ ជាមន្ត្រីចូលនិវត្តន៍មួយរូបក៏បានបញ្ចេញយោបល់ផងដែរថា រឿងស្នេហា នេះគឺមិនខុសសម័យកាលទេ ប៉ុន្តែអ្វីដែលខុសគឺថា យុវជននិងយុវនារីសម័យនេះគេហ៊ាននិយាយចំហបន្តិចអំពីរឿងស្នេហានេះ។

លោក សម្បត្តិបានបញ្ជាក់ថា " ដោយសារតែរបត់សង្គមបែបនេះហើយ ទើបលោកមានជំនឿថា នៅក្នុងការសេពគប់គ្នា យុវជននិងយុវនារីសម័យឥឡូវហ៊ានបើកចំហទំនាក់ទំនងស្នេហារបស់ ពួកគេ បានទូលាយជាងសម័យខ្ញុំ"។

លោកបានបន្តទៀតថា "សម័យខ្ញុំ ទាំងប្រុសនិងស្រី លាក់ម៉ែឪឲ្យក្វៃន (ឲ្យជិត) សូម្បីតែស្រលាញ់កូនគេ តែក្មេងឥឡូវកូនខ្ញុំអីហ្នឹង ពួកវាដូចជាអត់អៀន វាឱបគ្នាជួនកាលទៅឱបរិតគ្នាអត់អៀន"។

លោក សម្បត្តិ បានសំដែងការគាំទ្រថា ឲ្យយុវជននិងយុវនារីបើកចំហ រឿងស្នេហាគ្រាន់តែផ្តាំថា យ៉ាងណាៗ សូមកុំទុំមុនស្រគៀល ជាពិសេសគឺ នារីៗ ពីព្រោះផ្នត់គំនិតសង្គមយើង នៅមិនទាន់បើកចំហចំណុចនេះដូចបរទេសនៅឡើយទេ។

*ដោយប៉ែន ស្រីមាស*

# ពិធីបុណ្យ ខួប ៤០០ឆ្នាំនៃព្រះអំណោយទានរបស់សន្តវ៉ាំងសង់ដឺប៉ូល



ថតដោយ លី សុវណ្ណា

សមាជិកនានានៃក្រុមសន្តវ៉ាំងសង់ដឺប៉ូល ជាង១២០នាក់បានមកជួបជុំគ្នាអរព្រះគុណព្រះជាម្ចាស់ ក្នុងឱកាសខួប ៤០០ឆ្នាំ នៃអំណោយទានរបស់សន្តវ៉ាំងសង់ដឺប៉ូល។

ពិធីអរព្រះគុណនេះបានប្រារព្ធនៅព្រះវិហារសន្ត សិលា និងសន្តប៉ូល ក្រោមអធិបតីរបស់លោកអភិបាលអូលីវីយេ កាលពីថ្ងៃទី១៩ កុម្ភៈកន្លងទៅ។

សមាជិកនៃក្រុមសន្តវ៉ាំងសង់ដឺប៉ូល ដែលចូលរួមមាន សមាជិកក្រុមគ្រួសារសន្តវ៉ាំងសង់ដឺប៉ូល នៅប្រទេសកម្ពុជា សមាគមអន្តរជាតិនៃមេត្តាករុណា ក្រុមគ្រួសារបុត្រីមេត្តាករុណា និងសមាគមសន្តវ៉ាំងសង់ដឺប៉ូល។

ការជួបជុំគ្នាគឺមានពីរផ្នែក ដំបូងគឺពិធីអរព្រះគុណព្រះជាម្ចាស់ និងផ្នែកបន្ទាប់គឺជាការជួបប្រជុំ ដោយមានការណែនាំដោយលោកអភិបាលអូលីវីយេ។

នៅក្នុងពិធីអរគុណព្រះជាម្ចាស់លោកអភិបាលអូលីវីយេដែលជាអធិបតីបានមានប្រសាសន៍ក្នុងធម្មទេសនាថា ដោយសារសន្តវ៉ាំងសង់ដឺប៉ូល គឺធម៌មេត្តាករុណារបស់ព្រះជាម្ចាស់បានទៅដល់គ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល។ លោកថា ក្នុងជីវិតរបស់សន្តវ៉ាំងសង់ គឺគាត់ទទួលបានការត្រាស់ហៅពិសេស។

លោកអភិបាលបាននាំឲ្យអង្គប្រជុំរិះគិតថា តើធ្វើដូចម្ដេច ដើម្បីធ្វើឲ្យសេចក្ដីស្រឡាញ់ ដែលយើងមានចំពោះព្រះជាម្ចាស់ ចានហៀរចូលទៅដល់បងប្អូនឯទៀតៗ។ ជាទូទៅយើងពូកែនិយាយ ពូកែរិះគិត សំបូរគំនិត អំពីសេចក្ដីស្រឡាញ់ ប៉ុន្តែធ្វើដូចម្ដេចដើម្បីអនុវត្ត ហើយអនុវត្តពិតមែន។

លោកអភិបាលក៏មានប្រសាសន៍ ខួប ៤០០ឆ្នាំ នៃព្រះអំណោយទានរបស់សន្តវ៉ាំងសង់ គឺសន្តវ៉ាំងសង់ ទទួលបទពិសោធន៍ពិសេសចំនួន ដែលទទួលបានពីបទពិសោធន៍របស់ក្រីក្រ និងអ្នកជំងឺ នាំឲ្យលោករិះថា តើធ្វើដូចម្ដេចដើម្បី សង្គ្រោះវិញ្ញាណរបស់មនុស្ស នាំគេឲ្យចេញពីទុក្ខលំបាក ចេញពីអំពើបាប និងណែនាំឲ្យបានឃើញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងទទួលជីវិតថ្មី។ ចំពោះអ្នកជំងឺធ្វើយ៉ាងណាដើម្បីអាចជួយគេរយៈពេលយូរបាន។ គឺក្នុងឆ្នាំ១៦១៧ លោកបានបង្កើត សមាគមនៃមេត្តាករុណា ដោយចាប់ផ្ដើមជាមួយក្រុមស្ត្រី ដើម្បីបន្តជួយអ្នកក្រីក្ររហូត... អាចនិយាយបានថា ជាក្រុមសង្គហៈ។

លោកអូលីវីយេបានបន្តរៀបរាប់អំពីសកម្មភាពរបស់សន្តវ៉ាំងសង់ថា សន្តវ៉ាំងសង់ក៏បានជួយឲ្យបូជាចារ្យភ្ញាក់ស្មារតីអំពីការណែនាំផ្លូវវិញ្ញាណដល់អ្នកក្រីក្រ ដើម្បីឲ្យគេទទួលជីវិតថ្មី និងធ្វើយ៉ាងណាដើម្បីឲ្យមេត្តាករុណារបស់ព្រះជាម្ចាស់ទៅគ្រប់ទីកន្លែងដែលនាំឲ្យអ្នកក្រីក្រមានសេចក្ដីសង្ឃឹម។ ជាហេតុក្នុងឆ្នាំ១៦២៥ លោកបានបង្កើតសមាគមបូជាចារ្យ ដែលមានគំនិតតែមួយ គឺដើរតាមព្រះយេស៊ូគ្រីស្តប្រកាសដំណឹងល្អ ដល់ជនក្រីក្រ។ ក្រោមកក៏បង្កើតក្រុមបុត្រីមេត្តាករុណា ក្នុងឆ្នាំ១៦៣៣ ។ តាមស្មារតីរបស់សន្តវ៉ាំងសង់ដឺប៉ូល ក្នុងឆ្នាំ១៨៣០ បង្កើតសមាគមសន្តវ៉ាំងសង់ដឺប៉ូល។

អ្វីជាពិសេសនោះ គឺមុនទទួលមរណភាព គេសួរសន្តវ៉ាំងសង់ថា "តើអ្វីដែលលោកស្ដាយក្នុងជីវិតរបស់លោក? សន្តវ៉ាំងសង់ឆ្លើយថា រឿងតែមួយគត់គឺ មិនបានស្រឡាញ់បងប្អូនឯទៀតល្មមទេ។"

ជាចុងក្រោយលោកអភិបាលក៏បានរំឭកដល់គ្រីស្តបរិស័ទឲ្យខិតខំធ្វើយ៉ាងណា ដើម្បីឲ្យធម៌មេត្តារបស់ព្រះជាម្ចាស់បានជ្រាបចូលក្នុងខ្លួនយើង ដូចផ្កានាព្រឹកព្រលឹមដែលបានស្រូបយកទឹកសន្សើម។ ហើយបញ្ចេញចេញសេចក្ដីស្រឡាញ់ឲ្យហូរចេញទៅដល់បងប្អូនឯទៀតៗ ដែលនាំឲ្យសង្គមរបស់យើងបានពោរពេញដោយស្រឡាញ់ និងធម៌មេត្តាករុណា។

លោកធឹម ធន់ ប្រធានសមាគមសន្តវ៉ាំងសង់ដឺប៉ូលប្រចាំកម្ពុជារៀបរាប់ថា ពិតជាពិធីដ៏ប្រសើរដែលយើងត្រូវអរព្រះគុណព្រះជាម្ចាស់ ហើយខិតខំបន្តបេសកកម្មតាមស្មារតីរបស់សន្តវ៉ាំងសង់ដឺប៉ូល ដោយបម្រើអ្នកក្រីក្រ និងអ្នកតូចតាច។ លោកថាសព្វថ្ងៃសកម្មភាពសមាគមនេះមានការសួរសុខទុក្ខអ្នកក្រីក្រី ការសួរសុខទុក្ខអ្នកជំងឺ ជួយកុមារកំព្រា សកម្មភាពការពារបរិស្ថាន និងការសង់ផ្ទះសម្រាប់អ្នកគ្មានទីពឹងជាដើម។

លោកធន់បន្តថា សកម្មភាពទាំងអស់គឺជួយអ្នកដទៃ ប៉ុន្តែសមាជិកទាំងអស់ក៏ត្រូវរឹងមាំខ្លួនឯងខាងវិញ្ញាណដែរ។ យើងមានការជួបជុំអានព្រះគម្ពីរ រិះគិត និងចែករំលែកជំនឿជាមួយគ្នា លើកទឹកចិត្តគ្នា គាំទ្រ និងសហការគ្នាទៅវិញទៅមក។

តាមលោកធន់ រហូតដល់ពេលនេះ សមាគមសន្តវ៉ាំងសង់ដឺបូលនៅកម្ពុជា បានកើតក្នុងឆ្នាំ២០០៤ មានចំនួន ២៩ក្រុម មានសមាជិកចំនួន៤១៧នាក់ ក្នុងព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។

*ដោយ លី សុវណ្ណា*

# បេក្ខជនបេក្ខនារីចំនួន១៤នាក់ទទួលពិធីចូលព្រះសហគមន៍ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច

បងប្អូនដែលជាបេក្ខជនបេក្ខនារីកំពុងស្វែងយល់នូវជំនឿ អំពីព្រះសហគមន៍កាតូលិកចំនួន១៤នាក់ បានទទួលពិធីចូលព្រះសហគមន៍(ជំហានទី១) កាលពីថ្ងៃទី១៩ កុម្ភៈ ២០១៧នៅព្រះវិហារសន្តយ៉ូសែបផ្សារតូច។ តំណាងអ្នកណែនាំជំនឿ អ្នកស្រីចាន់ សេរី បានឲ្យដឹងថា ថ្ងៃនេះព្រះសហគមន៍យើងអំណរសប្បាយ ដោយមានបងប្អូនចំនួន១៤នាក់ បានសុំចូលព្រះសហគមន៍។ បងប្អូនទាំងនេះបានមកទទួលការស្វែងយល់នូវជំនឿអស់រយៈពេលជិត២ឆ្នាំ។ ដោយសារ ជំនឿរបស់ពួកគាត់ យើងខ្ញុំជាអ្នកណែនាំជំនឿ យល់ឃើញថា គ្រប់គ្រាន់ក្នុងការទទួលការអនុញ្ញាត្តិទទួលពិធីចូលព្រះសហគមន៍។ ដូច្នេះសូមលោកបូជាចារ្យ និងបងប្អូនគ្រីស្តបរិស័ទទាំងអស់មេត្តា ទទួលពួកគាត់ឲ្យចូលព្រះសហគមន៍ដោយក្ដីអនុគ្រោះផង។


ថតដោយ ឡុង សម្ផស្ស

ឆ្លើយតបតាមការស្នើរសុំពីក្រុមអ្នកណែនាំ លោកបូជាចារ្យ បានទទួលស្វាគមន៍បងប្អូនទាំង១៤នាក់ ឲ្យចូលព្រះសហគមន៍ដោយក្ដីសោមនស្សរីករាយក្រៃលែង។

លោកបូជាចារ្យរឿង ឆ័ត្រសិរី បានមានប្រសាសន៍ថា ព្រះជាម្ចាស់ពិតជា មានព្រះហឫទ័យប្រណីសន្ដោសចំពោះអ្នកដែលស្វែងរកព្រះអង្គ។ ព្រះអង្គតែងតែប្រទាននូវពន្លឺ របស់ព្រះអង្គដល់មនុស្សគ្រប់រូបដែលកើតមកក្នុងលោកនេះ ដែលព្រះអង្គក៏សម្ដែងនូវអាថ៌កំបាំង ដ៏អស្ចារ្យរបស់ព្រះអង្គដោយស្វាព្រះហស្ត ដើម្បីឲ្យមនុស្សអាចលើកតម្កើងព្រះអង្គ។

កញ្ញាសុខ ម៉ានយ៉ាន មានស្រុកកំណើតនៅឯខេត្តកំពង់ធំ បានសម្ដែងនូវទឹកចិត្តរំភើបរីករាយរបស់កញ្ញាថា មូលហេតុដែលនាំឲ្យកញ្ញាចូលរួមស្វែងយល់អំពីជំនឿពីព្រះសហគមន៍កាតូលិក មកពីកញ្ញាបានមើលឃើញ នូវគំរូរបស់បងប្អូនគ្រីស្តបរិស័ទដែលមានចិត្តមេត្តាករុណា និងមានសេចក្ដីស្រឡាញ់រវាងគ្នានិងគ្នា។

គួរបញ្ជាក់ថា បងប្អូនដែលបានទទួលពិធីចូលព្រះសហគមន៍ទាំង១៤នាក់ បានបង្ហាញនូវជំនឿរបស់ខ្លួន នៅចំពោះមុខព្រះសហគមន៍ ដោយរួមគ្នាគោរពឈើឆ្កាងព្រះគម្ពីរ និងព្រះសហគមន៍ បេក្ខជនប្រកាសថា សូមយកព្រះគ្រីស្តជាទីពឹងយកព្រះបន្ទូលជាទីពឹង និងសូមយកព្រះសហគមន៍ជាទីពឹង៕ *ដោយ ឡុង សម្ផស្ស*

# យុវជនជាសសរទ្រូងរបស់ប្រទេសជាតិ



ថតដោយ អរិយបុត្រ

យុវជនជាសសរទ្រូងរបស់ប្រទេសជាតិ ហើយយុវជនមួយចំនួនកំពុងតែចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពផ្សេងៗនៅក្នុងសង្គម ដូច្នេះដើម្បីឲ្យដឹងច្បាស់ថា យុវជនមានតួនាទី ហើយសំខាន់ប៉ុណ្ណា សម្រាប់សង្គម លេខនេះអ្នកនាំ-សារ សូមណែនាំមិត្តអ្នកអានឲ្យជួបជាមួយនឹងលោក **អ៊ឹម សុធី** ជានាយកប្រតិ-បត្តិនៃក្រុមប្រឹក្សាយុវជនកម្ពុជា។

អ្នកនាំសារ៖ **ថាតើលោកយល់ឃើញយ៉ាងម៉េចដែរអំពីស្ថានភាពយុវជនរបស់យើង? ថាតើវារីកចម្រើនទៅមុខឬដើរថយក្រោយ ឬមួយក៏វានឹងថ្កល់ ឬក៏យ៉ាងណា?**

លោក អ៊ឹម សុធី៖ តាមខ្ញុំអង្កេតបន្ទាប់ពីខ្ញុំធ្វើការងារជាមួយយុវជនមួយរយៈមកនេះខ្ញុំអង្កេតឃើញថា យុវជនមួយចំនួនគាត់មានសកម្មភាពខ្លាំងជាងមុន ទាំងចូលរួមជាមួយនឹងអង្គការសង្គមស៊ីវិល ទាំងសកម្មភាពផ្សេងៗរបស់រាជរដ្ឋាភិបាល និងគ្រប់វិស័យទាំងអស់។ កាលពីមុនយុវជនរបស់យើងមិនសូវជាចាប់អារម្មណ៍ជាមួយនឹងច្រៀងជាចម្រៀងដែលគេហៅថា ចម្រៀងដើមនិពន្ធដោយខ្លួនឯងទេ ប៉ុន្តែឥឡូវបែរជាឃើញយុវជនមួយចំនួនគាត់ចាប់ផ្តើមផុស។ គាត់ចេះនិពន្ធរឿងខ្លួនគាត់ហើយគាត់ច្រៀងខ្លួនគាត់ហើយធ្វើម៉េចដើម្បីពួកគាត់កាន់តែមានទស្សនិកជនគាំទ្រច្រើន។ រីឯការចូលរួម ផ្នែកបណ្តុះបណ្តាល វិជ្ជាជីវៈនោះក៏យើងឃើញតាមទិន្នន័យរបស់ក្រសួងក៏ មានអ្នកដាក់ពាក្យ ទៅរៀនច្រើនលើជំនាញផ្សេងៗ ដូចជាជំនាញជាងក្រឡឹងឬក៏ ជួសជុលម៉ូតូនិងរថយន្ត។ ហើយបើតាមមហាវិទ្យាល័យមួយចំនួនតាមយើងមើលថា យុវជនទាំងអស់ថាគាត់ចូលរួមច្រើនដែរទៅរៀនមហាវិទ្យាល័យទាំងឯកជនទាំងរដ្ឋ។

អ្នកនាំសារ ៖ **ចុះការចូលរួមនៅក្នុងសកម្មភាពនយោបាយយ៉ាងម៉េចដែរ?**

លោក អ៊ឹម សុធី៖ របាយការណ៍របស់អង្គការយូអេនឌីភី ជាដើមនោះយើងឃើញថាមានយុវជនប្រមាណជា ៣០%ដែរ ដែលគាត់ចូលរួមប្រឡូកនៅក្នុងវិស័យនយោបាយ។ គាត់អាចចូលរួមជាច្រើននៅក្នុងវិស័យនយោបាយមិនថាចូលរួមធ្វើកិច្ចការជាមួយឃុំ ចូលរួមធ្វើកិច្ចការងារជាមួយខាងគណបក្ស។ ដោយឡែកសម្រាប់គណបក្សនយោបាយដែលមានអសនៈនៅក្នុងសភាទាំង គណបក្សកាន់អំណាច និងគណបក្សប្រឆាំង គឺកំពុងតែ យកចិត្តទុកដាក់ចំពោះយុវជនមែនទែនទាំងការជំរុញឲ្យយុវជន គាត់បានចូលរួមផ្នែកនយោបាយ ប៉ុន្តែយើងអត់ដឹងថាពួកគាត់ដាក់យុវជនជាបេក្ខភាពក្នុងការបោះឆ្នោតគឺនៅក្នុងតារាងអាទិភាព។ ឧទាហរណ៍ដូចជាលេខ១លេខ២ ឬមួយយ៉ាងណាទេ យើងក៏អត់ទាន់ដឹងដែរ ។

អ្នកនាំសារ៖ **សម្រាប់ឆ្នាំ២០១៧ តើយុវជនអាច បញ្ហាប្រឈមនឹងបញ្ហាអ្វីខ្លះ?**

លោក អ៊ឹម សុធី៖ សម្រាប់ឆ្នាំ២០១៧ នេះបញ្ហាប្រឈមដែលខ្ញុំមើលឃើញ គឺថា សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពទូលំទូលាយ ប៉ុន្តែក៏នៅមានបញ្ហាមិនគោរពតម្លៃនៃសីលធម៌ ហើយក៏ប្រហែលជាអាចនឹងជួបបញ្ហា ដោយឡែកគឺច្បាប់ក៏បញ្ហាប្រឈមមួយដែរ។ ឧបមាថាគាត់ (យុវជន)ចង់ធ្វើសកម្មភាពមួយអប់រំប្រជាពលរដ្ឋ ជាមួយយុទ្ធនាការផ្សព្វផ្សាយឲ្យពលរដ្ឋ ឲ្យយកកូនទៅចុះឈ្មោះចូលរៀនពីអាយុ៦ឆ្នាំអីចឹង គឺគាត់មិនអាចធ្វើបានទេ គាត់ត្រូវតែសុំច្បាប់ពីអាជ្ញាធរ អីចឹងហើយនេះជាលក្ខណៈមួយដែលគាត់មិនអាចចូលរួមបានច្រើន។ ទាក់ទងជាមួយនឹងភាពអត់ការងារធ្វើរបស់ពួកគាត់ក៏ជាចំណុចមួយដែរ។ ខ្ញុំឃើញគាត់រៀនចប់ពីមហាវិទ្យាល័យ ហើយប៉ុនប៉ងក្លាយជាមន្ត្រីរាជការ ប៉ុន្តែភាគច្រើន ពេលប្រឡងចូលក្រសួងនីមួយៗ គឺកម្រជាប់។ លក្ខណៈមួយគាត់អស់អារម្មណ៍ អស់ទឹកចិត្តខ្លាំងដោយគាត់ដាក់ពាក្យប្រឡង៣ដងទៅ៤ដងដែរ តែនៅតែមិនជាប់។

អ្នកនាំសារ៖ **តើកំណើនសេដ្ឋកិច្ចមានផលប្រយោជន៍ដែរទេសម្រាប់យុវជន?**

លោក អ៊ឹម សុធី៖ យើងមានកំណើនសេដ្ឋកិច្ចកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំមែន តែបើយើងមើលទៅដល់ប្រជាពលរដ្ឋនៅតាមជនបទ គ្នាជួនកាលគាត់ចងការធនាគារដើម្បីឲ្យកូនមករៀននៅមហាវិទ្យា-ល័យ ទោះបីជាមើលរូបភាពឃើញថា ផ្ទះគាត់ធំស្កឹមស្កៃមែនតែអាខាងក្នុងអត់តែម្តង។ កំណើននៃសិស្សដែលរៀនបាក់ឌុបនោះយើងគិតថាមានរហូតដល់៥ម៉ឺន ៦ម៉ឺននាក់ ប៉ុន្តែអាហារូបករណ៍គឺមានប្រមាណជា១ម៉ឺននាក់។ ចុះអ្នកអ្នកដែលមិនជាប់បាក់ឌុប!

អ្នកនាំសារ៖ **ចុះទាក់ទងជាមួយការបញ្ចេញមតិ និងសិទ្ធិនយោបាយវិញថាតើវាជាបញ្ហាប្រឈម ឬទេព្រោះយើងឃើញថាក្នុងឆ្នាំ២០១៦កន្លងទៅ មានការចាប់ខ្លួនយុវជនដែលបានបញ្ចេញមតិបញ្ចេញយោបល់លើបណ្តាញសង្គម?**

លោក អ៊ឹម សុធី៖ បាទពិតជាមានជាក់ស្តែងនិស្សិតដែលនិយាយតាមហ្វេសបុករឿងបដិវត្តពណ៌។ ត្រង់ចំណុចនេះ យុវជនក៏ត្រូវតែចេះស្វែងយល់ពីច្បាប់ ហើយអាជ្ញា-ធរក៏គួរតែផ្សព្វផ្សាយអំពីច្បាប់នេះ ឲ្យបានទូលំទូលាយ ពីព្រោះជួនកាលយុវជនគាត់អត់ដឹងអំពីច្បាប់ទេ។ អាជ្ញាធរគួរតែបង្ហាញអំពីដែនកំណត់នៃច្បាប់។ នៅពេលនេះយុវជនខ្លះគាត់បានដឹង តែខ្លះគាត់អត់ដឹងទេដល់ពេលអីចឹងទៅវាអាចធ្វើឲ្យគាត់ទទួលផលប៉ះពាល់ពីការបញ្ចេញមតិ។

អ្នកនាំសារ៖ **ចុះបញ្ហាសីលធម៌របស់យុវជន វាយ៉ាងម៉េចទៅវិញ?**

លោក អ៊ឹម សុធី៖ យុវជនមួយចំនួនគាត់មានសីលធម៌ល្អ ហើយយុវជនមួយចំនួនគាត់អាចខ្វះសីលធម៌ល្អដែរ។ មួយទៀត បើសិនជាគាត់ បានសេពគ្រឿងស្រវឹង បញ្ហាសីលធម៌វារឹតតែជាបញ្ហា។

អ្នកនាំសារ៖ **នៅលើបណ្តាញសង្គមមានការកាត់តរូបព្រះមហាក្សត្រ និងថ្នាក់ដឹកនាំមួយចំនួន តើលោកមានការបញ្ចេញយោបល់យ៉ាងណា ?**

លោក អ៊ឹម សុធី៖ យើងឃើញថាយុវជនមួយភាគតូចទេ ដែលគាត់មានគំនិតអីចឹង។ សកម្មភាពគាត់ជួនកាលមានន័យថា មានអ្នកឲ្យយោបល់។ តែបើសិនជាតាមគំនិតគាត់ ខ្ញុំគិតថា ប្រហែលជាគាត់មិនទៅធ្វើទេ។

អ្នកនាំសារ៖ **ក្នុងនាមជានាយកប្រតិ-បត្តិនៃក្រុមប្រឹក្សាយុវជន តើលោកមានសារយ៉ាងណា សម្រាប់យុវជនប្រើប្រាស់បណ្តាញព័ត៌មានសង្គមឲ្យមានប្រយោជន៍?**

លោក អ៊ឹម សុធី៖ ខ្ញុំគិតថា សារដែលយើងគួរតែផ្សព្វផ្សាយវាអាចជា ព័ត៌មានផ្លូវការ ចេញពីរដ្ឋាភិបាល ចេញពីក្រសួង ឬចេញពីអង្គការសង្គមស៊ីវិល។ វាអាចជាសារលើកទឹកចិត្ត ចែករំលែកចំណេះដឹង។ ហើយក៏ត្រូវតែរិះគិតឲ្យបានគ្រប់ជ្រុងជ្រោយថា សារនោះ វាអាចប៉ះពាល់ដល់អារម្មណ៍អ្នកដទៃឬទេ។ កាត់តរូបភាពមេដឹកនាំកន្លងមក មិនមែនជារឿងល្អនោះឡើយ។

អ្នកនាំសារ៖ **ចុះទាក់ទងនឹងរឿងបោះឆ្នោត តើលោកមានសារនយោបាយ ឬមួយក៏ការផ្តាំផ្ញើរណាមួយដល់ យុវជនយើងទេ?**

លោក អ៊ឹម សុធី៖ យើងបានរៀបចំសារជាច្រើន គឺតាំងពីដំណាក់កាល ការចុះឈ្មោះ ការទៅបោះឆ្នោត ហើយកន្លងមកយើងក៏បានចូលរួមសកម្មដែរនៅក្នុងកិច្ចការនេះ ដោយរួមទាំងការជួយផ្សព្វផ្សាយនៅតាមផ្ទះនៅ៨ខេត្តក្រុងដែលយើងធ្វើសកម្មភាព។

*ដោយ អរិយបុត្រ*

# ជីវិតកម្មករដែលធ្វើការក្នុងការដ្ឋានសំណង់ បុរីក្នុងរាជធានីភ្នំពេញ

នៅក្នុងរាជធានីភ្នំពេញដែលជាបេះដូង និងជាមជ្ឈមណ្ឌលសេដ្ឋកិច្ចពាណិជ្ជកម្ម វប្បធម៌ ប្រវត្តិសាស្រ្ត និងនយោបាយនាពេលសព្វថ្ងៃនេះ យើងសង្កេតឃើញមានការដ្ឋានសំណង់ជាច្រើន រួមមានសំណង់បុរី សណ្ឋាគារ ការិយាល័យ ជាដើម ដែលគេដឹងថា សុទ្ធជាទីតាំងដែលកំពុងតែបានស្រូបទាញកម្លាំងពលកម្មពីជនបទ ប៉ុន្តែគេមិនដែលដឹងថា តើបណ្តាកម្មករទាំងនេះត្រូវប្រឈមនឹងបញ្ហា និងការព្រួយបារម្ភណ៍អ្វីខ្លះនោះទេ ?

នៅក្នុងការដ្ឋានសំណង់នីមួយៗវិញ យើងឃើញមានអ្នកធ្វើការជាកម្មករ មានមនុស្សគ្រប់វ័យ គ្រប់ភេទ ទាំងយុវជន និងមនុស្សវ័យចំណាស់ ដែលកំពុងធ្វើការទៅតាមជំនាញរៀងខ្លួន ខ្លះលាប ខ្លះបោកស៊ីម៉ង់ ខ្លះឈូស ខ្លះឆាប ខ្លះតខ្សែភ្លើង ខ្លះតទឹក ...។ល។

ចាកចេញពីស្រុកកំណើតនាខេត្តស្វាយរៀង គ្រួសារលោក ជា សុភ័ក្រ្ត ដែលជាកម្មករកំពុងធ្វើការក្នុង ការដ្ឋានសំណង់ បុរី ស៊ីធី ហូហ្វ ស្ថិតក្នុងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បាននិយាយប្រាប់ថា ការមកធ្វើការងារជាកម្មករ ក្នុងការដ្ឋានខាងលើនេះ គឺគាត់រួមនឹងគ្រួសារបានមកធ្វើការក្នុងបុរីទាំងអស់គ្នា។ នៅក្នុងគ្រួសារលោក មានប្តី ប្រពន្ធ និងកូនចំនួន៤នាក់ សុទ្ធតែធ្វើជាកម្មករសំណង់ទាំងអស់។

លោកសុភ័ក្រ្តបញ្ជាក់ប្រាប់ថា ចំពោះប្រាក់ឈ្នួលត្រូវបានគិតជាថ្ងៃ ដោយក្នុងមួយថ្ងៃគាត់ទទួលបាន ៣ម៉ឺនរៀល រីឯប្រពន្ធគាត់ បានចំនួន ២ម៉ឺនរៀលដែរ និងកូនប្រុសច្បងបានចំនួន ២ម៉ឺនរៀលបន្ថែម។

លោកសុភ័ក្រ្តបានបន្តថា សម្រាប់ការស្នាក់នៅរបស់គាត់ ស្នាក់នៅក្នុងការដ្ឋានសំណង់ខាងលើ ក៏ប៉ុន្តែត្រូវបានម្ចាស់គម្រោង បានផ្តល់នូវការស្នាក់នៅលើដីការដ្ឋាន មិនបានស្នាក់នៅក្នុងសំណង់កំពុងតែសាងសង់នោះទេ។ ដោយឡែកលោកសុភ័ក្រ្ត ត្រូវចំណាយ ថ្លៃអគ្គិសនី ការហូបចុក និងការសិក្សារបស់កូនតូច ៣នាក់ទៀតប៉ុណ្ណោះ។

សុភ័ក្រ បានបន្តថា សម្រាប់កូនតូចទាំងបីនាក់ត្រូវបាន អង្គការមួយជាអ្នកផ្តត់ផ្គង់លើការសិក្សានៅសាលារដ្ឋ និងនៅសាលាអង្គការនេះ។

រីឯលោក ហួន យិន ដែលជាកម្មករផ្នែកអគ្គិសនីក្នុងការដ្ឋានបុរីខាងលើ បានប្រាប់ផងដែរថា លោកមានស្រុកកំណើតនាខេត្តព្រៃវែង និងបានចាកចេញមករស់នៅ បំពេញការងារជាកម្មករអគ្គិសនី បានរយៈពេលជាង៥ឆ្នាំមកហើយ។ គ្រួសារលោក បំពេញការងារជាកម្មករចំនួន ២ នាក់ដែលមានលោកនិងកូនប្រុសច្បង។ ក្នុងមួយថ្ងៃលោក និងកូនអាចរកចំណូលបាន ប្រហែលជា៦ ទៅ៧ម៉ឺនរៀល។ តែលោកមិនបាន ស្នាក់នៅក្នុងសំណង់កំពុងសាងសង់នេះទេ។

ដោយឡែកគ្រួសារមួយដែល ប្រកបរបរជាកម្មករសំណង់ ស្ថិតក្នុងបុរី ប៉េងហួត ច្បារអំពៅវិញបានប្រាប់ថា គ្រួសារគាត់ធ្វើជាកម្មករ ក្នុងបុរីខាងលើទាំងអស់ ដែលមានរូបលោក ប្រពន្ធ និងកូនចំនួន ២នាក់ ដែលសុទ្ធសឹងជាកម្មករសំណង់ទាំងអស់។

លោក ហួរ គឹមសុខ បានលើកឡើងថា ចំណូលជាប្រចាំថ្ងៃបើរាប់បញ្ចូលទាំងអស់ គ្នាក្នុងគ្រួសារគាត់ បានប្រហែលជាជាង១០ម៉ឺនរៀល ដែលចំណាយទៅលើថ្លៃជួលបន្ទប់ស្នាក់នៅទឹកភ្លើង និងការប្រើប្រាស់ប្រចាំថ្ងៃមួយចំនួនទៀត នៅសល់ប្រហែលជាជាង៦ម៉ឺនរៀល ដែលមិនគិតពីថ្លៃព្យាបាលជំងឺពេលពួកគាត់ឈឺនោះទេ។

ជុំវិញស្ថានភាពកម្មករនេះតាមការរៀបរាប់ប្រាប់ពីតំណាង បុរី ស៊ីធី ហូស្វ បានឲ្យដឹងថា សម្រាប់កម្មករទាំងអស់ លើកលែងតែសន្តិសុខ វិស្វករ និងអ្នកបើកបររថយន្តដឹកសម្ភារសំណង់នោះគឺ ត្រូវបានបើកប្រាក់ប្រចាំថ្ងៃ និងត្រូវបានផ្តល់ទឹក និងដីសម្រាប់សង់ផ្ទះបណ្តោះអាសន្នសម្រាប់ស្នាក់នៅ តែមិនត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងការដ្ឋានសំណង់កំពុងតែសាងសង់នោះឡើយ ហើយចំណូលសម្រាប់ពួកគាត់គិតទៅតាមជំនាញរៀងខ្លួន ដែលចាប់ពី២ម៉ឺនរៀល ទៅដល់៦ម៉ឺនរៀលក្នុងមួយថ្ងៃ។

បន្ថែមពីលើនេះ ខាងតំណាងបុរីក៏បានបញ្ជាក់ថា ក៏មានកម្មករមួយចំនួនមិនបានស្នាក់នៅក្នុងការដ្ឋាន ឬផ្ទះបណ្តោះអាសន្ននេះទេ ដោយពួកគាត់សម្រេចធ្វើការជួលផ្ទះស្នាក់នៅដោយខ្លួនឯង។

លោកបានបន្តថា "បើតាមការសង្កេតមើលទៅ ដោយសារតែពួកគាត់ចង់រកចំណូលបន្ថែម ដោយអាចឲ្យប្រពន្ធកូនៗពួកគាត់អាចលក់ដូរបន្តិចបន្តួច សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ"។

នេះគឺជាការអះអាងរបស់កម្មករនិងតំណាងរបស់កម្មករដែលមានឱកាសធ្វើការនៅក្នុងការដ្ឋានធំៗ ដែលមានរយៈពេលយូរ ដោយពួកគេអាចមានប្រាក់ចំណូល កន្លែងស្នាក់នៅសមរម្យ ហើយតាមការរៀបរាប់ខាងលើ កូនៗរបស់ពួកគេក៏មានឱកាសទទួលបានការសិក្សាថែមទៀត ប៉ុន្តែសម្រាប់កម្មករ មួយចំនួន ដែលមានលក្ខណៈចល័ត ហើយអាចមានឱកាសទទួលការងារតាមគម្រោងតូចៗ ដែលមានរយៈពេលខ្លី ក្តីបារម្ភគឺមានចំពោះរូបគាត់និងគ្រួសារជាពិសេសគឺកុមារ។

លោកសាញ់ សែម ជាកម្មករនៅការដ្ឋានផ្ទះល្វែងមួយកន្លែង នៅម្តុំទួលសង្កែ បានថ្លែងថា សម្រាប់ថ្ងៃនេះខែនេះ គាត់និងកូនតូចៗ ២នាក់ គឺអាចនឹងរស់នៅជុំគ្នាបាន ប៉ុន្តែអនាគត មិនដឹងជាយ៉ាងទេ ហើយលោកក៏បារម្ភរឿងសុខភាពកូនផងដែរ ។

នៅក្នុងការដ្ឋានសំណង់អាគារដែលមានទំហំទទឹង ៤ ម៉ែត្រ និងបណ្តោយ ២០ម៉ែត្រ ហើយជំក្លិន ស៊ីម៉ង់ និងការបិទបំពង់ទីយោទឹក។ សែម បានថ្លែងថា លោកសម្រេចចិត្តយកប្រពន្ធកូនមកនៅជុំគ្នា គឺដើម្បីកាត់បន្ថយចំណាយ។

លោកបានបញ្ជាក់ថា "ម៉ាថ្ងៃធ្វើការបានលុយ៣ម៉ឺនរៀលអី តើនៅបែកគ្នាយ៉ាងម៉េច រស់នៅជួលផ្ទះម៉េច ដូច្នេះហើយក៏ចេញតែទ្រាំទៅ"។

លោកបានបន្តថា ឥឡូវនេះកូនតូចៗផង ចេះតែលើកកញ្ជើ (ផ្លាស់ប្តូកន្លែងរស់នៅ)ដើរតាមការដ្ឋានម្តងទៅនេះ ម្តងទៅនោះទៅ ប៉ុន្តែអនាគតប្រហែលជាឲ្យប្រពន្ធទៅស្រុកដើម្បីឲ្យកូនរៀន បើនៅជាមួយគ្នា គឺកូនប្រហែលរៀនមិនបានទេ។

លោកបានបញ្ជាក់ទៀតថា "ជាមួយប្រាក់ចំណូលប៉ុណ្ណេះខ្ញុំចេះតែចង់ឲ្យកូនរៀនហើយ ប៉ុន្តែមិនដឹងធ្វើម៉េច"។

បើតាមការអះអាងរបស់លោក សែម សព្វថ្ងៃនេះ កូនបងមានអាយុ ៤ឆ្នាំ ហើយរីឯកូនប្អូននោះ គឺមានអាយុ ២ឆ្នាំ។ ពួកគេរស់នៅក្នុងការដ្ឋានដ៏ចង្អៀតនេះ ដោយជួនកាលត្រូវឥដ្ឋធ្លាក់ចំជើង ត្រូវស៊ីម៉ង់ធ្លាក់ចំក្បាល ត្រូវនេះត្រូវនោះ ជួលកាលទៅលេងឈើមានដេកគោលមុតដៃ មុនជើងអីចឹងទៅ ប៉ុន្តែដូចរៀបរាប់ខាងលើដូច្នេះដែរ គឺមិនមានលទ្ធភាពនៅខាងក្រៅបាន។ លោកបានបន្តថា ប្រពន្ធនេះ ក៏ជាកម្មករដែរ ប៉ុន្តែសម្រាក ដោយសារតែជាប់មើលកូន មេកាឲ្យសម្រាកសិន តែបើគេប្រើធ្វើនេះធ្វើនោះតិចតួច គឺអាចបានចំណូលជួយទប់គ្នា១ម៉ឺន ទៅ២ម៉ឺនរៀល តាមការងារឥចឹងដែរទៅ។

*ដោយ អរិយបុត្រ*



*ថតដោយ កញ្ញា*

## សម្តេចតេជោ ហ៊ុន សែន អះអាងអំពីវត្តមាននៃកិច្ចប្រជុំកំពូលវិថីសូត្រនៅខែឧសភា

សម្តេចតេជោ ហ៊ុន សែន កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ បានថ្លែងអំពីការចូលរួមរបស់សម្តេចចំពោះកិច្ចប្រជុំកំពូលអំពីវិថីសូត្រ ដែលគ្រោងនឹងរៀបចំឡើងនៅក្នុងទីក្រុងប៉េកាំងប្រទេសចិននៅខែឧសភាឆ្នាំនេះ។

ការថ្លែងអំពីវត្តមានរបស់សម្តេចបានធ្វើឡើងនៅក្នុងពេលដែលសម្តេចអញ្ជើញចូលរួមជាអធិបតីនៅក្នុងពិធីសម្ពោធសមិទ្ធផលថ្មី និងបើកការដ្ឋានសាងសង់ផ្លូវខ្សែក្រវាត់ក្រុង។

កិច្ចប្រជុំកំពូលនេះ គឺជាវេទិការមួយដែលមកដល់ពេលនេះ មេដឹកនាំចិន កំពុងតែបានបញ្ជូនលិខិតអញ្ជើញជាច្រើនទៅមេដឹកនាំនៅលើពិភពលោក។ កិច្ចប្រជុំនេះ ជាផ្នែកមួយ គំនិតផ្តួចផ្តើម "វិថីមួយខ្សែក្រវាត់មួយ" ដែលផ្តួចផ្តើមឡើងដោយមេដឹកនាំចិន នៅក្នុងគោលបំណង កសាងនូវវិថីសូត្រមួយ ដើម្បីជំរុញវិស័យពាណិជ្ជកម្ម និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធនៅអាស៊ី និងអឺរ៉ុប ។

នៅក្នុងអំឡុងពេលនោះសម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងអំពីក្តីសង្ឃឹមថាកម្ពុជានឹងទទួលបានការគាំទ្រពីចិននៅក្នុងការកសាងស្ពានឆ្លងទន្លេមេគង្គពីរកន្លែង គឺមួយពីជ្រោយចង្វាទៅស្វាយជ្រុំ និងមួយទៀតអរិយក្សត្រទៅក្តីតាកុយ។

## កូរ៉េខាង ជើងសាកល្បងមីស៊ីលថ្មី កូរ៉េខាងត្បូង ជប៉ុន អាមេរិកថ្កោលទោស

ប្រទេសបី រួមមានកូរ៉េខាងត្បូង ជប៉ុន និងអាមេរិកនៅថ្ងៃទី៦ ខែមីនាបានរួមគ្នាថ្កោលទោសកូរ៉េខាងជើងចំពោះការបាញ់កាំជ្រួចមីស៊ីល ៤ដើមកាលពីព្រឹកថ្ងៃច័ន្ទដោយ៣ដើមធ្លាក់ចូលក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ជប៉ុន។

កូរ៉េខាងជើងបានបាញ់មីស៊ីលចេញពីតំបន់តុងចាង រី កន្លែងដែលជាមូលដ្ឋានមីស៊ីលហើយយោធាកូរ៉េខាងត្បូងនិយាយថា មីស៊ីលដែលបាញ់ចេញពីឆ្នេរខាងកើតរបស់ប្រទេសនេះ ហើយបានហោះចម្ងាយប្រមាណ ១.០០០ គីឡូម៉ែត្រមុនពេលវាធ្លាក់។

តុងចាងរីមានទីតាំងស្ថិតនៅព្រំដែនកូរ៉េខាងជើងជាប់ជាមួយប្រទេសចិន កន្លែងដែលរដ្ឋមួយនេះបានបាញ់រ៉ុក្កែតចម្ងាយឆ្ងាយកាលពីឆ្នាំមុន ដើម្បីដាក់សម្ភារៈទៅតារាវិថី និងត្រូវបានថ្កោលទោសដោយអ.ស.បថាបានបំពានសេចក្តីសម្រេចចិត្តនានា ដែលហាមប្រាមការប្រើប្រាស់បច្ចេកវិជ្ជាកាំជ្រួច។

ដើម្បីឆ្លើយតបនឹងការសាកល្បងគ្រាប់មីស៊ីលពីសំណាក់កូរ៉េខាងជើងជាបន្តបន្ទាប់ ប្រទេសកូរ៉េខាងត្បូង និងជប៉ុន កំពុងតែពន្លឿនកម្មវិធីនៃការដាក់ពង្រាយប្រព័ន្ធ THAAD និងទទួលយកប្រព័ន្ធការពារប្រឆាំងកាំជ្រួចនុយក្លេអ៊ែររបស់កូរ៉េខាងជើង។

ការបាញ់កាំជ្រួចនេះទំនងជាការប្រឆាំងតវ៉ាទៅនឹងសមយុទ្ធរួមគ្នាដែលកំពុងប្រព្រឹត្តទៅរវាងយោធាកូរ៉េខាងត្បូងនិងអាមេរិក ដែលបានចាប់ផ្តើមកាលពីសប្តាហ៍មុននិងត្រូវចំណាយពេល២ខែឯណោះ។

## សម្តេចតេជោ ហ៊ុន សែន អះអាងពីការពិតចំពោះការលេចធ្លាយព័ត៌មានតាមបណ្តាញសង្គម

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច បានថ្លែងការពារការលេចធ្លាយព័ត៌មានដែលគេទម្លាយអំពីទំនាក់ទំនងរវាងសម្តេចនិងលោកកឹម សុខា ប្រធានគណ-បក្សសង្គ្រោះជាតិ ថ្មីថា ជាព័ត៌មានពិត។

ថ្លែងនៅក្នុងពិធីសម្ពោធសមិទ្ធផលជាផ្លូវក្រវាត់ក្រុងកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ព័ត៌មានដែលលេចធ្លាយជាព័ត៌មានពិត ហើយសម្លេងដែលលេចធ្លាយមិនមែនជាសម្លេងដែលកាត់តនោះទេ។

សម្តេចតេជោ ហ៊ុន សែន ក៏បានព្រមាននឹងបញ្ចេញនូវព័ត៌មានបន្ថែមទៀតនៅក្នុងករណីនេះតាមបណ្តាញសង្គមនានាក្រៅពីហ្វេសបុក ថែមទៀត ប្រសិនបើមេដឹកនាំគណបក្សប្រឆាំងថ្មី បដិសេធការពិតនៃការសន្ទនានោះ។

កាលពីថ្ងៃទី០៤ ខែមីនា មានសម្លេងសន្ទនា មួយដែលមានរយៈពេលប្រមាណជា ២០នាទី បង្ហាញអំពីការពិតរវាងសម្តេចតេជោ ហ៊ុន សែន និងលោកកឹម សុខា ត្រូវបានលេចធ្លាយតាមបណ្តាញហ្វេសបុក។

## នាយករដ្ឋមន្ត្រីចិនប្រកាសបន្ថយគោលដៅកំណើនសេដ្ឋកិច្ចមកនៅត្រឹម៦,៥%

លោក លី ខឺឈាង នាយករដ្ឋមន្ត្រីចិនបានប្រកាសពីគោលដៅបន្ថយកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនសម្រាប់ឆ្នាំនេះ។

លោកបានអះអាងថា កំណើនសេដ្ឋកិច្ចត្រូវបានបន្ថយមកនៅប្រហែល៦,៥% ពោលគឺធ្លាក់ចុះពី៦,៥%ទៅ៧% កាលពីឆ្នាំមុននេះ ។

លោកបានថ្លែងបែបនេះទៅកាន់សភាប្រជាជនជាតិរបស់ប្រទេសចិន ដែលបានកោះប្រជុំប្រចាំឆ្នាំរបស់ខ្លួននៅក្នុងទីក្រុងប៉េកាំង។

យោងតាមសន្ទស្សន៍សេដ្ឋកិច្ចបង្ហាញថា សេដ្ឋកិច្ចរបស់មហាយក្សចិនបានកើនឡើងក្នុងកម្រិតល្បឿនយឺតបំផុតរបស់ខ្លួនសម្រាប់រយៈពេល ២៦ឆ្នាំនៅក្នុងឆ្នាំ២០១៦។

លោកនាយករដ្ឋមន្ត្រីចិនរូបនេះបានគូសបញ្ជាក់ថា លោកនឹងលៃលកដោះ-ស្រាយជាមួយបណ្តាក្រុមហ៊ុនសហគ្រាសត្រូវការឧបត្ថម្ភធនរបស់រដ្ឋ ដែលផលិតធ្យូងថ្ម និងដែកច្រើនជាងតម្រូវការទីផ្សារ៕

## គណបក្សនយោបាយ១២នឹងចូលរួមប្រកួតនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសឲ្យដឹងថា គិតត្រឹមម៉ោង ៥និង៣០នាទីល្ងាច ថ្ងៃទី០៤ មីនា មានគណបក្សនយោបាយចំនួន១២ បានសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ/សង្កាត់ នៅពេលខាងមុខ។

ប្រភពដដែលបានបន្តថា នៅក្នុងចំណោមគណបក្សទាំងនោះ មាន ១.គណបក្សប្រជាជនកម្ពុជា សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ១,៥៧០។ ២.គណបក្សសង្គ្រោះជាតិ សុំចុះបញ្ជីនៅក្នុងឃុំ សង្កាត់ចំនួន ១,៣៧២។ ៣.គណបក្សហ្វ៊ុនស៊ិនប៉ិច សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ២៨៧។ ៤.គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ៥១៧។ ៥.គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ១០១។ ៦.គណបក្សប្រជាធិបតេយ្យមូលដ្ឋាន សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ២៣។ ៧.គណបក្សសញ្ជាតិកម្ពុជា សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ១១។ ៨.គណបក្សខ្មែររួបរួមជាតិ សុំចុះបញ្ជីនៅក្នុងឃុំ សង្កាត់ចំនួន ២៦១។ ៩.គណបក្សសាធារណរដ្ឋប្រជាធិ-បតេយ្យ សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ។ ១០.គណបក្សយុវជនកម្ពុជា សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ៩។ ១១.គណបក្សអំណាចខ្មែរ សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ៣។ ១២.គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា សុំចុះបញ្ជីនៅក្នុងឃុំ/សង្កាត់ចំនួន ៣។

ជុំវិញបញ្ហានេះកាលពីម្សិលមិញ សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបាន អំពាវ នាវគណបក្សទាំងអស់ឲ្យចូលរួមការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ហើយកុំមានជំងឺតួងង ពីព្រោះការបោះឆ្នោតនេះមានគណបក្សនយោបាយចូលរួមច្រើន ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ គ្រោងនឹងប្រព្រឹត្តទៅនាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ។

# ពលរដ្ឋកម្ពុជាចាប់អារម្មណ៍នឹងសេវាកម្មដឹកជញ្ជូន



ប្រជាពលរដ្ឋកម្ពុជាទាំងអ្នកដែលបានធ្លាប់សាកល្បងនឹងសេវាកម្មដឹកជញ្ជូនតាមផ្លូវដែកជាថ្មី ក្រោយពេលមធ្យោបាយដឹកជញ្ជូននេះត្រូវទុកចោលរាប់ឆ្នាំ ក្រោមការគំរាមកំហែងដោយធម្មជាតិ និងពេលវេលា ដោយសារការមិនយល់ចិត្តទុក្ខដាក់ និងអ្នកដែលមិនទាន់សាកល្បង បានរីករាយស្វាគមន៍ទាំងអស់គ្នានូវការដាក់ឲ្យដំណើរការសេវាកម្មដឹកជញ្ជូននេះ។

លោក ខេត សុភ័ត្រា ជាមន្ត្រីនៃអង្គការសង្គមស៊ីវិលមួយបានមានប្រសាសន៍ថា បើទោះបីជាសេវាកម្ម ដឹកជញ្ជូនតាមប្រព័ន្ធនេះវាមិនទាន់ល្អប្រសើរដូចនៅបរទេសយ៉ាងណាក៏ដោយ ក៏វាមានលក្ខណៈអាចទទួលយកបានដែរ។

លោកបានបញ្ជាក់ថា "តាមដែលខ្ញុំធ្លាប់ជិះរថភ្លើងនៅក្នុងប្រទេសថៃ សិង្ហបុរី ចិន និងជប៉ុន សេវាកម្មដឹកជញ្ជូនផ្លូវដែកយើងមិនដល់គេទេ ប៉ុន្តែវាជាមោទនភាពដែលយើងបានប្រែក្លាយមធ្យោបាយដែលសឹងតែគេបំភ្លេចចោលមកឲ្យដំណើរការឡើងវិញ"។

លោកបានបន្តថា តាមការប្រៀបធៀបសេវាកម្មដឹកជញ្ជូនតាមរថភ្លើងនៅកម្ពុជាយើងពិតជាមិនដល់គេមែន តាំងពីផាសុកភាព ល្បឿន និងសោភ័ណភាព ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលយើងអាចធ្វើបានប៉ុណ្ណឹងចាត់ទុកថា វាប្រសើរណាស់ទៅហើយ។

លោកបានបន្តទៀតថា ស្ថានភាពវាម្យ៉ាងម្នាក់ទេ។ រថភ្លើងយើងចាស់ ផ្លូវយើងទៀតសោតក៏មិនជារឹងមាំ អាចឲ្យរថភ្លើងបើកបរលឿនបាន ប៉ុន្តែរថភ្លើងរបស់យើងមានតម្លៃពិសេសមួយ ដែលរកនិយាយមិនត្រូវ។

លោកបានបញ្ជាក់ថា "វារកនិយាយមិនត្រូវ សេវាកម្មមិនជាល្អជាងគេទេ ល្បឿនក៏យឺតទៀតហើយសោភ័ណ្ឌភាពក៏មិនស៊ីរថភ្លើងស្រុកគេដែរ ប៉ុន្តែពេលជិះមានអារម្មណ៍ថា មោទនភាពនឹងជាតិយើងដែរ។"

លោកបានបន្តទៀតថា ល្បឿនរថភ្លើងដែលបើកនេះ គឺមិនទាន់ចិត្តទេបើនិយាយរឿងដឹកជញ្ជូនទំនិញ និងពាណិជ្ជកម្មផ្សេងៗ ប៉ុន្តែបើនិយាយអំពីទេសចរណ៍ គឺពិតជាមិនអាចមើលរំលងបាន។

លោកបានបញ្ជាក់ថា "បើសិនការជិះដើម្បីហេតុផលទេសចរណ៍ គឺពិតជាប្រសើរ ប៉ុន្តែបើនិយាយអំពីពាណិជ្ជកម្ម គឺពិតជាយឺតណាស់។

លោកស្រីសឿន វត្ថារី ជាស្ត្រីមេផ្ទះមួយរូបបានថ្លែងថា លោកស្រីនៅមិនទាន់បានសាកល្បង ជិះសេវាកម្មរថភ្លើងនៅឡើយទេ ហើយនៅពេលបច្ចុប្បន្ននេះកំពុងតែរកឱកាសធ្វើដំណើរតាមរថភ្លើងនឹងគេម្តង។

លោកស្រី បានបញ្ជាក់ថា "ខ្ញុំឮតែគេថា វាសប្បាយ ប៉ុន្តែនៅមិនទាន់មានឱកាសសាកល្បងនឹងគេ បានម្តងនៅឡើយ"។

លោកស្រី បានបន្ថែមថា តាំងពីសេវាកម្មដឹកជញ្ជូនតាមរថភ្លើងបានត្រូវសម្ពោធមកឃើញអ្នកធំៗ តាំងពីព្រះមហាក្សត្រជាដើមសាកល្បងអស់ហើយ ប៉ុន្តែខ្ញុំនិងគ្រួសារនៅមិនទាន់មានឱកាស នឹងគេបានម្តងនៅឡើយដែរ។

ស្ត្រីមេផ្ទះរូបនេះបានបញ្ជាក់ថា "តាំងពីសម្ពោធបើកដំណើរការមក ខ្ញុំប៉ុនប៉ងសាកល្បងពីរទៅបីដងនឹងគេដែរ ប៉ុន្តែចេះតែឃ្វាង"។

លោកស្រីបានបន្តទៀតថា កាលពីលើកទីមួយ រៀបចំចេញទៅហើយ ប៉ុន្តែដល់ទៅសាកសួរ រឿងសំបុត្រគេថា អត់មានសំបុត្រទេ ដោយសារលក់អស់ហើយ ក្រោយមក ក៏គ្រោងទៅម្តងទៀត ប៉ុន្តែដល់ពេលដែលទំនាក់ទំនងទៅមន្ត្រីនៅស្ថានីយរថភ្លើង គេប្រាប់ថា អត់មានទេ លោកធំកក់អស់ហើយ ដល់ថ្មីៗនេះ ពេលឆ្លងឆ្នាំក៏គិតថា មានឱកាសសម្រាកក៏ចង់នាំគ្រួសារទៅលេង ប៉ុន្តែចំពេលព្រះមហាក្សត្រយាងតាមរថភ្លើងដែរ ក៏ខកទៀត

## រដ្ឋមន្ត្រី៖ ឆ្នាំ២០១៧ ជាឆ្នាំពង្រឹងការជួសជុលថែទាំផ្លូវថ្នល់ ដែក និងទឹកដើម្បីជំរុញការដឹកជញ្ជូន

លោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន បានមានប្រសាសន៍កាលពីពេលថ្មីៗនេះថា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងកាត់បន្ថយតម្លៃដឹកជញ្ជូន នៅឆ្នាំនេះក្រសួងកំពុងតែផ្តោតលើការងារពង្រឹងការជួសជុលថែទាំផ្លូវថ្នល់ ដែក និង ទឹក។

លោកទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីសមិទ្ធិផល សម្រេចបាននាពេលថ្មីៗកន្លងទៅនេះ ចាប់តាំងពីការចូលកាន់តំណែងដែលនោះរួមមាន "ការកាត់បន្ថយថ្លៃឈ្នួលដឹកជញ្ជូន ការដាក់ឱ្យដំណើរការមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរ ការរៀបចំបង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈ ប្រព័ន្ធចេញផ្លាកលេខសម្គាល់យានយន្តថ្មី ការពង្រីក ការផ្តល់សេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តការផ្សព្វផ្សាយពីបច្ចេកទេសនៃការជួសជុលកែច្នៃយានយន្ត យុទ្ធនាការចុះបង្ក្រាបរថយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ការផ្តល់ជូនឧបករណ៍ ឈរបញ្ជាចរាចរណ៍ សម្រាប់ប៉ូលីសនគរបាលចរាចរណ៍ ប្រើប្រាស់នៅតាមផ្លូវចំណុចប្រសព្វ ការផ្ទេរកម្មសិទ្ធិយានយន្ត និងគំនិតផ្តួចផ្តើមថ្នាក់ជាតិ ផ្តោតលើសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

លោកក៏បានលើកឡើងនូវផែនការតភ្ជាប់ផ្លូវដែកមួយខ្សែរទៀត ដោយភ្ជាប់ពី តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញទៅកាន់ព្រលានយន្តហោះអន្តជាតិភ្នំពេញ និងគម្រោងប្រើប្រាស់ផ្លូវទឹកឲ្យអស់លទ្ធភាព ដើម្បីសម្រួលនិងកាត់បន្ថយការកកស្ទះចរាចរណ៍ផ្លូវគោក និងកាត់បន្ថយចំណាយដឹកជញ្ជូនផងដែរ។

# តាមរថភ្លើង ប៉ុន្តែរអ៊ូរឿងពេលវេលា




photo supply

រហូតដល់សព្វថ្ងៃនេះ ។

លោកស្រីបានបន្តទៀតថា បានអីរកកន្លែងអង្គុយបាន បើរថភ្លើងនៅក្នុងស្រុកយើងរត់តែជាមួយនឹងទូចំនួន៤ ទៅ ៥ ហ្នឹង។

នេះគឺជាចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅភ្នំពេញ ដោយឡែកប្រជាពលរដ្ឋ ដែលរស់នៅក្នុងភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាឯណោះវិញ ក៏បានបង្ហាញនូវចំណាប់អារម្មណ៍ ទន្ទឹងចង់សាកល្បងសេវាកម្មដឹកជញ្ជូនតាមផ្លូវដែកនេះដែរ។

លោក សាត បុណ្ណា ជាអាជីវករមួយរូបនៅខេត្តបាត់ដំបង បានថ្លែងថា ប្រជាពលរដ្ឋនៅភូមិភាគពាយ័ព្យ ពិតជាចង់ឃើញរថភ្លើងឡើងវិញណាស់ ក្រោយពីលែងបានឃើញវា ជាងដប់ឆ្នាំមកហើយ។

លោកបានបន្តទៀតថា "យើងឃើញតែឡាវីទេ ប៉ុនដប់ឆ្នាំនេះ "។

លោក ខេង សាមិត ជាមន្ត្រីរាជការចូលនិវត្តន៍មួយរូប ដែលបច្ចុប្បន្ននេះ កំពុងតែស្នាក់នៅក្នុងក្រុងបាត់ដំបង បានមានប្រសាសន៍ថា រថភ្លើងយើងពីសង្គមមកមានពីរខ្សែ គឺមួយខ្សែ ទៅភូមិភាគនិរតី និងមួយខ្សែទៀត មកកាន់ភូមិភាគពាយ័ព្យ។ ហើយបើតាមលោកចាំ គឺរថភ្លើងនេះ សុទ្ធតែជាសមិទ្ធិផលនៅក្នុងសម័យសង្គមរាស្ត្រនិយម សម័យសម្តេចសីហនុ។

លោកបានបញ្ជាក់ថា "ឥឡូវនេះប្រជាពលរដ្ឋខាងនិរតីគេឃើញរថភ្លើងវិញហើយ លើកលែងតែប្រជាពលរដ្ឋខាងភាគពាយ័ព្យ នៅមិនទាន់ឃើញនឹងគេ"។

លោកបានរៀបរាប់ពីបទពិសោធន៍កាលពីសម័យមុនសង្គ្រាមថា រថភ្លើងស្រួលហើយទេសភាពក៏ស្អាតទៀត ប៉ុន្តែឥឡូវមិនដឹងយ៉ាងម៉េចទេ។

លោកបានរៀបរាប់នៅបេនរថយន្តក្រុងសុរិយាជិតផ្សារធំថ្មីថា "ស្រណោះដែរពេលនិយាយអំពីរថភ្លើង។ កាលពីខ្ញុំនៅក្មេង ខ្ញុំចាំបានថា ខ្ញុំធ្វើដំណើរជាមួយ លោកពុក អ្នកម្ដាយខ្ញុំ តែតាមរថភ្លើង"។

លោក បានបន្តទៀតថា សម័យនោះលោក មិនដែលស្គាល់ភ្នំពេញនឹងគេនោះទេ ដោយសារមិនមានបងប្អូន ប៉ុន្តែឧស្សាហ៍ធ្វើដំណើរវាង ពោធិសាត់ បាត់ដំបង ជួនកាលមកដល់កំពង់ឆ្នាំង ម្តងម្កាលដែរ។

លោកបានសន្មាថា ប្រសិនបើផ្លូវដែកភ្នំពេញ បាត់ដំបង គេបើកឲ្យដំណើរការ ហើយលោក នៅមានជីវិតលោក នឹងសាកល្បងប្រើសេវាកម្មដឹកជញ្ជូននេះ។

កញ្ញា ស៊ីម សុវណ្ណរី ជាយុវនិស្សិតមួយរូបដែលមានទីលំនៅនៅខេត្តពោធិសាត់ ហើយបច្ចុប្បន្ន កំពុងតែសិក្សាជំនាញទេសចរណ៍នៅក្នុងទីក្រុងភ្នំពេញបានរៀបរាប់ថា នាងខ្ញុំឮតែចាស់ៗនិយាយទេ រឿងរថភ្លើងនេះ។

កញ្ញាបានរៀបរាប់ថា តាំងពីកញ្ញាដឹងក្តីមក រថភ្លើងនៅកម្ពុជាលែងដំណើរការទៅហើយ ដោយសារតែវាចាស់ទ្រុឌទ្រោម។

កញ្ញា បានអះអាងបញ្ជាក់ថា "តាមដែលនាងខ្ញុំចាំ គឺធ្លាប់ឃើញរថភ្លើង ប៉ុន្តែដល់ពេលនាងខ្ញុំធំដឹងក្តីមក បើកភ្នែកឡើងឃើញតែឡូរី"។

កញ្ញាបានបន្តថា ផ្ទះរបស់នាងនៅឯខេត្ត គឺមានផ្លូវរថភ្លើងកាត់ពីក្រោយ ហើយពេលទៅសាលា ជាពិសេស ចាប់ពីអនុវិទ្យាល័យមកដល់វិទ្យាល័យ គឺនាងឧស្សាហ៍ជិះឡូរីទៅរៀនណាស់ ដោយសារតែវាសប្បាយ ហើយខ្ចិលជិះកង់ ឬម៉ូតូ ហើយក៏មានសុវត្ថិភាពថែមទៀត។

កញ្ញាបានបន្តទៀតថា នៅពេលដែលកំណាត់ផ្លូវដែកភ្នំពេញបន្ទាយមានជ័យ ត្រូវបានដាក់ឲ្យដំណើរការ កញ្ញាបានអះអាងថា នឹងចូលរួមគាំទ្រ ហើយនឹងសាកល្បងធ្វើដំណើរយ៉ាងហោចណាស់ក៏ម្តងដែរដើម្បីឲ្យស្គាល់។

កញ្ញាបានបញ្ជាក់ថា "ចេះតែចង់សាកហើយ! ខ្ញុំធ្លាប់តែជិះឡូរី ជិះឡាន និងកាណូត ប៉ុន្តែនៅរថភ្លើង និងយន្តហោះ! ខ្ញុំចង់សាកនឹងគេម្តង ដើម្បីឲ្យដឹង"។

គួររំឭកថា កាលពីខែមេសា ឆ្នាំ២០១៦ កន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការផ្តល់សិទ្ធិវិនិយោគដល់ក្រុមហ៊ុនរ៉ូយ៉ាល ហ្គ្រុប រយៈពេល ៣០ឆ្នាំ បានដាក់ឲ្យដំណើរការនូវកំណាត់ផ្លូវដែក ដែលមានប្រវែង ២៥៦គម ពីភ្នំពេញទៅខេត្តព្រះសីហនុ សម្រាប់សេវាកម្មដឹកអ្នកដំណើរដោយមួយជើងមានកៅអីពីចំនួន ១៣០ ទៅ ១៦៥នាក់ ហើយមានតែថ្ងៃសៅរ៍ និងថ្ងៃអាទិត្យប៉ុណ្ណោះ ដោយនៅលើកំណាត់ផ្លូវនោះ ត្រូវចំណាយពេលប្រមាណជា ពី ៧ទៅ ៨ម៉ោង។ កំណាត់ផ្លូវដែកនេះ គឺចំណាយថវិកាជួសជុលសរុបទាំងអស់ចំនួន ១៤១,៦លានដុល្លារ។ ដោយថវិកាគឺបានមកពីប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី ជំនួយពីរដ្ឋាភិបាលអូស្ត្រាលី ប្រាក់កម្ចីពីអង្គការមូលនិធិអភិវឌ្ឍន៍ នៃអង្គការអូប៉ិច។

ក្រៅពីកំណាត់ផ្លូវដែកនេះ កម្ពុជានៅមានកំណាត់ផ្លូវដែកដែលមានស្រាប់មួយខ្សែទៀត គឺភ្ជាប់ពីភ្នំពេញទៅកាន់ប៉ោយប៉ែត ដែលគេរំពឹងថា នឹងជួសជុលរួចរាល់ព្រមទាំងដាក់ឲ្យដំណើរការនៅក្នុងពេលឆាប់ៗនេះ។ កំណាត់ផ្លូវដែកនេះមានប្រវែងសរុបប្រមាណជា ៣៣៧ គម។ ក្រៅពីគម្រោងផ្លូវ ដែកនេះ រដ្ឋាភិបាលកម្ពុជាក៏បានគ្រោងហើយកំពុងតែដើររកមូលនិធិដើម្បីកសាងផ្លូវដែកយ៉ាងហោចណាស់ក៏ពីរខ្សែទៀតផងដែរ ដោយភ្ជាប់ពី សៀមរាបទៅស៊ីសុផុន និងមួយខ្សែទៀតភ្ជាប់ពីស្នួលទៅ វៀតណាម និងពីស្នួលទៅឡាវ។

ឯកសារមួយរបស់ក្រសួងសាធារណៈការនិងដឹកជញ្ជូនបានឲ្យដឹងថា គម្រោងកសាងផ្លូវដែក នេះគឺស្ថិតនៅក្នុងគម្រោងផែនការមេរបស់ក្រសួងអស់ហើយ គឺនៅរង់ចាំតែថវិកានឹង ដាក់ឲ្យដំណើរការភ្លាម។ *ដោយ អរិយបុត្រ*

## ប្រវត្តិផ្លូវដែកនៅកម្ពុជា

តាមឯកសារផ្លូវការរបស់ក្រសួងសាធារណៈការនិងដឹកជញ្ជូនបានឲ្យដឹងថា ផ្លូវដែកកម្ពុជាមានពីរខ្សែ ដោយមួយខ្សែកសាងនៅសម័យអាណានិគមនិយមបារាំង និងមួយខ្សែទៀតកសាងនៅសម័យសង្គមរាស្ត្រនិយម។

ប្រភពដដែលបានឲ្យដឹងថា ខ្សែទីមួយ គឺភ្ជាប់ពីភ្នំពេញ ទៅបាត់ដំបង ទៅប៉ោយប៉ែត ត្រូវបានកសាងឡើងចន្លោះរវាងឆ្នាំ១៩២៩ ដល់ ឆ្នាំ ១៩៤២ មានប្រវែងសរុប ប្រមាណជា ៣៨៦ គម។ ខ្សែទីពីរ គឺពីភ្នំពេញទៅកាន់ ខេត្តព្រះសីហនុ និងកំពង់ផែសមុទ្រនៅខេត្តនេះសាងសង់នៅក្នុងរវាងឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៩ មានប្រវែងសរុបចំនួន ២៦៦គម ។

នៅក្នុងសម័យសង្គ្រាមស៊ីវិលផ្លូវដែកទាំងពីរខ្សែបានរងនូវការគំរាមកំហែងដោយសារសង្គ្រាម ពីគ្រប់ភាគី និងគ្រោះធម្មជាតិ និងកង្វះការថែទាំ ទើបតែរាជរដ្ឋាភិបាលកម្ពុជាបានស្វះស្វែងរកម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍឡើងវិញក្រោយពីកម្ពុជាមានសន្តិភាព ហើយវិស័យអាទិភាពមួយចំនួន បានស្តារនិងកសាងឡើងវិញ ទើបវិស័យដឹកជញ្ជូនតាមផ្លូវដែកនេះ ត្រូវបានស្តារឡើងវិញដែរ។

# ពិធីបុណ្យឆ្លងព្រះវិហារ សន្តសិលា នៅពោធិ៍ធំ



ថតដោយ សម្បត្តិ



គ្រីស្តបរិស័ទ រាប់រយនាក់មកពីព្រះសហគមន៍នានា មកជួបជុំក្នុងពិធីអរព្រះគុណព្រះជាម្ចាស់ នៃបុណ្យឆ្លងព្រះវិហារថ្មី គឺព្រះវិហារសន្តសិលា ស្ថិតនៅក្នុងព្រះសហគមន៍ចំណាស់មួយនៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង ក្នុងភូមិពោធិ៍ធំ ស្រុកល្វាឯម ខេត្តកណ្តាល ដែលបានប្រារព្ធកាលពីថ្ងៃទី១៨ កុម្ភៈ កន្លងទៅក្រោមអធិបតីភាពលោកអូលីវីយេ ឝ្មីតអឺស្លែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។ សម្លេងភ្លេងរបាំក្ងោកពោធិសាត់ អមដោយអ្នករបាំរាំព័ទ្ធពេន នាំមុខ ក្បួនដង្ហែជុំវិញអគារព្រះវិហារថ្មី ពេលខ្លះក៏មានបទចម្រៀងកោតសរសើរព្រះជាម្ចាស់។ ក្នុងក្បួនមានលោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័ទ។ ក្រោយបានហែចំនួនបីជុំព្រះវិហារថ្មី ទាំងលោកអភិបាល បូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់បានមកជួបជុំគ្នានៅមុខព្រះវិហារថ្មី ក្នុងពេលនោះមានតំណាងគ្រីស្តបរិស័ទនៃព្រះសហគមន៍ពោធិ៍ធំ គឺលោកស្រីតួច បានប្រគល់កូនសោរព្រះវិហារថ្មីជូនលោកអភិបាល។ ព្រះវិហារថ្មីនេះមានឈ្មោះថា "ព្រះវិហារសន្តសិលា"។ លោកអភិបាលអូលីវីយេ បានអធិដ្ឋាន និងគូសសញ្ញាឈើឆ្កាងនៅទ្វារព្រះវិហារថ្មី រួចអញ្ជើញគ្រីស្តបរិស័ទទាំងអស់ឲ្យចូលទៅក្នុងព្រះវិហារថ្មី ដែលជាព្រះរាជ្យដំណាក់នៃព្រះជាម្ចាស់ ដើម្បីប្រារព្ធពិធីអភិបូជា ដែលជាពិធីលើកតម្កើង និងអរព្រះគុណព្រះជាម្ចាស់។ នៅក្នុងការចាប់ផ្តើមនៃអភិបូជាលោកអូលីវីយេ បានប្រទានពរលើទឹក និងប្រោសទៅលើគ្រីស្តបរិស័ទ ដើម្បីរំឭកដល់អ្នកចូលរួមទាំងអស់អំពីអត្ថន័យនៃអគ្គសញ្ញាជ្រមុជទឹក ដែលបានណែនាំយើងឲ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ បន្ទាប់មកលោកអភិបាលប្រោសទឹកទៅលើជញ្ជាំងព្រះវិហារថ្មី ដែលជាសញ្ញានៃការលាងជម្រះឲ្យបានស្អាតបរិសុទ្ធថ្វាយព្រះអង្គ និងសាកសមនឹងធ្វើជាព្រះរាជ្យដំណាក់នៃព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។ នៅក្នុងធម្មទេសនាលោកអភិបាលបានមានប្រសាសន៍ថា នៅទីនេះជាព្រះសហគមន៍ចាស់ជិត១០០ឆ្នាំ ប៉ុន្តែនៅក្នុងព្រះសហគមន៍នេះយើងជឿថា បងប្អូន គឺជាសំណង់ដ៏សំខាន់ដែលព្រះជាម្ចាស់កំពុងសាងសង់ ហើយគ្មាននរណាអាចចាក់គ្រឹះណាផ្សេងក្រៅពីព្រះជាម្ចាស់បានឡើយ។ លោកបានលើកទឹកចិត្តគ្រីស្តបរិស័ទ ដោយប្រៀបធៀបជីវិតព្រះសហគមន៍នៅទីនេះទៅនឹងគ្រឹះនៃអាគារ ព្រោះថាគ្រឹះគឺជាការងាររយូរ។ លោកបន្ថា រយៈពេល១០ឆ្នាំនៅទីនេះគ្រឹះរបស់យើងមើលមិនឃើញ តែក្រោយមកយើងឃើញមានរូបរាង ហើយយើងត្រូវការពេលដើម្បីតុបតែង គឺត្រូវការតុបតែងជីវិតរបស់យើងតាមរបៀបព្រះជាម្ចាស់ ដោយលាបថ្នាំនៃសេចក្តីស្រឡាញ់ ថែមផ្កានៃមេត្តាករុណា និងថ្នាំនៃការលើកលែងទោស ដើម្បីឲ្យសំណង់នេះស្រស់ស្អាត។ លោកអូលីវីយេ បានផ្តាំផ្ញើទៀតថា អ្វីដែលសំខាន់ គឺសូមឲ្យបងប្អូននៅទីនេះថែរក្សាជំនឿ ដោយតុបតែងជីវិតរបស់យើង និងដឹងថា ព្រះវិហាររបស់យើងនៅទីនេះមានព្រះកាយព្រះយេស៊ូ ដែលទន្ទឹងរង់ចាំយើងនៅទីនេះ។ លោកបានសំណូមពរដល់គ្រីស្តបរិស័ទទាំងអស់ជាពិសេសគ្រីស្តបរិស័ទនៅព្រះវិហារសន្តសិលាឲ្យធ្វើជាដើមស្វាយលំអរព្រះវិហារដែលផ្តល់ផលផ្លែថ្មីៗជារៀងរាល់ខែ ដោយនឹកដល់ពូជរបស់យើងដែលជាមរណសាក្សី និងបានដុះចេញពីទឹកដីកន្លែងនេះ មានលោកអភិបាល ឆ្មារសាឡាស និងលោកបូជាចារ្យឆ្មារ សាឡឹមជាដើម។ លោកអូលីវីយេបន្តថា សូមឲ្យកន្លែងនេះជាកន្លែងមួយដែលផ្តល់ក្តីសង្ឃឹម ជាកន្លែងដែលថ្លែងអំពីព្រះជាម្ចាស់ ដោយធ្វើជាសហការីនៃព្យាការីផងដែរ។ លើសពីនេះទៅទៀត លោកថា ទោះបីមានគណៈកម្មការហើយ ក៏ដោយតែព្រះសហគមន៍របស់យើងត្រូវរួមគ្នាដើម្បីកសាងព្រះសហគមន៍ព្រះយេស៊ូ ដែលជាព្រះសហគមន៍រងទុក្ខលំបាកពិតមែន តែជាព្រះសហគមន៍ដែលផ្តល់ក្តីសង្ឃឹម និងអំណរសប្បាយដែលបង្ហាញពីសិរីរុងរឿងរបស់ព្រះជាម្ចាស់។ បន្ទាប់ពីបញ្ចប់ធម្មទេសនា លោកអភិបាលព្រះសហគមន៍ បានប្រសិទ្ធិពរលើតុអាសនៈ ដោយប្រេងគ្រីស្មា ដើម្បីឲ្យបានទៅជាតុសក្ការៈ ព្រមទាំងបញ្ចុះធាតុសន្តីតេរេសានៅកាល់គូតា ក្នុងតុសក្ការៈ ដើម្បីអធិដ្ឋានសូមឲ្យសន្តីជួយថែរក្សាបងប្អូននៅក្នុងព្រះសហគមន៍នេះ។ លោកក៏បន្តដោយលាបប្រេងនៅតាមសរសរព្រះវិហារដែលបង្ហាញពីវត្តមានព្រះជាម្ចាស់គង់នៅ។ លោកបូជាចារ្យ ហ្គូស្តាវ៉ូ បានមានប្រសាសន៍ថា ព្រះសហគមន៍ពោធិ៍ធំ គឺជាព្រះសហគមន៍មួយដែលកើតមានតាំងពីដើមដោយមានគ្រីស្តបរិស័ទខ្មែរ ពីមួយជំនាន់ទៅមួយជំនាន់ ដូចនេះចំពោះយើង ព្រះវិហារថ្មីនេះមានអត្ថន័យ និងសារៈសំខាន់ចំពោះភូមិពោធិ៍ធំតែម្តង។ លោកបន្ថែមថា ម៉្យាងទៀតតាំងពីមុនសម័យប៉ុលពត កន្លែងនេះមានអត្ថន័យពិសេសសម្រាប់គ្រីស្តបរិស័ទនៅទីនេះ ព្រោះជាកន្លែងដែលលោកឆ្មារ សាឡាស លោកឆ្មារ សាឡឹម ដែលជាមរណសាក្សីរបស់យើងធ្លាប់បានរស់នៅបានចូលរួមបុណ្យអភិបូជានៅទីនេះ។

លោកបញ្ជាក់ទៀតថា ព្រះវិហារថ្មីនេះគឺ ជាសញ្ញាមួយក្នុងការជួយយើងដើម្បីកសាងព្រះរាជ្យព្រះជាម្ចាស់ តាមរយៈគ្រីស្តបរិស័ទដែលកំពុងរស់នៅក្នុងភូមិពោធិ៍ធំនេះ។ លោកហ្គូស្តាវ៉ូ បានឲ្យដឹងទៀតថា ព្រះសហគមន៍នៅទីនេះមានសកម្មភាពជាច្រើនដើម្បីប្រកាសដំណឹងល្អ តាមរយៈសកម្មភាពយុវជន កុមារកាយឫទ្ធិ តាមរយៈគណៈកម្មការរបស់ព្រះសហគមន៍ដូចជា អប់រំជំនឿ សង្គហៈ និងពិធីបុណ្យ ដែលមានសកម្មភាពជាច្រើន។ លោកថា នៅពេលអនាគតព្រះសហគមន៍អាចគិតបន្ថែមសកម្មភាពពីរចំណុចទៀត ដើម្បីប្រកាសអំពីព្រះរាជ្យព្រះជាម្ចាស់គឺ គំរោងទាក់ទងទៅនឹងសេវាកម្មនៃការរៀនគួរបន្ថែមរបស់កុមារនៅទីនេះ ដោយអាចជួលគ្រូមកបង្រៀនផ្ទាល់នៅក្នុងព្រះសហគមន៍។ គំរោងមួយទៀត គឺបង្កើតឲ្យមានកម្មវិធីកាត់ដេរសម្រាប់ស្ត្រី។

*ដោយដាលីស*

# បេក្ខជនបេក្ខនារីចំនួន១២៨នាក់ នៅភូមិភាគភ្នំពេញ ទទួលពិធីត្រាស់ហៅយ៉ាងឱឡារិក

"អបអរសាទរដល់បងប្អូនដែលទទួលជីវិតថ្មី និងជាព្រះកាយព្រះគ្រីស្តរួមជាមួយយើងទាំងអស់។ នេះជាអំណរសប្បាយដែលយើងមាន ប៉ុន្តែដើម្បីទទួលអំណរសប្បាយនេះយើងត្រូវការចូលទៅក្នុងរដូវសែសិបថ្ងៃបន្តិចម្តងៗដើម្បីរួមជាមួយព្រះយេស៊ូដើម្បីក្លាយទៅជាព្រះកាយព្រះគ្រីស្តក្នុងពិភពលោកទាំងមូលនៅក្នុងសង្គមរបស់យើងជានិច្ច"។ នេះគឺជាប្រសាសន៍របស់លោកអភិបាលភូមិភាគភ្នំពេញនៅក្នុងឱកាសពិធីត្រាស់ហៅយ៉ាងឱឡារិក បេក្ខជនបេក្ខនារីចំនួន១២៨នាក់ ឲ្យរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលបុណ្យចម្លងខាងមុខនេះ។ បេក្ខជនបេក្ខនារីទាំងនោះមកពីមណ្ឌលសកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ពិធីត្រាស់ហៅយ៉ាងឱឡារិកនេះរៀបចំឡើងនៅព្រះវិហារសន្តប៉ូល និងសន្តសិលានៃមណ្ឌលសកម្មភាពភ្នំពេញថ្មីក្នុងសង្កាត់ភ្នំពេញថ្មីខណ្ឌសែនសុខរាជធានីភ្នំពេញក្រោមអធិបតីភាពលោកអូលីវីយេផ្មីតហស្មែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញលោកបូជាចារ្យក្នុងភូមិភាគបងប្រុសបងស្រីព្រមជាមួយបងធម៌រួម និងបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

ក្នុងពិធីនោះលោកអភិបាលបានមានលើកឡើងថា ថ្ងៃនេះជាថ្ងៃអាទិត្យទីមួយនៅក្នុងរដូវអប់រំពិសេសជាពេលវេលារបស់លោកអភិបាលត្រូវធ្វើពិធីត្រាស់ហៅយ៉ាងឱឡារិកសម្រាប់បេក្ខជនបេក្ខនារីឲ្យត្រៀមខ្លួនទទួលពិធីជ្រមុជទឹកនៅក្នុងឱកាសបុណ្យចម្លងនាពេលខាងមុខ។ សម្រាប់ពួកគេជាបេក្ខជនដែលត្រៀមទទួលពិធីជ្រមុជទឹកបានរៀបចំខ្លួនអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ក្នុងការដើរតាមព្រះយេស៊ូដោយមានអ្នកខ្លះ៣ឆ្នាំ ខ្លះ៥ឆ្នាំ ដែលមកពីមណ្ឌលសកម្មភាពចំនួន៨ក្នុងភូមិភាគភ្នំពេញដែលសុំទទួលពិធីជ្រមុជទឹក។

លោកអភិបាលបញ្ជាក់ថា នៅថ្ងៃនេះដែរគឺជាអំណរសប្បាយសម្រាប់ព្រះសហគមន៍ទាំងមូល ហើយក៏ជាអំណរសប្បាយសម្រាប់ពួកគេផងដែរដោយសារពួកគេបានឃើញនិងបានដើរ តាមព្រះយេស៊ូយូរហើយ គេស្គាល់ព្រះសហគមន៍យូរហើយប៉ុន្តែឥឡូវនេះពិតមែនពួកគេនឹងត្រូវទទួលអគ្គសញ្ញាជ្រមុជទឹកនៅយប់ថ្ងៃបុណ្យចម្លងខាងមុខនេះ។

តាមក្បួនអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិកក្នុងរដូវអប់រំពិសេសនេះ បងប្អូនទាំងនេះនឹងទទួលពីធីផ្សេងៗក្នុងអាទិត្យក្នុងនីមួយៗ មានពិធីជំរះចិត្ត៣ដង ពិធីទទួលធម៌ជឿ និងពិធីទទួលធម៌ឱព្រះបិតាជាដើម។

លោកអភិបាលក៏បានមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទថា រដូវ៤០ថ្ងៃសម្រាប់យើងទាំងអស់គ្នា ដែលមកពីមណ្ឌលសកម្មភាពនីមួយៗ ដោយបានទទួលបេក្ខជនថ្មីៗទាំងនេះទៅជាពេលវេលាពិសេស គឺការអប់រំពិសេសសម្រាប់យើងទាំងអស់។ ពេលខាងមុខនេះយើងចូលនៅក្នុងដំណាក់កាលនីមួយៗជាមួយបេក្ខជន ដោយមានពិធីជម្រះចិត្តគំនិតទីមួយ ពិធីជម្រះចិត្តគំនិតទីពីរ ពិធីជម្រះចិត្តគំនិតទីបី និងក្រោយមកប្រគល់ធម៌ប្រកាសជំនឿឲ្យបេក្ខជន និងមួយសប្តាហ៍បន្ទាប់ទៀត គឺប្រកាសជំនឿរបស់គេ។ ពិតមែនយើងជឿលើព្រះជាម្ចាស់ដែលជាព្រះបិតាព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធពិតមែន យើងជឿលើព្រះសហគមន៍កាតូលិកលើជីវិតអស់កាលជានិច្ច លើការលើកលែងទោសរបស់ព្រះជាម្ចាស់។ នេះជាឱកាសមួយសម្រាប់យើងជាគ្រីស្តបរិស័ទដើម្បីភ្ញាក់ស្មារតីម្តងទៀតដោយខិតខំជម្រះចិត្តគំនិតរបស់យើងម្តងបន្តិចៗខិតខំប្រកាសជំនឿរបស់យើងម្តងទៀត និងក្រោយមកយើងប្រគល់ធម៌ឱព្រះបិតាឲ្យនឹកឃើញពិតមែនខ្ញុំជាបុត្រធីតារបស់ព្រះជាម្ចាស់។

លោកអភិបាលបន្ថែមថា ឆ្នាំនេះថ្ងៃសុក្រពិសិដ្ឋគឺត្រូវថ្ងៃចូលឆ្នាំខ្មែរទីមួយជាឱកាសមួយ ដើម្បីប្រកាសថាពិតមែនខ្ញុំជាគ្រីស្តបរិស័ទ ទោះបីជាថ្ងៃទីមួយនៃពិធីចូលឆ្នាំដែលបងប្អូនមកជួបជុំគ្នាសប្បាយតែខ្ញុំចូលនៅក្នុងព្រះវិហារដើម្បីគោរពព្រះយេស៊ូដែលសោយទិវង្គត និងដើម្បីចូលរួមនៅក្នុងទុក្ខលំបាករបស់ព្រះយេស៊ូគ្រីស្ត ដើម្បីតមអាហារ និងធ្វើដំណើរជាមួយព្រះយេស៊ូយ៉ាងជិតស្និត។ យើងអាចនិយាយថា អាទិត្យពិសិដ្ឋ ឆ្នាំនេះគឺពិសេសថែមទៀតដែលណែនាំឲ្យយើងធ្វើជាមនុស្សដ៏វិសុទ្ធថែមទៀត ដោយសារយើងសុខចិត្តលះបង់ចោលដើម្បីបង្ហាញថា យើងជាសាវ័ករបស់ព្រះគ្រីស្ត។ ក្រោយមកយើងចូលនៅក្នុងអំណរសប្បាយនៃរាត្រីបុណ្យចម្លងឲ្យយើងម្នាក់ៗដែលជាគ្រីស្តបរិស័ទចូលរួមយប់បុណ្យចម្លងឲ្យបានច្រើនដើម្បីអបអរសាទរបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកដែលនឹងទទួលជីវិតថ្មីដែលទៅជាព្រះកាយព្រះគ្រីស្តរួមជាមួយយើងទាំងអស់គ្នា។

ក្រោយពីធម្មទេសនាលោកអភិបាលក៏បានសួរសំណួរមួយចំនួនទៅបេក្ខជនបេក្ខនារីអំពីគោលបំណង និងជំនឿរបស់គេ ព្រមទាំងបានត្រាស់ហៅតាមឈ្មោះគេម្នាក់ៗនៅមុខព្រះសហគមន៍យ៉ាងឱឡារិក ឲ្យចុះឈ្មោះក្នុងបញ្ជីព្រះសហគមន៍។

អ្នកស្រីលិន សីហា អាយុ៣៦ឆ្នាំ មកពីព្រះសហគមន៍សន្តយ៉ូសែប ជុំគីរី ខេត្តកំពត បានឲ្យដឹងថា សម្រាប់អ្នកស្រីពិតជាមានចិត្តរំភើបរីករាយជាខ្លាំងដែលបានទទួលការត្រាស់ហៅនាឱកាសនេះ។ អ្នកស្រីបានបញ្ជាក់អំពីជំនឿរបស់ខ្លួនថា ការក្លាយទៅជាបុត្រធីតារបស់ព្រះជាម្ចាស់តែងមានសេចក្តីសង្ឃឹមជានិច្ច។ ដូចនៅពេលដែលអ្នកស្រីបានចូលរួមជាមួយព្រះយេស៊ូដែលនាំឲ្យរូបអ្នកស្រីមានសេចក្តីស្រឡាញ់ និងចិត្តមេត្តាករុណាចំពោះអ្នកដទៃ។ ម៉្យាងទៀតមានអំណរដោយសារបានចូលរួមជាមួយព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។

ជាជនពិការជើងទាំងពីរអង្គុយនៅលើរទេះរុញយុវជនប្រាច់ ចិន អាយុ២៦ឆ្នាំ មកពីមណ្ឌលសកម្មភាពតាខ្មៅបានឲ្យដឹងថា រូបប្អូនផ្ទាល់នៅថ្ងៃនេះ ពិតជាមានចិត្តរំភើបណាស់ដែលបានចូលរួម និងទទួលពិធីត្រាស់ហៅក្នុងថ្ងៃនេះ។ប្អូនប្រុសជឿថា ព្រះជាម្ចាស់បានដឹកនាំផ្លូវជីវិតរបស់ប្អូនឲ្យដើរតាមផ្លូវល្អ និងនាំប្អូនឲ្យកែប្រែជីវិតថ្មី ជាពិសេសជួយប្អូនឲ្យគិតដល់ការយកចិត្តទុកដាក់យកអាសា និងជួយអ្នកដទៃព្រមទាំងការលើកលែងទោសឲ្យអ្នកដទៃជាដើម។

អ្នកស្រីចាន់ សុម៉ាឡា អាយុ២៨ឆ្នាំរស់នៅសង្កាត់ចោមចៅបានឲ្យដឹងថា ក្រោយពេលដែលអ្នកស្រីស្វែងយល់ជំនឿ អ្នកស្រីជឿថាអ្នកស្រីបានចូលរួមដំណើរជីវិតជាមួយព្រះយេស៊ូបានទទួលដំណឹងល្អដោយក្តីសង្ឃឹមទទួលបានជីវិតថ្មី។

ជាមួយគ្នានេះអ្នកស្រីបញ្ជាក់ថា នៅក្រោយពេលបានទទួលពិធីជ្រមុជទឹករួចអ្នកស្រី និងចូលរួមជាមួយកិច្ចការបំរើព្រះសហគមន៍នៅក្នុងការសម្តែងធម៌មេត្តាករុណាតាមរយៈសកម្មភាពផ្សេងៗដែលព្រះសហគមន៍មាន។

ដោយឡែកសម្រាប់លោកតែ មុន្នីរតនា អាយុ៣៩ឆ្នាំ បានលើកឡើងថា លោកបានទទួលការអប់រំជំនឿពីព្រះសហគមន៍កាតូលិកដោយយល់ថា "ខ្ញុំជាមនុស្សមានបាបហើយត្រូវការប្រែចិត្តគំនិត"។ ទៅថ្ងៃអនាគតលោករតនាប្តេជ្ញាថា ប្រកាសដំណឹងល្អអំពីព្រះយេស៊ូនេះទៅដល់បងប្អូនឯទៀតៗ និងទៅដល់មិត្តភក្តិ ដើម្បីឲ្យពួកគេបានស្គាល់ព្រះយេស៊ូនិងស្គាល់នូវសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះអង្គ៕

*ដោយ ឡុង សម្ផស្ស*



*ថតដោយ លី សុវណ្ណា*

# ក្រុមគ្រីស្តបរិស័ទនៃព្រះសហគមន៍ចំណោម រួមជាមួយអ្នកភូមិ ប្រារព្ធពិធីប្រោះព្រំ សុំសេចក្តីសុខ



ថតដោយ Chorch Saven

បងប្អូនគ្រីស្តបរិស័ទនៃព្រះសហគមន៍ចំណោម ស្ថិតក្នុងឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ បានជួបជុំគ្នាប្រារព្ធពិធីថ្វាយអភិបូជា អរព្រះគុណព្រះជាម្ចាស់ សម្រាប់ភោគផលកសិកម្មក្នុងរដូវកាលនៃឆ្នាំកន្លងទៅ និងប្រារព្ធពិធីប្រោះព្រំទឹកព្រះពរក្នុងភូមិ ដើម្បីសុំសេចក្តីសុខសាន្តក្នុងភូមិ។

ពិធីនេះបានប្រារព្ធ នៅព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយមានវត្តមានដ៏ខ្ពង់ខ្ពស់ នៃលោកអភិបាល គីគេ អស់លោកបូជាចារ្យ នៅក្នុងភូមិភាគបាត់ដំបង បងប្រុសបងស្រី ព្រមទាំងបងប្អូនពុទ្ធបរិស័ទជាអ្នកភូមិទាំងមូល។

ថ្លែងនៅក្នុងពិធីថ្វាយអភិបូជានាឱកាសនោះ លោក គីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា អត្ថបទព្រះគម្ពីរដែលយើងទាំងអស់គ្នាបានស្តាប់នេះ គឺព្រះយេស៊ូបានបង្ហាញនូវជំរើសសម្រាប់យើងម្នាក់ៗ នៅក្នុងការប្រតិបត្តិខ្លួន ដោយរក្សាជំនឿសម្រាប់ជីវិតរស់នៅ។ តើយើងម្នាក់ៗចង់ក្លាយទៅជាគ្រាប់ពូជ បែបណា ជាគ្រាប់ពូជដែលធ្លាក់នៅលើដីមានជីជាតិល្អ ធ្លាក់ទៅលើដីមានបន្លា ដីមានថ្ម ឬជាគ្រាប់ពូជធ្លាក់ទៅលើផ្លូវ? ពេលយើងបានស្តាប់ព្រះបន្ទូលនេះហើយ ចូរយើងរិះគិត ហើយអនុវត្តតាមព្រះបន្ទូល ដោយផ្តល់សេចក្តីស្រឡាញ់ឲ្យគ្នាទៅវិញទៅមក ប្រព្រឹត្តិអំពើល្អ មានទំនាក់ទំនងល្អរវាងគ្នានិងគ្នា ជាពិសេសទំនាក់ទំនងជាមួយបងប្អូន នៅក្នុងភូមិរបស់យើង និងបងប្អូនដែលកាន់សាសនាដទៃ។

លោកអភិបាលបន្តទៀតថា ក្នុងជីវិតរស់នៅរបស់យើងម្នាក់ៗជាគ្រីស្តបរិស័ទ យើងត្រូវចេះរួបរួមគ្នា ដោយមានការសាមគ្គីគ្នា និងផ្តល់សេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ដើម្បីជួយឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូ បង្កើតបានជាផលផ្លែល្អ នៅក្នុងជីវិតរបស់យើង គឺប្រៀបដូចជាគ្រាប់ពូជធ្លាក់ទៅលើដី ដែលមានជីជាតិល្អ ដោយបង្កើតបានផលមួយជាសែសិប មួយជាហុកសិប និងមួយជាមួយរយជាដើម។

លោកយ៉េង យ៉ាត ជាសមាជិកគណៈកម្មការនៃព្រះសហគមន៍កាតូលិកចំណោម បានឲ្យដឹងថា ពិធីបុណ្យនេះ គឺតែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដែលគិតរហូតមកដល់ពេលនេះ គឺយើងរៀបចំធ្វើឡើងអស់រយៈពេល ១៥ឆ្នាំកន្លងមកហើយ។ ពិធីប្រោះព្រំភូមិ នេះមានការដង្ហែដែលនាំមុខក្បួនដោយក្រុមឆៃយ៉ាំ ក្រុមយុវជន ក្រុមលោកបូជាចារ្យ និងគ្រីស្តបរិស័ទ។

ការរៀបចំពិធីនេះឡើងនៅក្នុង គោលបំណងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រទានពរ និងអរព្រះគុណព្រះជាម្ចាស់ ក្នុងឱកាសរដូវប្រមូលភោគផលនាឆ្នាំនេះ។ ហើយពិធីនេះរៀបចំឡើងដើម្បីរួបរួមគ្នារវាងបងប្អូនទាំងគ្រីស្តបរិស័ទ និងបងប្អូនពុទ្ធបរិស័ទនៅក្នុងភូមិ ដើម្បីអធិដ្ឋានសុំសុខសន្តិភាព សុវត្ថិភាព សម្រាប់ភូមិរបស់យើងទាំងមូល ដោយមិនមានការប្រកាន់សាសនា ឬពូជសាសន៍អ្វីឡើយ។

លោកយ៉េង យ៉ាត បានបញ្ជាក់ដោយសង្កត់ធ្ងន់ថា ពិធីបុណ្យភូមិនេះ មិនមែនរៀបចំឡើងសម្រាប់ តែព្រះសហគមន៍ចំណោមនោះទេ គឺប្រារព្ធធ្វើឡើងសម្រាប់បងប្អូនដែលរស់នៅក្នុងភូមិទាំងមូល នៅក្នុងអំណរសប្បាយ និងអរព្រះគុណព្រះជាម្ចាស់រួមជាមួយគ្នា។

សូមបញ្ជាក់ថា ពិធីបុណ្យភូមិនេះ បានរៀបចំឡើងដោយមានការថ្វាយអភិបូជា នៅក្នុងព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូចំណោម និងមានការប្រោះទឹកព្រះពរនៅតាមផ្ទះរបស់បងប្អូន ទាំងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ ដើម្បីសុំព្រះជាម្ចាស់ប្រទានភាពសុខសាន្តក្នុងគ្រប់ក្រុមគ្រួសារ។ ពិធីបុណ្យដូចនេះ ធ្លាប់ត្រូវបានប្រារព្ធធ្វើឡើងកាលពីសម័យដើម ក្នុងព្រះសហគមន៍ចំណោម ដែលអ្នកស្រុកហៅឈ្មោះថា ពិធីបុណ្យប្រទានព្រះពរដីស្រែក្នុងគោលបំណងប្រោះព្រំដីស្រែ និងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ភោគផលរបស់ពួកគេ ដែលជាព្រះអំណោយទាន របស់ព្រះជាម្ចាស់។ នេះបើតាមការបញ្ជាក់ប្រាប់ពីលោកយ៉េងយ៉ាត៕

*ដោយ ឡុង សម្ផស្ស*

# កិច្ចព្រមព្រៀង ( MOU ) រវាងវិទ្យាស្ថានសន្តប៉ូល និងសកលវិទ្យាល័យប៊ឺហ្គាមូ



ថតដោយ ដាលីស

វិទ្យាស្ថានសន្តប៉ូល និងសកលវិទ្យាល័យ ប៊ឺហ្គាមូ ( Bergamo ) នៃប្រទេសអ៊ីតាលី បានចុះអនុស្សារណៈ ( MOU ) ជាមួយគ្នា លើគម្រោងកម្មវិធីមានឈ្មោះថា ប្រទេសកំពុងអភិវឌ្ឍរួមសហការប្រទេសកំពុងអភិវឌ្ឍ ២០១៧-២០១៩ គឺរវាងប្រទេស តង់ហ្សានៀ និងប្រទេសកម្ពុជាលើការអប់រំ និងសង្គមកិច្ច។ ពិធីចុះហត្ថលេខានេះ បានប្រព្រឹត្តទៅនៅរសៀលថ្ងៃទី២២ កុម្ភៈ ២០១៧ នៅភ្នំពេញថ្មី។

លោកផុន សុផល ជាអ្នកទទួលខុសត្រូវផ្នែកទំនាក់ទំនងអន្តរជាតិ និងកិច្ចការងារសាធារណៈ នៅវិទ្យាស្ថានសន្ត ប៉ូល និងជានាយកប្រត្តិបត្តិនៃការិយាល័យយុវជន និងកុមារនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានឲ្យដឹងថា ថ្ងៃនេះជាថ្ងៃពិសេសដោយវិទ្យាស្ថានសន្តប៉ូលបានចុះកិច្ចព្រមព្រៀងអនុសារណៈយោគយល់គ្នា ជាពិសេសគឺការជ្រើសរើសនិស្សិតទៅចុះកម្មសិក្សានៅប្រទេសតង់ហ្សានៀ និងប្រទេសអ៊ីតាលី។ លោកបន្តថា នៅក្នុងកិច្ចព្រមព្រៀងរវាងសកលវិទ្យាល័យប៊ឺហ្គាម៉ូ និងវិទ្យាស្ថានសន្តប៉ូល គឺបានសម្រេចចិត្តយល់ព្រមផ្ញើនិស្សិតផ្នែកសង្គមកិច្ចទៅប្រទេសតង់ហ្សានៀនៅអាហ្វ្រិក ដើម្បីស្វែងយល់ពីសង្គមកិច្ចនៅប្រទេសតង់ហ្សានៀ និងស្វែងយល់អំពីស្ថានភាពសង្គមកិច្ចនៅប្រទេសអ៊ីតាលី។

អ្នកទទួលខុសត្រូវរូបនេះបានបន្ថែមថា គម្រោងនេះ គឺធ្វើដូចម្តេចដើម្បីឲ្យយុវនិស្សិតនៅប្រទេសកម្ពុជាមានការអភិវឌ្ឍក្លាយទៅជាប្រជាពលរដ្ឋដ៏ល្អ និងយល់អំពីតម្លៃនៃជីវិតជាពិសេស គឺតម្លៃនៃការសិក្សា។

លោក សុផល បានបង្ហើបឲ្យដឹងពីគម្រោងនេះទៀតថា ពីថ្ងៃទី១ ដល់ទី២០ ខែឧសភា ឆ្នាំ២០១៧ និស្សិតចំនួនបួននាក់ រួមជាមួយសាស្ត្រាចារ្យពីរនាក់ នៃវិទ្យាស្ថានសន្តប៉ូល នឹងទៅសិក្សានៅប្រទេសតង់ហ្សានៀ។ ឆ្នាំ២០១៨ និស្សិត និងសាស្ត្រាចារ្យ នៃប្រទេសតង់ហ្សានៀមកសិក្សានៅវិទ្យាស្ថានសន្តប៉ូល ប្រទេសកម្ពុជា។ ឆ្នាំ២០១៩ និស្សិតនៃប្រទេសទាំងពីរខាងលើ នឹងទៅទស្សនកិច្ចរួមគ្នានៅប្រទេសអ៊ីតាលី រយៈពេលបីសប្តាហ៍ ដើម្បីចែកបទពិសោធន៍ និងសិក្សាស្រាវជ្រាវ អំពីសង្គមកិច្ច និងយុត្តិធម៌សង្គម។

សម្រាប់រូបលោកផ្ទាល់ កិច្ចព្រមព្រៀងនេះគឺមានសារៈសំខាន់ក្នុងការជួយដល់និស្សិតខ្មែរ ជាពិសេសនៅវិទ្យាស្ថានសន្តប៉ូល ដើម្បីឲ្យនិស្សិតផ្នែកសង្គមកិច្ច ក៏ជានិស្សិតផ្សេងទៀតមើលឃើញអំពីកិច្ចសហប្រត្តិបត្តិការអន្តរជាតិរបស់សាលាសន្តប៉ូល ជាពិសេសតាមរយៈលោកអភិបាលអូលីវីយេ ដែលតែងតែមានបណ្តាញទំនាក់ទំនងអន្តរជាតិច្រើន និងយើងពង្រឹងសហប្រតិបត្តិការនេះ តាមការងារផ្សេងៗ ដើម្បីជួយដល់និស្សិត ជាពិសេសគឺនិស្សិតក្រីក្រដែលពួកគាត់អត់មានឱកាស ក្នុងការស្វែងយល់ពីស្ថានភាពនៅតាមបណ្តាប្រទេសដទៃផ្សេងទៀត។

*ដោយដាលីស*

# លោកសិលា រស់ អេន(១៩៤០-១៩៧៧)

## Mr. Pierre ROS EN

## ជាគ្រហស្ថ ជួយការងារព្រះសហគមន៍



លោកជាគ្រហស្ថម្នាក់។ លោកកើតនៅឆ្នាំ ១៩៤០ នៅក្នុងភូមិកំពង់គ។ គាត់មានបងប្អូន ៩នាក់ ប្រុស ៥ ស្រី៤។ រស់ អេនជា កូនទី១។

ពេលលោកនៅក្មេងៗ លោកចូលចិត្តទៅព្រះវិហារ ដែលតែងតែថ្វាយអភិបូជាម៉ោង ៥ភ្លឺ។ ពេលនៅក្មេង លោកមិនមែនជាមនុស្សពិបាកនិយាយគ្នាទេ។

លោកពុករ៉ឺណេ បញ្ជូនលោកទៅរៀននៅក្នុងអនុទេវវិទ្យាល័យ( Petite seminair ) នៅផ្សារតូច រហូតដល់ចូលទេវវិទ្យាល័យ ( grandeseminair ) ។

រាល់ពេលវាកង់ពីការសិក្សានៅអនុទេវវិទ្យាល័យ លោកមកផ្ទះវិញ ជួយបង្រៀនអប់រំជំនឿដល់យុវជន។ លោកជាមនុស្សស្លូតបូត មិនចេះផឹកស្រា លេងល្បែង ឬជក់បារីទេ។ លោកជាមនុស្សសាមញ្ញ រួសរាយ អត់មាត់ក ទៅរកអ្នកដ៏ទៃ។ "រាល់ពេលលោកមកផ្ទះម្តងៗ លោកតែងតែទៅសួរសុខទុក្ខអ្នកក្នុងភូមិ ឬទៅជួយធ្វើការអ្នកក្នុងភូមិ ដូចជាជួយធ្វើរបងផ្ទះ ឬសាងសង់ផ្ទះអ្នកភូមិជាដើម។ ក្រៅពីនោះទៀត លោកបានជួយធ្វើការងារព្រះវិហារដូចជា ហាត់ចម្រៀង រៀបចំកម្មវិធីបុណ្យធំៗ"។

លោកបានសម្រេចចិត្តជំរាបលោកពុករ៉ឺណេហើយ ចេញពីទេវវិទ្យាល័យ។ ក្រោយមកលោកធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រហែលជាបីឆ្នាំ ក្រោយមក លោករៀបការ និងមានកូនបីនាក់។

លោកធ្វើទាហានតាមច្បាប់រដ្ឋមួយរយៈ។ នៅឆ្នាំ ១៩៦៣-១៩៦៤ លោកត្រឡប់មករស់នៅក្នុង ភូមិកំពង់គវិញ ដើម្បីធ្វើជាគ្រូបង្រៀនក្នុងភូមិ និងនៅសាលារៀនរដ្ឋ។ កូនសិស្ស និងអណាព្យាបាលចូលចិត្ត និងរាប់អានលោកណាស់។

នៅឆ្នាំ១៩៧០ លោកទទួលការតែងតាំងជាប្រធានផ្នែកសាកសួរចម្លើយ ប៉ុន្តែមិនដែលឮថាលោកធ្វើបាបមនុស្សណាសោះ។ លោកមានចិត្តក្លាហានបង្ហាញជំនឿរបស់លោកមុខសាធារណៈ។ លោក "ជាអ្នកទទួលបន្ទុកក្រុមគ្រីស្តបរិស័ទ នៅជ្រោយចង្វារ ដែលជាផ្នែកមួយរបស់ទីក្រុងភ្នំពេញ"។

នៅខែឧសភា ឆ្នាំ១៩៧៥ អ្នកក្រុងភ្នំពេញទាំងអស់ត្រូវជម្លៀសចេញ។ លោកខិតខំទៅដល់ខេត្តកំពង់ធំ។ ពេលលោកមកដល់ស្ពានមួយនៅកំពង់ថ្ម លោកត្រូវខ្មែរក្រហមអញ្ជើញចូលរួម"ប្រជុំ"។ មានមិត្តភ័ក្រ្តម្នាក់ជាមិត្តរួមថ្នាក់បានសួរលោក ហើយលោកឆ្លើយថា លោកជាគ្រីស្តបរិស័ទ និងជាគ្រូបង្រៀន។ នាងណារី ជាភរិយារបស់លោក ដែលជាគ្រីស្តបរិស័ទថ្មី និងជាគ្រូបង្រៀនក៏ឆ្លើយដូចគ្នាដែរ។ នៅពេលល្ងាច គ្រួសាររបស់លោកទាំងអស់ត្រូវអញ្ជើញទៅអង្គុយក្នុងឡានធំ ដើម្បីយកទៅ "សិក្សា" ហើយព្រឹកស្អែកឡើង ទាហានខ្មែរក្រហមធ្វើទារុណកម្មចែកខារអោវឲ្យក្រុមគ្រួសាររបស់ពួកគេទាំងអស់។

លោកទទួលមរណភាពជាមួយអ្នកកំពង់គប្រហែលជាឆ្នាំ ១៩៧៧។



សន្ត អ៊ីសាក យ៉ូក

លោកអ៊ីសាក យ៉ូក កើតនៅប្រទេសបារាំងនៅឆ្នាំ១៦០៧។ គាត់ជាសាស្ត្រាចារ្យបង្រៀន អក្សរសិល្ប៍ តែគាត់ឈប់ដើម្បីចូលបួសធ្វើជាសមាជិកក្រុមគ្រួសារសហជីវិនព្រះយេស៊ូ។ គេបញ្ជូនគាត់ទៅប្រទេសកាណាដា នៅក្នុងចំណោមជនស្បែកក្រហម។ លោកឪពុក អ៊ីសាក និងសហការីរបស់គាត់រងទុក្ខលំបាកគ្រប់យ៉ាង ហើយទទួលរងគ្រោះថ្នាក់ដល់ជីវិតជារៀងរាល់ថ្ងៃដែរ។ ថ្ងៃមួយខណៈដែលគាត់កំពុងធ្វើដំណើរទៅរកអាហារនិងថ្នាំ ជនស្បែកក្រហមចាប់គាត់ និងសហការីរបស់គាត់ ហើយធ្វើទារុណកម្មដល់ពួកគេ។ ក្រោយមក គាត់រត់គេចខ្លួន ហើយត្រឡប់មកប្រទេសបារាំងវិញ។ គេបានកាត់ កិន ឬដុតម្រាមដៃគាត់។ សម្តេចប៉ាបបានអនុញ្ញាតឲ្យគាត់ថ្វាយអភិបូជាដោយដៃពិការ ទាំងមានប្រសាសន៍ថា បូជាចារ្យម្នាក់ដែលបង្ហូរឈាមរបស់ខ្លួនចំពោះព្រះយេស៊ូជាគំរូសម្រាប់ខ្ញុំមែន។ ដោយសារតែគាត់មានចិត្តខ្នះខ្នែងចំពោះព្រះយេស៊ូខ្លាំងពេក លោកឪពុកអ៊ីសាកសម្រេចចិត្តត្រឡប់ទៅប្រទេសកាណាដាវិញ។ នៅទីនោះ គេចាប់គាត់ ធ្វើទារុណកម្មគាត់ម្តងទៀត អស់រយៈពេល ១៤ម៉ោង ហើយកាត់កគាត់នៅឆ្នាំ ១៦៤៦។ គាត់ និងសហការីរបស់គាត់ជាមរណសាក្សីដំបូងបង្អស់នៅអាមេរិកខាងជើង។




# គ្រោះថ្នាក់នៃគ្រឿងញៀន ចំពោះយុវវ័យបច្ចុប្បន្ន

បញ្ហាគ្រឿងញៀន នៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នពុំមែនជារឿងថ្មីនោះទេ។ គ្រឿងញៀន ជាបញ្ហាចម្បងសម្រាប់សង្គម អាណាព្យាបាលសិស្សនិស្សិត និងជាពិសេសរាជរដ្ឋាភិបាលកម្ពុជា។

គ្រឿងញៀនដែលមានការហូរចូលមកកម្ពុជា មានដូចជា មេតំហ្វេតាមីន កូការអ៊ីន ក្រោមរូបភាព ជាថ្នាំបង្កើនកម្លាំង សម្រាប់អ្នកធ្វើការងារធ្ងន់ និងអ្នកធ្វើការនៅពេលយប់ជាដើម ដែលបានវាយលុកខ្លាំងក្នុងស្រទាប់យុវវ័យជាពិសេស សិស្សសាលា អ្នកនេសាទ និងកម្មករសំណង់ជាដើម។

ការរាលដាលពាក់ព័ន្ធ និងគ្រឿងញៀន តាមរយៈឈ្មួញ ដែលបានបង្កើតបណ្តាញ នៅក្នុងសង្គមទាំងនៅទីក្រុងក៏ដូចជា នៅជនបទ ដែលពួកគេបានបញ្ចុះបញ្ចូល និងញុះញង់ថា ថ្នាំទាំងនេះធ្វើឲ្យសប្បាយ និងភ្លេចទុក្ខកង្វល់ជាដើម។

ឯកឧត្តម មាស វិទ្ធ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានថ្លែងដូចនេះថា ការរីករាលដាលនៃគ្រឿងញៀន ប៉ះពាល់ដល់យុវជនកម្ពុជា ដែលស្ថិតនៅចន្លោះ អាយុពី ១៨ទៅ៣៥ឆ្នាំ បាននឹងកំពុងក្លាយខ្លួនទៅជាអ្នករួមចំណែក ក្នុងការប្រើប្រាស់គ្រឿងញៀនផង និងមួយចំនួនក្លាយទៅជា អ្នកញៀនគ្រឿងញៀនផង។

ឯកឧត្តមបានបន្តថា មូលហេតុចម្បងដែលធ្វើឲ្យ ក្លាយខ្លួនទៅជាអ្នកញៀនគ្រឿងញៀន មាន២ គឺទី១ ភាពភ្លឹតភ្លើននៃយុវវ័យដែលចង់ដឹងចង់ស្គាល់នៃគ្រឿងញៀន ទី២ កង្វះខាតនៃមធ្យោបាយផ្សព្វផ្សាយអប់រំឲ្យបានស៊ីជម្រៅដល់បុគ្គល។

បើតាមការសិក្សាវេជ្ជសាស្ត្របានបង្ហាញថា គ្រឿងញៀនបណ្តាលឲ្យសាមីខ្លួនមានបញ្ហាទាក់ទងនិងអារម្មណ៍ផ្ទាល់របស់ពួកគេ ជាពិសេសពួកគេមានការអន់ចិត្តជាមួយក្រុមគ្រួសារ ឬមានអំពើហឹង្សាក្នុងគ្រួសារជាដើម ហើយក្នុងចំណោម អ្នកមានបញ្ហាផ្លូវចិត្ត។

លោកវេជ្ជបណ្ឌិត សោម កុសល បានថ្លែងថា មនុស្សប្រើប្រាស់គ្រឿងញៀន មកពីកត្តាខាងក្រៅ និងកត្តាខាងក្នុង។ កត្តាខាងក្រៅមានន័យថា បរិស្ថានខាងក្រៅជុំវិញអ្នកជម្ងឺ ទី១អ្នកដែលប្រើខ្លួនឯងកត្តាខាងក្រៅតាមរយៈអ្នកលក់គ្រឿងញៀន ដោយឃោសនាអូសទាញ ផលិតផលគ្រឿងញៀននេះឯង។

នៅក្នុងប្រទេសកម្ពុជាមាន គ្រឿងញៀន ២សំខាន់ៗ ដែលទី១គឺប្រភេទ យ៉ាម៉ា ដែលជាសារធាតុពិតរបស់មេតំហ្វេតាមីន ជាថ្នាំដែលធ្វើឲ្យខួរក្បាលកំរើក យ៉ាងសកម្មហើយប្រើយូរបណ្តាលឲ្យខូចប្រព័ន្ធខួរក្បាល និងមិនអាចព្យាបាលបាន។



Photo Supply

ទី២ គឺប្រភេទសុរា ដែលជាប្រភេទគ្រឿងញៀនម្យ៉ាងដែរ និងត្រូវបានប្រើប្រាស់ទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រី តែក្នុងករណីខ្លះគេសង្កេតឃើញមានយុវជនមួយចំនួនប្រើប្រាស់ លាយបញ្ចូលគ្នារវាងមេតំហ្វេតាមីន និងសុរាតែម្តង។

លោកវេជ្ជបណ្ឌិត សោម កុសល បានបន្ថែមថា ការប្រើប្រាស់គ្រឿងញៀន វាបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរខ្លាំងលើខួរក្បាល រូបរាងកាយ និងធ្វើឲ្យប្រព័ន្ធសរសៃប្រសាទ មានបញ្ហា ហើយវាអាចធ្វើឲ្យខួរក្បាលយើងចុះខ្សោយ ទាំងការគិត និងប្រាជ្ញាស្មារតី ក្នុងករណីធ្ងន់ធ្ងរ វាអាចធ្វើឲ្យដាច់សរសៃឈាមក្នុងខួរក្បាល ឬអាចស្លាប់ក្នុងករណីប្រើប្រាស់ក្នុងកម្រិតខ្ពស់។

យោងតាមបទបញ្ជា របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងយុទ្ធនាការ៦ខែ ក្នុងការបោសសម្អាតគ្រឿងញៀន ក្នុងប្រទេសកម្ពុជា ដែលមានសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានធ្វើការបង្ក្រាបបានជាង១០០០ករណី ទូទាំងផ្ទៃប្រទេស ក្នុងរយៈពេលជាង៣ខែកន្លងមកនេះ។

*ដោយ ផល សុផានិត*

# ជីវិតស្ត្រី រកស៊ីបម្រើការកម្សាន្ត ដែលត្រូវបានចាញ់បោក អតីតគូស្នេហ៍របស់ខ្លួន

ណាគ្រី ជាឈ្មោះមួយដែលអ្នកយកព័ត៌មានយើងខ្ញុំបានដាក់ឲ្យនាង នាងជានារី ដែលមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង នាងរស់នៅក្នុងស្ថានភាពក្រីក្រ។ ដោយសារមានការលួងលោមពីដៃគូជាសង្សាផងនោះ ធ្វើឲ្យណាគ្រីបានសម្រេចចិត្តចាកចេញពីស្រុកកំណើតមកធ្វើការក្នុងភោជនីយដ្ឋានមួយកន្លែងក្នុងរាជធានីភ្នំពេញ កាលពីនាងមានអាយុ ១៩ឆ្នាំ ប៉ុន្តែតាមពិតនាងត្រូវបានមេខ្យល់ បោកបញ្ឆោតយកមកលក់ឲ្យធ្វើជានារីបម្រើ ការកម្សាន្តនៅក្នុងផ្ទះបនមួយកន្លែង។

ណាគ្រីបានរៀបរាប់ប្រាប់ថា នាងពុំដែលបានស្គាល់បុរសនោះទេ ដោយគេបបួលដោយប្រាប់ម្តាយនាង ធ្វើការរត់តុនៅហាងម៉ាស្សា តែនាងពុំដែលបានដឹងទេ ដោយគេបានឲ្យនាងអង្គុយចាំ តែប៉ុណ្ណោះ ក៏ប៉ុន្តែនាងត្រូវបានគេយកមកលក់ ឲ្យធ្វើជានារីបម្រើការកម្សាន្ត ដោយនាងគ្រាន់គិតថា នាងគ្រាន់តែធ្វើការជាអ្នកម៉ាស្សាម្នាក់ប៉ុណ្ណោះ។



ថតដោយ រិទ្ធី

ណាគ្រី ត្រូវបានមេបនបង្ខំឲ្យរួមភេទជាមួយបុរសជាច្រើននាក់ក្នុងមួយថ្ងៃ។ ថ្ងៃមួយ ណាគ្រី សម្រេចចិត្តរត់ចេញពីផ្ទះបនបានសម្រេច ក៏ប៉ុន្តែនាងមិនត្រូវបានរួចផុតពីជីវិតនារី បម្រើការកម្សាន្តនោះទេ។

នាងត្រូវបានផ្លាស់ប្តូរពីនារីបម្រើការកម្សាន្តនៅក្នុងផ្ទះបន មកជានារីរកស៊ីបម្រើភ្ញៀវរបស់នាងដោយឯករាជ្យវិញម្តង។ មានន័យថានាង យកទីកន្លែងផ្សេងៗ ដូចជាតាមក្លឹបរាត្រី សួនច្បារសាធារណៈ ធ្វើជាកន្លែងទទួលអតិថិជនរបស់នាង។

ណាគ្រីបានបន្ថែមថា នាងតែងតែទទួលភ្ញៀវរបស់នាង ជាធម្មតារៀងរាល់ថ្ងៃ ដោយភ្ញៀវរបស់បានឲ្យតម្លៃខ្លួននាង ១០ដុល្លាសហរដ្ឋអាមេរិច ដោយនាងធ្វើបែបនេះអស់រយៈពេលជាង១០ឆ្នាំមកហើយ។

ណាគ្រីប្រកបរបរបែបនេះ អស់រយៈពេលជាច្រើនឆ្នាំ ទើបនាងសម្រេចចិត្តប្រាប់ការពិតពីការងារទៅដល់ម្តាយនាង។

នៅក្នុងជីវិតជានារីបម្រើការកម្សាន្ត នាងរកប្រាក់ចំណូលបានពី ១ម៉ឺនរៀលទៅ១៥០០០រៀលក្នុងមួយដង។ ដោយនាងអាចរកភ្ញៀវរបស់នាងបានចន្លោះពី ៥ ទៅ៦នាក់ក្នុងមួយថ្ងៃ។ បន្ថែមលើសពីនេះ ណាគ្រី បានបញ្ជាក់ថា មានភ្ញៀវខ្លះបានធ្វើការតិះដៀលនាង និងមានភ្ញៀវខ្លះមិនបានឲ្យលុយនាងទៀតផង។

ឆ្លងកាត់មុខរបរជានារីបម្រើការកម្សាន្តសម្រាប់បុរសនេះ ណាគ្រី បានបន្សល់កូន ២នាក់ ដោយគ្មានឪពុក ដោយកូនទាំង២នាក់នោះ ត្រូវបានទទួលការមើលថែពីជីដូន នៅឯស្រុកកំណើតរបស់នាង ហើយទទួលការសិក្សារៀនសូត្រ ដែលមានការឧបត្ថម្ភពី ម្តាយដែលជានារី ប្រកបរបរបម្រើការកម្សាន្ត។

អ្នកស្រីមាស សុធារី ដែលជាម្ចាស់បន្ទប់ជួលរបស់ណាគ្រី បានឲ្យដឹងថា ណាគ្រី ជាស្ត្រីដែលមានចរិតស្លូតបូត និងជាអ្នកជិតខាងល្អម្នាក់ផងដែរ។

បន្ទាប់បម្រើអតិថិជន នៅពេលថ្ងៃ ណាគ្រី ក៏ទៅបម្រើការងារក្នុងហាងខារ៉ាអូខេមួយ នៅពេលយប់ ដើម្បីផ្គត់ផ្គង់ជីវភាពរបស់នាង។

*ដោយ ផល សុផានិត*

# បុណ្យឆ្លងព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូនិងមជ្ឈមណ្ឌលសំណាក់ធម៌នៅព្រៃកប្បាស



ថតដោយ សម្បត្តិ

មនុស្សជាច្រើនរយនាក់មកពីព្រះសហគមន៍ផ្សេងៗគ្នាក្នុងភូមិភាគភ្នំពេញ បានមកជួបជុំគ្នាដើម្បីអបអរសាទរ ព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ និងមជ្ឈមណ្ឌលសំណាក់ធម៌នៅព្រៃកប្បាស នៅក្នុងខេត្តតាកែវ ក្រោមអធិបតីភាពលោកអូលីវីយេ ដ្មឹតអឺស្លែរ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងអាដ្ឋាធរភូមិឃុំ កាលពីថ្ងៃទី២៥ ខែកុម្ភៈ កន្លងទៅ។ ពេលចាប់ផ្តើមលោកបូជាចារ្យ ទទួលខុសត្រូវព្រះសហគមន៍ វង្សម៉ាសែន ហាតាផៃ (សាន់ដេ) បានស្វាគមន៍ភ្ញៀវទាំងអស់ បន្ទាប់មកក៏មានរបាំជូនពរ ហើយក្បួនដង្ហែបានចាប់ផ្តើមដោយមានចម្រៀងលើកតម្កើងព្រះជាម្ចាស់ ហែជុំវិញព្រះវិហារមួយជុំ។ នៅមុខព្រះវិហារ និងមុខគ្រីស្តបរិស័ទទាំងអស់លោកបូជាចារ្យ សាន់ដេ បានប្រកាសថា ព្រះវិហារនេះឈ្មោះថា សន្តីតេរេសា នៃព្រះកុមារយេស៊ូ។ បន្ទាប់មកលោកអភិបាលបានគូសសញ្ញាឈើឆ្កាងនៅមុខទ្វារព្រះវិហារ និងកាត់ខ្សែប្ញូរមជាមួយលោកបូជាចារ្យទទួលបន្ទុកមណ្ឌលសកម្មភាពតាកែវ និងលោកបូជាចារ្យសាន់ដេ រួចអញ្ជើញបងប្អូនទាំងអស់ឲ្យចូលមកក្នុងព្រះវិហារ ដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់។ លោកអូលីវីយេ បានប្រទានពរលើទឹក និងប្រោះទៅលើគ្រីស្តបរិស័ទ ដើម្បីរំឭកដល់អ្នកចូលរួមទាំងអស់អំពីអត្ថន័យនៃអគ្គសញ្ញាជ្រមុជទឹក ដែលបានណែនាំយើងឲ្យទៅប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ បន្ទាប់មកលោកអភិបាលប្រោសទឹកទៅលើជញ្ជាំងព្រះវិហារថ្មី ដែលជាសញ្ញានៃការលាងជម្រះឲ្យបានស្អាតបរិសុទ្ធថ្វាយព្រះអង្គ និងសាកសមនឹងធ្វើជាព្រះដំណាក់នៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ក្នុងធម្មទេសនា នៃកម្មវិធីបុណ្យនេះ លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា ព្រះវិហារនេះពិសេសដោយបងប្អូនបានចេញកម្លាំងសាងសង់ដោយផ្ទាល់ និងមានភាពកក់ក្តៅដែលនាំឲ្យយើងចេញចូលដោយអំណរសប្បាយ។ លោកបានបន្តថា ការដាក់ឈ្មោះសន្តីតេរេសានៃព្រះកុមារយេស៊ូជាឧបការីជននៃព្រះវិហារនេះ គឺនាំឲ្យយើងយល់ថា ជីវិតរបស់យើងត្រូវពឹងផ្អែកលើព្រះជាម្ចាស់ដូចសន្តីដែរ។ លោកអភិបាលក៏បានបញ្ជាក់អំពីអត្ថន័យនៃព្រះវិហារថា ព្រះវិហារ គឺជាកន្លែងដែលយើងអធិដ្ឋានលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងស្តាប់ព្រះបន្ទូលដែលនាំឲ្យយើងទៅជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គតាមរយៈអគ្គសញ្ញាជ្រមុជទឹក។ លោកអូលីវីយេ ក៏បានសំណូមពរថា សូមឲ្យកន្លែងនេះទៅជាពូជ និងជាកន្លែងមួយដែលណែនាំបងប្អូនឯទៀតៗឲ្យរកឃើញពន្លឺនៃជីវិត គឺយល់ពីតម្លៃជីវិតរបស់យើង ព្រោះនៅជុំវិញយើងមានមនុស្សគ្រប់ប្រភេទដែលកំពុងអស់សង្ឃឹម។ លោកបន្ថែមទៀតថា ដូចនេះសូមធ្វើដូចម្តេចដើម្បីឲ្យកន្លែងនេះទៅជាកន្លែងដែលផ្តល់ក្តីសង្ឃឹមដល់បងប្អូនដែលចេញចូលទីនេះ។ ជាចុងក្រោយលោកអភិបាលក៏បានក្រើនរំឭកផងដែរ អំពីបេសកកម្មរបស់គ្រីស្តបរិស័ទ គឺធ្វើជាពន្លឺ និងជាអំបិល ជាពន្លឺដែលលាក់មិនបានគឺណែនាំបងប្អូនទាំងអស់ឲ្យមើលឃើញពីវត្តមានរបស់ព្រះជាម្ចាស់។ លោកក៏បានរំឭកដល់លោកបូជាចារ្យសាន់ដេ ដើម្បីអភិវឌ្ឍទីនោះឲ្យក្លាយជាមជ្ឈមណ្ឌលសំណាក់ធម៌យ៉ាងសកម្ម។ សម្រាប់ភូមិភាគភ្នំពេញទាំងមូល លើការត្រៀមខ្លួនជានិច្ចដើម្បីទទួលស្វាគមន៍បងប្អូនទាំងអស់ដែលមកធ្វើសំណាក់ធម៌ និងសិក្ខាសាលានៅទីនេះ។ បន្ទាប់ពីធម្មទេសនា លោកអភិបាលបានបញ្ចុះធាតុសន្តីតេរេសានៃក្រុងកុលកូតា នៅក្នុងតុសក្ការៈ និងលាបប្រេងគ្រីស្មា លើតុសក្ការៈ ព្រមទាំងសរសរព្រះវិហារ។ ព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ នៅភូមិព្រៃកប្បាស បានសាងសង់រួចរាល់ក្នុងឆ្នាំ២០១៣ ដោយទទួលបានការឧបត្ថម្ភ ពីបុរសវ័យចំណាស់ជនជាតិបារាំងម្នាក់នូវទឹកប្រាក់ចំនួនមួយម៉ឺនដុល្លាអាមេរិក តាមរយៈលោកអភិបាលអូលីវីយេ។ តាមការរៀបរាប់របស់លោកអភិបាលព្រះវិហារនេះ បានសាងសង់ឡើងដោយផ្ទាល់ដៃរបស់គ្រីស្តបរិស័ទនៅទីនេះ ជញ្ជាំងព្រះវិហារនេះ គឺសង់ឡើងពីអង្កាមចំបើង និងដីឥដ្ឋ ដំបូលប្រក់ស្បូវ យើងអាចនិយាយបានថា ជាព្រះវិហារប្លែកពីព្រះវិហារផ្សេងៗ។ ព្រះសហគមន៍កាតូលិកព្រៃកប្បាស បានកើតឡើងដោយ គ្រីស្តបរិស័ទម្នាក់ដែលបានឃើញគំរូដ៏ល្អរបស់សន្តយ៉ូហាន បូស្កូ ក្នុងអំឡុងពេលគាត់រៀន និងបង្រៀននៅសាលាបច្ចេកទេស ដុនបូស្កូនៅភ្នំពេញថ្មី រួមជាមួយការយកចិត្តទុកដាក់របស់ព្រះសហគមន៍។ ពេលត្រឡប់ទៅស្រុកកំណើតលោក បានខិតខំប្រកាសដំណឹងល្អតាមរយៈការរស់នៅផ្ទាល់របស់លោក។ បច្ចុប្បន្នព្រះសហគមន៍នេះមានគ្រីស្តបរិស័ទចំនួន២៤នាក់ និងបេក្ខជនដែលត្រៀមទទួលដំហាន ទី២ខាងមុខនេះចំនួន១១នាក់។ ក្រៅពីសកម្មភាពនៃគណៈកម្មការសំខាន់ៗទាំងបី នៅក្នុងព្រះវិហារ និងមជ្ឈមណ្ឌលសំណាក់ធម៌ ព្រះសហគមន៍ព្រៃកប្បាសក៏មានសកម្មភាពជាច្រើនដូចជា សាលាមត្តេយ្យ ក្រុមកុមារកាយឫទ្ធិ និងក្រុមយុវជន។

*ដោយដាលីស*

# សម្តេចប៉ាប ប្រាប់លោកបូជាចារ្យថា គួរតែជំរុញការគាំទ្រដល់ពិធីរៀបអាពាហ៍ពិពាហ៍

កាលពីថ្ងៃអាទិត្យ វិទ្យុវាទីកង់បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានជួបពិភាក្សា ជាមួយនឹងលោកបូជាចារ្យមួយចំនួន ហើយនៅក្នុងពេលនោះ បានជំរុញឲ្យបណ្តាលលោកបូជាចារ្យនៅក្នុងព្រះសហគមន៍កាតូលិកទាំងអស់ លើកទឹកចិត្ត និងគាំទ្រដល់ពិធីរៀបអាពាហ៍-ពិពាហ៍។

ថ្លែងនៅពេលដែលជួបសាវនាការជាមួយនឹងអស់លោកបូជាចារ្យដែលបានមកចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងទម្រង់នៃការបដិសេធចំណងអាពាហ៍ពិពាហ៍ និងទម្រង់ច្បាប់នានា ជុំវិញពិធីអាពាហ៍ពិពាហ៍ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានលើកឡើងថា ពិធីអាពាហ៍ពិពាហ៍គឺសំខាន់ណាស់ ហើយព្រះសហគមន៍តម្រូវឲ្យមានការសិក្សាស្វែងយល់ឲ្យច្បាស់លាស់ប៉ុន្តែអស់លោកបូជា-ចារ្យត្រូវតែគាំពារ និងលោកទឹកចិត្តដើម្បីធ្វើយ៉ាងណាជួយគ្រីស្តបរិស័ទរៀបចំពិធីដ៏មានអត្ថន័យនេះប្រកបដោយជោគជ័យ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា លោកបូជាចារ្យទាំងឡាយ គឺជាអ្នកដែលប្រាស្រ័យដោយផ្ទាល់ជាមួយនឹងគ្រីស្តបរិ-ស័ទ ដូច្នេះគួរតែមានការលើកទឹកចិត្តឲ្យមានអាពាហ៍ពិពាហ៍មួយ ដែលទទួលបាននូវភាពសមស្របតាមនិយមន័យនៃព្រះសហគមន៍។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា លោកបូជាចារ្យ គឺជាអ្នកដែលមានទំនាក់ទំនងដំបូងនិង ផ្ទាល់ជាមួយនឹងយុវជន ដូច្នេះការអប់រំយុវជនឲ្យមានការសម្រេចចិត្តទទួលយកអាពាហ៍ពិពាហ៍មួយត្រឹមត្រូវមានគោលដៅច្បាស់លាស នៅក្នុងការបង្កើតគ្រួសារ គឺសំខាន់ណាស់។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ការយល់ដឹងរបស់យុវជនជុំវិញអត្ត-សញ្ញាអាពាហ៍ពិពាហ៍ គឺត្រូវតែចំណុចដែលគួរតែយកចិត្តទុកដាក់។

គួររំលឹកថា ការបណ្តុះបណ្តាលចំណុចនេះ គឺបានប្រព្រឹត្តទៅនៅស្ថាប័នតុលាការរ៉ូម៉ាំង រ៉ូតា ដែលជាសាលាឧទ្ធរណ៍នៃព្រះសហគមន៍កាតូលិក។

# សម្តេចប៉ាបនៅក្នុងអង្គនៃព្រះជា-ម្ចាស់ គឺមានតែយុត្តិធម៌ និងមេត្តាករុណា

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងកាលពីពេលថ្មីៗនេះថានៅក្នុងខ្លួននៃអង្គព្រះជាម្ចាស់គឺមានតែយុត្តិធម៌និងមេត្តាករុណា។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងជាសារនៅក្នុងពិធីថ្វាយអភិបូជានៅវិសាលវិហារ ខាសា សានតា ម៉ាថា កាលពីពេលថ្មីៗនេះថា ព្រះយេស៊ូបានបង្រៀនយើងថា សេចក្តីពិត ដែលគ្មានការល្អៀង និងវៀចវេ គឺជាដំណើរដ៏វែងឆ្ងាយនៃព្រះគ្រីស្ត ដូច្នេះ ជាគ្រិស្តបរិស័ទ គឺត្រូវតែមានយុត្តិធម៌និងមានសេចក្តីករុណា។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ព្រះយេស៊ូ ព្រះអង្គមិនដែលផ្តល់នូវការសម្រេចនូវការសម្រេចតក្កភាពណាមួយនោះទេ ប៉ុន្តែព្រះអង្គតែងតែពន្យល់អំពីសេចក្តីពិត ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា មានសំនួរផ្ទាញ់ផ្ទាលទ្រង់ច្រើន ប៉ុន្តែចម្លើយដែលទ្រង់ ផ្តល់ឲ្យគឺ សេចក្តីពិត មេត្តាករុណា និងការលើកលែងទោស។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ព្រះអង្គមិនដែលផ្តល់នូវចម្លើយដែលថា ទេ ហើយក៏មិនផ្តល់ចម្លើយដែលថា បាទ ប៉ុន្តែជាសេចក្តីពន្យល់ឲ្យមនុស្សយល់អំពីសេចក្តីពិត។

# សម្តេចប៉ាបហ្វ្រង់ស៊ីស្កូជួបជាមួយនឹងក្រុមអ្នកស្ម័គ្រចិត្តបារាំង

តាមការរាយការណ៍របស់វិទ្យុវាទីកង់កាលពីសប្តាហ៍មុនថា សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានជួបសាវនាការជាមួយនឹងក្រុមអ្នកស្ម័គ្រចិត្តបារាំង ដោយនៅក្នុងឱកាសនោះ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានជំរុញពួកគេឲ្យជួយផ្សព្វផ្សាយ និងលើកកំពស់វប្បធម៌នៃសេចក្តីករុណា។

ប្រភពដដែលបានបន្តថា ជំនួបនេះគឺស្របនឹងពិធីរំលឹកខួបលើកទី ៥០ឆ្នាំនៃការបង្កើតមូលនិធិអ្នកស្ម័គ្រជនជាតិបារាំងនេះឡើង។

ប្រភពដដែលបានបន្តថា ទីភ្នាក់ងារបម្រោះស្ម័គ្រចិត្តអន្តរជាតិដែលដំណើរការដោយព្រះសហគមន៍កាតូលិកបារាំង គឺមានអ្នកស្ម័គ្រចិត្តនៅក្នុងប្រទេសសរុបជាង ៥០ប្រទេស នៅលើពិភពលោក ដោយពួកគេកំពុងតែធ្វើការប្រកបដោយសាម-គ្គីភាព និងមនុស្សធម៌ នៅក្រោមកិច្ចសហ-ការជាមួយនឹងព្រះសហគមន៍កាតូលិកនៅតាមមូលដ្ឋាន នៅក្នុងគម្រោងអភិវឌ្ឍន៍ជាច្រើន ។

នាឱកាសនោះសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងរំលឹកអំពីវប្បធម៌នៃសេចក្តីមេត្តាករុណា ហើយជំរុញនឹងដាស់តឿនពួកគេថា សូមកុំខ្លាចនឹងបេសកម្មទាំងនេះ។ ជាការពិតនេះជាបេសកម្មមួយដែលពិបាក ប៉ុន្តែសូមកុំរត់ចោលការទទួលខុសត្រូវ នេះគឺជាសេចក្តីសោកសង្រេងរបស់បងប្រុសបងស្រីយើងទាំងអស់គ្នា ប្រសិនបើយើងមិនរវីរវល់ទេនោះ។

# សម្តេចប៉ាបស្នើឲ្យព្រះសហគមន៍និងគ្រិស្តបរិស័ទបន្តយកចិត្តទុកដាក់នឹងជនពិការ

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា ការទុកឲ្យជនពិការរស់នៅដោយគ្មានការយកចិត្តទុកដាក់ គឺជារឿងដែលមិនអាចទទួលយកបាន។

ថ្លែងកាលពីថ្ងៃទី២៥ ខែកុម្ភៈ ដែលដកស្រង់សំដីដោយវិទ្យុវាទីកង់បានផ្សាយថា សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានជំរុញឲ្យគ្រីស្តបរិស័ទបន្តកិច្ចការ និងលើកទឹកចិត្តពួកគេឲ្យជួយជនពិការ និងមនុស្សដែលគេមិនរាប់រក។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានជំរុញបន្ថែមទៀតឲ្យអង្គការមួយដែលមានឈ្មោះថា កុមុយនីតា ឌី កាប៉ូដាកូ ត្រូវធ្វើការដើម្បីជួយដល់ជនពិការ និងបង្រួមគម្លាតរបស់ប្រជាពលរដ្ឋ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានរំឭកនូវកិច្ចការនេះ គឺដោយសារតែអង្គការនេះគឺជាអង្គការមួយដែលកើតពីសហគមន៍មួយនៅភាគខាងកើតនៃទីក្រុងហ្វ៊ូម៉ូ នៃប្រទេសអ៊ីតាលី កាលពីឆ្នាំ១៩៦៦។

អង្គការនេះមានបេសកម្មមួយ ដ៏មុតស្រួចនៅក្នុងព្រះសហគមន៍ គឺផ្តល់នូវសេវាកម្មស្តានិតិសម្បទាដល់ជនពិការទាំងឡាយ ដើម្បីឲ្យពួកគេទទួលបានឱកាសទទួលការងារធ្វើ និងអាចសម្របសម្រួលពួកគេទៅហ្នឹងសមាហរណកម្មសង្គមបាន។

ក្រោយមកអង្គការនេះបានពង្រីកសកម្មភាព និងបេសកម្មបន្ថែមទៀត រហូតជួយដល់កុមារ មនុស្សវ័យជំទង់ ជនតន្តោ-ប្រវេសន៍ ព្រមទាំងជនដែលញៀនគ្រឿងញៀន ក៏ដូចជាមានបញ្ហាផ្លូវចិត្តដោយរួមទាំងប្រជាជនដែលសង្គមមិនរាប់រកជាច្រើនទៀត។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានសំដែងនូវការគាំទ្រពួកគេ លើកទឹកចិត្តពួកគេដើម្បីធ្វើយ៉ាងណា ឲ្យពួកគេទទួលបាននូវជោគជ័យ និងសម្រេចបាននូវភារកិច្ចថ្មីៗរបស់ព្រះសហគមន៍កាតូលិក។

# សម្តេចប៉ាបលើកឡើងអំពីបញ្ហាសិទ្ធិមនុស្ស និងបញ្ហាទឹក

វិទ្យុវាទីកង់បានរាយការណ៍ថា កាលពីពេលថ្មីៗកន្លងទៅនេះ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបាន អញ្ជើញចូលរួមនៅក្នុងសន្និសិទមួយដែលគេរៀបចំឡើងនៅក្នុងបុរីវាទីកង់អំពីសិទ្ធិមនុស្សនៅក្នុងការទទួលបានទឹក។

ថ្លែងនៅក្នុងសិក្ខាសាលាស្តីដែលរៀបចំឡើងដោយបណ្ឌិតសភាវិទ្យាសាស្ត្រនៃព្រះសហគមន៍កាតូលិក សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានថ្លែងថា សំនួរអំពីការព្រួយបារម្ភអំពីសិទ្ធិនៅក្នុងការទទួលបានទឹក គឺកំពុងតែជាបញ្ហាប្រឈមមួយ ហើយបានរំឭកថា ទឹកសំខាន់ណាស់ដោយសារតែ ទីណាដែលមានទឹកទីនោះនឹងមានជីវិតហើយក៏បានជំរុញឲ្យអ្នកចូលរួម ធ្វើការរិះគិតបញ្ហាប្រឈមនេះ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ទឹកគឺជាតម្រូវការរបស់មនុស្សគ្រប់គ្នា ដូច្នេះ វាត្រូវតែការពារ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងបន្តថា ទឹកនៅលើពិភពលោកនេះវាមានគ្រប់កន្លែង ប៉ុន្តែដាច់ខាតត្រូវតែមិនអាចមិននិយាយបានទេ អំពីបញ្ហាទឹកស្អាត មានសុវត្ថិភាព និង ទឹក ដែលមានគុណភាពសម្រាប់ជីវិត។

សម្តេចប៉ាបហ្សង់ស៊ីស្កូ បានថ្លែងថា ទឹកគឺជាមូលដ្ឋាននៃសិទ្ធិមនុស្ស ដែលទាមទារឲ្យមាន ដំណោះស្រាយមួយ កម្រិតជានយោបាយសាធារណៈមួយអំពីវា។

រហូតមកដល់ពេលបច្ចុប្បន្ននេះជារៀងរាល់ថ្ងៃមានកុមារ និងមនុស្សជាងមួយពាន់នាក់ ដែលស្លាប់ដោយសារតែបញ្ហាដែលពាក់ព័ន្ធនឹងបញ្ហាជំងឺដែលមកពីទឹក ហើយក៏មានមនុស្សរាប់លាននាក់ដែលកំពុងតែប្រើប្រាស់ទឹកដែលបំពុល ឬទឹកដែលមិនស្អាត ដូច្នេះយើងគួរតែផ្តោតការអប់រំទៅមនុស្សជំនាន់ក្រោយឲ្យយកចិត្តទុកដាក់នឹងបញ្ហាទឹក នេះ ឲ្យហើយ ។



## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ

## អភិបូជាបុណ្យរោយផេះនៅព្រះសហគមន៍បឹងទំពុន

អត្ថបទទី១៖ យអ ២,១២-១៤
អត្ថបទទី២៖ ២កូរ ៥,២០-៦,២
ដំណឹងល្អ៖ មថ ៦,១-៦,១៦-១៨

បងប្អូនជាទីស្រឡាញ់!

យើងបានស្តាប់នៅក្នុងអត្ថបទទីមួយ "ឥលូវនេះចូរនាំគ្នាវិលមករកយើងដោយស្មោះអស់ពីចិត្ត ចូរតមអាហារ យំសោក ហើយកាន់ទុក្ខ ចូរកែប្រែចិត្តគំនិត កុំហែកតែសម្លៀកបំពាក់ប៉ុណ្ណោះ ចូរវិលមករកព្រះជាអម្ចាស់"។ ថ្ងៃនេះដែលយើងចូលនៅក្នុងរដូវ៤០ថ្ងៃ ជាឱកាសមួយដើម្បីស្តាប់ព្រះបន្ទូលនេះម្តងទៀត ឥលូវនេះចូរនាំគ្នាវិញមករកយើង ព្រះសហគមន៍បានឲ្យពេលវេលាយើង៤០ថ្ងៃ ដើម្បីស្តាប់ និងអនុវត្តតាមព្រះបន្ទូលនេះ ឲ្យយើងវិលទៅរកព្រះជាម្ចាស់វិញ ដោយស្មោះអស់ពីចិត្ត។ យើងបានសប្បាយរួមជាមួយព្រះយេស៊ូប្រសូតប៉ុន្មានខែមុន បានសប្បាយជាមួយបងប្អូននៅក្នុងព្រះសហគមន៍។ ក្រោយមកយើងចូលទៅក្នុងរដូវធម្មតា យើងរវល់និងការងាររវល់នេះរវល់នោះ ពេលនេះយើងចូលនៅក្នុងរដូវ៤០ថ្ងៃ ជាឱកាសមួយដើម្បីនឹកឃើញតាមពិតព្រះជាម្ចាស់បន្តទន្ទឹងរងចាំយើង ឥលូវចូរវិលមករកព្រះអង្គវិញដោយស្មោះអស់ពីចិត្ត។ រដូវ៤០ថ្ងៃ ជាឱកាសមួយដើម្បីវិញត្រលប់មកវិញ ដើម្បីរកឃើញព្រះយេស៊ូដោយសារវិលត្រលប់មកវិញ ព្រោះព្រះយេស៊ូគង់នៅជាមួយយើងជានិច្ច។ ប៉ុន្មានដងប៉ុន្មានសារយើងគិតថា ព្រះយេស៊ូនៅឆ្ងាយពីបញ្ហាដែលយើងជួបជាប្រចាំថ្ងៃ ប៉ុន្តែនៅពេលយើងចូលនៅក្នុងរដូវ៤០ថ្ងៃនេះ យើងត្រូវតែរីវរល់ជាមួយព្រះជាម្ចាស់សារជាថ្មី ដោយដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា។ យើងធ្វើដូចម្តេចដើម្បីវិលត្រលប់មករកព្រះយេស៊ូវិញ?

នៅក្នុងសារលិខិតរបស់សម្តេចប៉ាបសម្រាប់រដូវ៤០ថ្ងៃនេះ សម្តេចប៉ាបបានអញ្ជើញយើង "ទីមួយ ឲ្យយើងទទួលស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះអំណោយទាន និងទីពីរ ឲ្យយើងទទួលស្វាគមន៍បងប្អូនឯទៀតៗជាអំណោយទានដែរ"។ ដើម្បីទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអំណោយទាន យើងមានរបៀបរបប ដែលព្រះសហគមន៍ណែនាំយើងជារៀងរាល់ឆ្នាំ ដូចយើងបានស្តាប់នៅក្នុងព្រះគម្ពីរដំណឹងល្អថា "ពេលណាអ្នករាល់គ្នាធ្វើទានដល់អ្នកក្រីក្រ ពេលណាអ្នករាក់គ្នាអធិដ្ឋាន ពេលណាអ្នករាល់គ្នាតមអាហារ" នេះជាសរសរទាំងបីដែលព្រះសហគមន៍ប្រគល់ឲ្យយើង ដើម្បីឲ្យយើងខិតខំត្រលប់មករកព្រះយេស៊ូដែលគង់នៅជាមួយយើងជាប្រចាំ។

ដើម្បីទទួលស្វាគមន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងពិសេស គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតយើង ទីមួយឲ្យយើងយល់ថា ព្រះសហគមន៍បានអញ្ជើញយើងឲ្យយើងអធិដ្ឋាន។ មុនគិតជួយអ្នកដទៃ មុនគិតអំពីការជួយបងប្អូនឯទៀតៗ ឲ្យយើងយកពេលវេលានៅក្នុង៤០ថ្ងៃនេះដើម្បីអធិដ្ឋាន។ ពេលយើងចូលនៅក្នុងការអធិដ្ឋានជាពេលវេលាមួយដែលយើងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង ជាពេលវេលាមួយដើម្បីចូលជ្រៅនៅក្នុងជីវិតរបស់យើងយ៉ាងពិតប្រាកដ។ ជារៀងរាល់ថ្ងៃក្នុងរដូវ៤០ថ្ងៃនេះឲ្យយើងរកពេលវេលាដើម្បីអធិដ្ឋាន កុំឲ្យយើងអធិដ្ឋានគ្រាប់តែសូត្រធម៌បពិត្រព្រះបិតា ឬបពិត្រព្រះនាងម៉ារីតែប៉ុណ្ណឹង ឲ្យយើងអធិដ្ឋានដោយបិទសម្លេងជុំវិញយើង ដូចព្រះយេស៊ូមានព្រះបន្ទូលថា "នៅពេលយើងអធិដ្ឋាន ឲ្យយើងចូលនៅក្នុងបន្ទប់របស់យើង នៅក្នុងបន្ទប់នៃដួងចិត្តរបស់យើង"។ យើងដឹងថា សង្គមរបស់យើងមានសម្លេងគ្រប់ទីកន្លែង ឲ្យយើងធ្វើដូចម្តេចដើម្បីយកពេលវេលាដប់ ដប់ប្រាំនាទី ក្នុងមួយថ្ងៃ ដើម្បីនៅស្ងៀមស្ងាត់។ មុនសូត្រធម៌ មុនអានព្រះគម្ពីរដំណឹងល្អ ឲ្យយើងនៅស្ងៀមស្ងាត់ដើម្បីឲ្យយើងដឹងថា យើងមានឈើឆ្កាង យើងមានព្រះយេស៊ូ មានព្រះនាងម៉ារី យើងអង្គុយដោយស្ងៀមស្ងាត់ ដើម្បីចូលទៅក្នុងដួងចិត្តរបស់យើង ដើម្បីទុកពេលវេលឲ្យព្រះយេស៊ូមានព្រះបន្ទូលដល់យើង។ បើយើងពោរពេញដោយ សម្លេងពីខាងក្រៅ ពោរពេញដោយសម្លេងនៅខាងក្នុង ដែលយើងកំពុងគិតណែនាំឲ្យព្រះជាម្ចាស់ពិបាកក្នុងការនិយាយដល់យើង។ ដូច្នេះមុនយើងគិតអំពីអ្វីៗទាំងអស់ ឲ្យយើងយកចិត្តទុកដាក់ដើម្បីរកភាពស្ងៀមស្ងាត់ជុំវិញយើង នៅក្នុងយើងដើម្បីទុកឱកាសឲ្យព្រះជាម្ចាស់មានព្រះបន្ទូលដល់យើង។ សម្តេចប៉ាប អញ្ជើញយើងឲ្យយើងស្តាប់ព្រះបន្ទូល ដោយសារតែព្រះបន្ទូល ដែលអាចណែនាំឲ្យយើងកែប្រែចិត្តគំនិត។ នៅក្នុង៤០ថ្ងៃនេះ ឲ្យយើងអានព្រះបន្ទូលជារៀងរាល់ថ្ងៃ ហើយយើងគិតអំពីព្រះបន្ទូលនេះមានន័យយ៉ាងម៉េចសម្រាប់ជីវិតរបស់យើង។ យើងមានទស្សនៈច្រើន ប៉ុន្តែធ្វើយ៉ាងណាឲ្យទស្សនៈរបស់យើងគំនិតរបស់យើង ចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងបានអានជារៀងរាល់ថ្ងៃ។ ពីមួយថ្ងៃទៅមួយថ្ងៃមានព្រះបន្ទូលមួយដែលណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី លុះត្រាតែយើងយកព្រះបន្ទូលនេះ ដើម្បីចូលយ៉ាងជ្រៅនៅក្នុងជីវិតយើង និងណែនាំឲ្យយើងកែប្រែចិត្តគំនិតតាមព្រះបន្ទូល។ ព្រះសហគមន៍ឲ្យយើងធ្វើ គឺសូមអ្នករាល់គ្នាតមអាហារ ដើម្បីមានផលប្រយោជន៍នៅក្នុងជីវិតរបស់យើង ដែលត្រលប់មករកព្រះយេស៊ូវិញ។ ក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខ្ញុំបានថារៀងរាល់ថ្ងៃសុក្រសប្តាហ៍ទីបីនៃខែនីមួយៗយើងតមអាហារ និងរាល់ថ្ងៃសុក្រក្នុងរដូវ៤០ថ្ងៃយើងក៏ត្រូវតមអាហារ។ ក្នុងខែនេះយើងអធិដ្ឋានសម្រាប់គ្រីស្តបរិស័ទដែលត្រូវគេបៀតបៀននៅក្នុងពិភពលោកទាំងមូល រួមជាមួយសម្តេចប៉ាប និងព្រះសហគមន៍សកល។ នៅពេលយើងតមអាហារ ដើម្បីឲ្យចូលនៅក្នុងដួងចិត្តរបស់យើងថែមទៀត ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀត ដើម្បីទុកឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់សូនបេះដូងរបស់យើង សូនជីវិតរបស់យើងឲ្យយើងមានជីវិតថ្មី។ ប្រសិនបើយើងមិនទុកឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្តិចម្តងៗកែប្រែចិត្តគំនិត និងកែទស្សនៈរបស់យើង កែឥរិយាបទរបស់យើង កែរបៀបរបស់យើង ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រៀបបីដូចជា ព្រះបន្ទូលដែលចូលមួយភ្លែត និងចេញតែម្តង។ ក្នុងសារលិខិតរបស់សម្តេចប៉ាប អញ្ជើញយើងឲ្យយើងសម្លឹងមើលព្រះបន្ទូលមួយ ដែលស្តីអំពីលោកឡាសា ដែលជាអ្នកក្រីក្រម្នាក់ ពីមួយថ្ងៃទៅមួយថ្ងៃនៅមុខទ្វាផ្ទះរបស់សេដ្ឋីម្នាក់ តែសេដ្ឋីម្នាក់នោះមិនមែនដាក់ទានសោះ។ ចុងក្រោយគេទាំងពីរបានស្លាប់ សម្តេចប៉ាបបានឲ្យយើងរិះគិតអំពីរបៀបរបស់សេដ្ឋីម្នាក់នោះ តាមពិតសេដ្ឋីម្នាក់នោះគាត់មានបញ្ហាច្រើនពេក ដែលណែនាំឲ្យគាត់ខ្វះភ្នែកដើម្បីមើលឃើញលោកឡាសា។ បញ្ហាទីមួយរបស់គាត់ គឺស្រឡាញ់លុយហួសហេតុ ណែនាំឲ្យខួរក្បាលរបស់គាត់គិតតែទ្រព្យសម្បត្តិ គាត់គិតធ្វើយ៉ាងណាដើម្បីរកស៊ីថែមទៀត។ បញ្ហាទីពីរ អំនួតរបស់គាត់ គាត់មានអំនួតពេញខ្លួនដោយបានគិតថាគាត់ជាមនុស្សល្អជាងគេ ជាមនុស្សដែលមានសមត្ថភាពជាងគេ ជាមនុស្សអស្ចារ្យជាងគេ។ បញ្ហាទីបី គឺគាត់មានការក្រអើតក្រទម ដែលណែនាំឲ្យគាត់ចង់បង្ហាញអំពីអ្វីដែលគាត់មាន ឲ្យមនុស្សទាំងអស់ឃើញ។ នេះជាពាក្យប្រស្នារបស់ព្រះយេស៊ូ២០០០ឆ្នាំមុន ប៉ុន្តែជាអ្វីដែលកំពុងកើតឡើងនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះដែរ។ យើងចង់បានទ្រព្យសម្បត្តិថែមទៀត យើងចង់អួតខ្លួនថាយើងមានសមត្ថភាពដែលយើងចង់ឲ្យគេឃើញ យើងចង់បង្ហាញគេមើលឃើញយ៉ាងច្បាស់ ថាយើងជាមនុស្សយ៉ាងមិច នេះដែលណែនាំឲ្យយើងបិទភ្នែក បិទត្រចៀក បិទដៃ បិទដួងចិត្តដើម្បីទទួលស្វាគមន៍បងប្អូនឯទៀតៗ។ ប្រសិនបើយើងសុខចិត្តតមអាហារ អ្វីៗទាំងអស់ដែលណែនាំឲ្យយើងបិទភ្នែក បិទដៃ បិទត្រចៀក បិទដួងចិត្តរបស់យើងបន្តិចម្តងៗព្រះបន្ទូលរបស់ព្រះជាម្ចាស់យាងចូលសារជាថ្មី។ ពេលសេដ្ឋីនៅដល់ឋាននរក គាត់បានសុំធ្វើយ៉ាងណាប្រាប់បងប្អូនគាត់កុំឲ្យធ្វើតាមគាត់ តែហួសពេលហើយដោយសារអស់មួយជីវិតរបស់គាត់ គាត់មានពេលដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែគាត់មិនយកពេលដើម្បីស្តាប់ព្រះបន្ទូលនេះ។ សម្រាប់យើងមានពេល៤០ថ្ងៃ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈការអធិដ្ឋាន តាមការតមអាហារ ដើម្បីឲ្យព្រះបន្ទូលយាងចូលនៅក្នុងខ្លួនយើង និងណែនាំឲ្យយើងកែប្រែចិត្តគំនិតយើងអាចទៅជាមនុស្សថ្មី។ ពេលយើងទៅជាមនុស្សថ្មី ពេលនោះយើងអាចធ្វើបុណ្យដាក់ទានដើម្បីជួយបងប្អូនឯទៀតៗ។ ប៉ុន្តែមុនគិតជួយអ្នកដទៃ មុនគិតអំពីអ្វីដែលយើងចង់ធ្វើសម្រាប់បងប្អូនឯទៀតៗ ឲ្យយើងកែប្រែខ្លួនសិន ឲ្យយើងភ្ជាប់ជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យយើងទទួលអំពើអាក្រក់នៅក្នុងជីវិតរបស់យើងយ៉ាងពិតប្រាកដមែនដើម្បីទៅជាមនុស្សថ្មី។ ពេលយើងទៅជាមនុស្សថ្មីហើយ យើងអាចជួយបងប្អូនឯទៀតៗ ក្នុងរដូវ៤០ថ្ងៃនេះជាឱកាសមួយដើម្បីសម្រេចចិត្តពីថ្ងៃនេះតទៅតើក្នុង៤០ថ្ងៃខាងមុខនេះខ្ញុំបានធ្វើអ្វីខ្លះ ដើម្បីចែករំលែកសេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ។

ធ្វើយ៉ាងណាក្នុង៤០ថ្ងៃនេះ ទីមួយ យកពេលដើម្បីអធិដ្ឋាននៅក្នុងបរិយាកាសស្ងៀមស្ងាត់ទាំងខាងក្រៅទាំងខាងក្នុង ទីពីរ យកពេលដើម្បីតមអាហារឲ្យជីវិតរបស់យើងលះបង់ចោលអ្វីដែលរាំងភ្នែក ត្រចៀក ដៃ ដួងចិត្តយើង ដើម្បីទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងមើលឃើញបងប្អូនឯទៀតៗ។ ទីបី ឲ្យយើងសម្រេចចិត្តយើងធ្វើអ្វីខ្លះ ដើម្បីជួយបងប្អូនឯទៀតជាក់ស្តែង គឺមានន័យថាឲ្យយើងធ្វើរៀងៗខ្លួន។ ឲ្យយើងសម្រេចចិត្តផ្ទាល់ខ្លួនយើងធ្វើអ្វីខ្លះ ដើម្បីឲ្យការសម្រេចចិត្តរបស់យើងយកទៅអនុវត្តជាក់ស្តែង។

នៅពេលនេះ យើងអធិដ្ឋានដោយស្ងៀមស្ងាត់ ដោយទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គជួយខ្ញុំ ដើម្បីឲ្យខ្ញុំត្រលប់ទៅរកព្រះអង្គវិញនៅក្នុងដួងចិត្តរបស់ខ្ញុំ សូមព្រះអង្គជួយខ្ញុំ ដើម្បីឲ្យខ្ញុំទទួលព្រះបន្ទូលរបស់ព្រះអង្គជាជីវិត សូមព្រះអង្គជួយខ្ញុំ ដើម្បីឲ្យខ្ញុំពិតមែនចែករំលែកអំណរសប្បាយសេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ ដោយសារបងប្អូនឯទៀតជាអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។ អាម៉ែន។

# លោកសុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានទទួលមរណភាពហើយ



រូបថតពី ហ្វេសបុក

សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានទទួលមរណភាពកាលពីថ្ងៃទី១៥ មីនា ២០១៧ នៅវេលាម៉ោង១៨:៣២នាទី នៅមន្ទីរពេទ្យទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ដោយរោគាពាធក្នុងជន្មាយុ ៦៦ឆ្នាំ។

យោងតាមព្រះរាជក្រឹត្យចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ នេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះនរោត្តម សីហមុនី បានសម្រេចតែងតាំងលោកសុខ អាន ដោយមានគោរមងារថ្មីជា "សម្តេចវិបុលបញ្ញា សុខ អាន" នោះបានឲ្យដឹងថា សម្តេចវិបុលបញ្ញា សុខ អាន បានចូលបម្រើជាតិមាតុភូមិតាមរយៈរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ សពរបស់សម្តេចបានដឹកតាមយន្តហោះមកដល់កម្ពុជានៅព្រឹកប្រលឹមថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ហើយត្រូវបានតម្កល់ធ្វើបុណ្យតាមប្រពៃណីនៅគេហដ្ឋានរហូតដល់ថ្ងៃអាទិត្យ។

សម្តេចវិបុលបញ្ញា សុខ អាន មានប្រវត្តិការសិក្សាដែលជាបណ្ឌិតកិត្តិយសផ្នែករដ្ឋបាលសាធារណៈ នយោបាយការទូតអប់រំគោលនយោបាយសាធារណៈ វិទ្យាសាស្រ្តនយោបាយ រដ្ឋបាលសាធារណៈ វិទ្យាសាស្រ្ត នីតិសាស្រ្តហើយជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា និងទទួលបានគោរមងារ បណ្ឌិតសភាចារ្យ។

សម្តេចវិបុលបញ្ញា សុខ អាន បានចូលរួមដឹកនាំប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ដោយបាននាំមកនូវសន្តិភាពជាតិ ឯកភាពជាតិ សេដ្ឋកិច្ចជាតិ ការអភិវឌ្ឍលើគ្រប់វិស័យ និងការពារនូវឯករាជ្យជាតិ និងបូរណភាពទឹកដីកម្ពុជា៕


# របៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម

ថ្ងៃទី០៦-០៧ ខែមេសា ឆ្នាំ២០១៧

ទីតាំង៖ ការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក

ផ្ទះលេខ២៥ ផ្លូវ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ ០២៣ ២២៤ ១២០

Email: csccambodia@gmail.com

**៤០$**

ចុះឈ្មោះចូលរៀនមុនថ្ងៃទី០៣ មេសា ២០១៧

ទទួលបានការបញ្ចុះតម្លៃ២០%។

មានអាហារសម្រន់២ពេល និងអាហារថ្ងៃត្រង់

## ខ្លឹមសារគោលនៃវគ្គបណ្តុះបណ្តាល

- អ្វីទៅជាប្រព័ន្ធផ្សព្វផ្សាយសង្គម?
- តើប្រព័ន្ធផ្សព្វផ្សាយសង្គមមានអ្វីខ្លះ?
- យល់ដឹងអំពីចំណុចវិជ្ជមាន និងអវិជ្ជមានក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបសរសេរក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមឲ្យមានប្រសិទ្ធភាព និងជៀសវាងការប្រឈមទោសទណ្ឌ
- របៀបបង្កើតគណនីក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម(Facebook) និងការបង្កើតគេហទំព័រ(Facebook Page)
- របៀបមើលនិងពង្រីកសក្ដានុពលរបស់គណនី និងគេហទំព័រ

## គោលដៅនៃវគ្គបណ្តុះបណ្តាល

- សិក្ខាកាមនឹងស្វែងយល់អំពីប្រព័ន្ធផ្សព្វផ្សាយសង្គមកាន់តែច្បាស់ ចេះពីរបៀបនៃការប្រើប្រាស់
- ចេះពីរបៀបនៃការសរសេរ និងការបញ្ចៀសហានិភ័យផ្ទាល់ខ្លួននិងក្នុងសង្គម។
- សិក្ខាកាមអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីរិះគន់ និងស្ថាបនាដែលជួយជាប្រយោជន៍ដល់សង្គមនិងជាតិ។
- សិក្ខាកាមអាចធ្វើជាអ្នកផ្តល់ពត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដោយមានប្រសិទ្ធភាព។

## ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧

- មូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្សព្វផ្សាយសង្គម៖
  - អ្វីទៅជាប្រព័ន្ធផ្សព្វផ្សាយសង្គម?
  - តើប្រព័ន្ធផ្សព្វផ្សាយសង្គមមានអ្វីខ្លះ?
  - ចំណុចវិជ្ជមាននិងអវិជ្ជមាននៃប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបសរសេរដើម្បីឲ្យមានការចាប់អារម្មណ៍
  - តើអ្នកចង់សរសេរអំពីអ្វី ហើយអ្វីទៅជាសារសំខាន់ក្នុងអត្ថបទរបស់អ្នក?
  - ការបង្រួមអត្ថបទឲ្យខ្លី និងមានខ្លឹមសារ
  - ការចម្លងអត្ថបទនិងសំយោគខ្លឹមសារអត្ថបទដកស្រង់
  - ការដាក់រូបភាពនិងអត្ថបទ
- ក្រមសីលធម៌ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម
  - ស្វែងយល់អំពីច្បាប់នានានៃការផ្សព្វផ្សាយ
  - អ្វីខ្លះដែលអ្នកអាចធ្វើបាន និងមិនអាចធ្វើបាន ដើម្បីបញ្ចៀសពីទោសទណ្ឌនានា

## ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧

- របៀបបង្កើតគណនីនានាក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម៖
  - Facebook, Facebook Page
  - Youtube
  - Twitter
  - Others.....
- របៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ (ផ្តោតសំខាន់លើ Facebook and Facebook Page)
- ការគ្រប់គ្រងលើគេហទំព័រ Facebook និងការបង្កើតឲ្យមានអ្នកចូលមើលកាន់តែច្រើន